actionaid

# បង់សំណាញ់ឲ្យទូលាយ



## កច្ចពិគ្រោះយោបល់ជាច្រើនទៀតគឺ ចាំបាច់សម្រាប់គម្រោងកំពង់ផែទេសចរណ៍កំពត

មករា ២០១៧

### អ្នកស្រាវជ្រាវ

ដានីញ៉ែល អ៊ី (Daniel Eyre) អ្នកដឹកនាំស្រាវជ្រាវ រ៉ាយស្តាត (RightsStart)
អៀង សុខា( Eng Sokha) អ្នកស្រាវជ្រាវ រ៉ាយស្តាត ( RightsStart)

### តាក់តែងក្រប និងទម្រង់របាយការណ៍

បុណ្យ រចនា ប្រធានផ្នែកសិទ្ធិទទួលបានសន្តិសុខស្បៀង អង្គការ អាក់សិនអេត កម្ពុជា
អ៊ិនវិន ព្រីនធីង (Invent Printing)

### បកប្រែរបាយការណ៍ពីភាសាអង់គ្លេសមកខេមរៈភាសា

សន រ៉ាមាណា

### រូបភាព

ដានីញ៉ែល អ៊ី (Daniel Eyre) ៖រូបលេខ ២ ៤ ៧ ៨ ៩ ១១ និង ១២
កែវ ស្រីស្រស់ រុន សុខខេង ប៉ាវ ហេងឡាលីន(Sreysros Keo, Sokheng Run and Henglalin Pao) ៖ រូបក្របមុខ និងរូបលេខ ៣ ៥ និង ៦
ធនាគារអភិវឌ្ឍន៍អាស៊ី, Digital Globe –រូបលេខ១
Digital Globe, CNES / Astrium – Figure 10
Pallas Investment Group – Figure 13

### របៀបដកស្រង់និងប្រើប្រាស់ព័ត៌មាននៅក្នុងរបាយការណ៍ ៖

Daniel Eyre, Eng Sokha, Casting a wider net: More consultation needed for the Kampot Pier Project, ActionAid Cambodia, 2017

### បោះពុម្ពដោយ៖

អង្គការ អាក់សិនអេត កម្ពុជា ក្រោមការគាំទ្រថវិការដោយ សហភាពអ៊ឺរ៉ុប
ខែមករា ឆ្នាំ២០១៧

### សេចក្តីបញ្ជាក់

ទស្សនៈបរិយាយនៅក្នុងរបាយការណ៍នេះគឺជាទស្សនៈ និងការរកឃើញផ្ទាល់របស់អ្នកស្រាវជ្រាវ។ ទស្សនៈទាំងអស់នេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអ៊ឺរ៉ុប នោះទេ។

### ដើម្បីទទួលបានរបាយការណ៍សូមទំនាក់ទំនង ៖ អាក់សិនអេត កម្ពុជា

ផ្ទះលេខ ៣៣ ផ្លូវ ៧១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៩៩៤ ៩៨៧ និង អ៊ីម៉ែល៖ e-mail.cambodia@actionaid.org

This report is distributed under the terms of the Creative Commons Attribution License which permits non-commercial use, distribution, and reproduction in any medium, provided the original author and the source are credited.

# សេចក្តីថ្លែងអំណរគុណ

អង្គការ អាក់សិនអេតកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រុមអ្នកឯកទេសស្រាវជ្រាវរបស់ រ៉ាយស្តាត (Rights Start) ដែលមានលោក ដានីញ៉ែល អ៊ី (Daniel Eyre) និង កញ្ញា អៀង សុខា(Eng Sokha) ដែលបានធ្វើការសិក្សាអង្កេតស្រាវជ្រាវនេះ "*បង់សំណាញ់ឲ្យទូលាយ៖ កិច្ចពិគ្រោះយោបល់ជាច្រើនទៀតគឺចាំបាច់សម្រាប់គម្រោងកំពង់ផែទេសចរណ៍កំពត*"។ ទន្ទឹមនេះយើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការចូលរួមផ្តល់មតិយោបល់របស់អស់លោកដែលជាមន្ត្រីឯកទេសប្រចាំនៅធនាគារអភិវឌ្ឍន៍អាស៊ី(ADB) មន្ត្រីឯកទេសប្រចាំនៅក្រសួងទេសចរណ៍រាជធានីភ្នំពេញ និងមន្ទីទេសចរណ៍ខេត្តកំពត មន្ទីមន្ទីដែនដី នគររូបនីយកម្ម និងសំណង់ខេត្តកំពត និងមន្ទីបរិស្ថានខេត្តកំពត និងរដ្ឋបាលជលផលខេត្តកំពត។

អង្គការ អាក់សិនអេតកម្ពុជា ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំគ្រប់រូបនៅឃុំជុំគ្រាល ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ និង គណៈកម្មការគ្រប់គ្រងរបស់សហគមន៍នេសាទត្រពាំងសង្កែ និង សហគមន៍នេសាទកំពង់សាមគ្គី។ យើងខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកសហគមន៍នេសាទត្រពាំងសង្កែ និងក្នុងឃុំកូនសត្វគ្រប់រូបដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់ពួកគាត់ចូលរួមផ្តល់ព័ត៌មាន និងប្រឹក្សាជាមួយក្រុមអ្នកស្រាវជ្រាវ។ បើសិនជាគ្មានការចូលរួមយ៉ាងសកម្មនិងពេញលេញពីសំណាក់ពួកគាត់ទេ ការសិក្សាស្រាវជ្រាវនេះប្រាកដជាមិនអាចធ្វើបាននោះទេ។

អង្គការ អាក់សិនអេតកម្ពុជា សូមកោតសរសើរដល់ក្រុមការងារផ្នែកសិទ្ធិទទួលបានសន្តិសុខស្បៀងជាពិសេសសូមអរគុណដល់ កញ្ញា បុណ្យ រចនា ដែលជាប្រធានផ្នែក ដែលបានធ្វើការយ៉ាងសកម្មជាមួយក្រុមឯកទេសស្រាវជ្រាវ និងផ្តល់ទិសដៅជាយុទ្ធសាស្ត្រក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវនេះ ។

រាជធានីភ្នំពេញ ខែមករា ឆ្នាំ២០១៧<br>
ហ៊ុន បូរមី នាយិការប្រចាំប្រទេស<br>
អង្គការអាក់សិនអេត កម្ពុជា

# មាតិកា

សទានុក្រម ........ ២

សេចក្តីផ្តើម និងសេចក្តីសង្ខេប ........ ៤

ជំពូកទី ១ ៖ គម្រោងកំពង់ផែទេសចរណ៍កំពត ........ ១៥

ជំពូកទី ២ ៖ ក្របខ័ណ្ឌច្បាប់ ........ ២០

ជំពូកទី ៣ ៖ ដីធ្លី ........ ២៥

ជំពូកទី ៤ ៖ ជីវភាព ........ ៣១

ជំពូកទី ៥ ៖ កិច្ចពិគ្រោះយោបល់ ........ ៤៦

ជំពូកទី ៦ ៖ គម្រោងផ្សេងទៀតនៅឆកសមុទ្រកំពត ........ ៥៤

សេចក្តីសន្និដ្ឋាន ........ ៦១

# សទានុក្រម

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| CESCR | គណៈកម្មាធិការស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| EIA | ការវាយតម្លៃផល ប៉ះពាល់បរិស្ថាន ៖ ឯកសារដែលតម្រូវដោយច្បាប់កម្ពុជា ដែលត្រូវតែអនុម័តដោយក្រសួងបរិស្ថាន មុននឹងគម្រោងដែលអាចនឹងបង្កផលប៉ះពាល់ អាចដំណើរការសាងសង់បាន។ |
| EMC | ទីប្រឹក្សាគ្រប់គ្រងបរិស្ថាន |
| EMP | ផែនការតាមដានបរិស្ថាន ៖ ឯកសារដែលរៀបចំដោយទីប្រឹក្សា សម្រាប់ក្រសួងទេសចរណ៍ ដែលជាឯកសារមួយក្នុងកិច្ចសន្យាផ្ដល់ប្រាក់កម្ចីរវាង ADB និង រាជរដ្ឋាភិបាលកម្ពុជា សម្រាប់កំពង់ផែទេសចរណ៍កំពត។ |
| FPIC | គោលការណ៍គោលការណ៍ស្ដីពីការជូនដំណឹងជាមុន និងព្រមព្រៀងដោយសេរី |
| ICCPR | កតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ICESCR | កតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| IEE | ការសិក្សាបរិស្ថានបឋម ៖ ឯកសារដែលរៀបចំដោយទីប្រឹក្សា សម្រាប់ក្រសួងទេសចរណ៍ ដែលជាឯកសារមួយក្នុងកិច្ចសន្យាផ្ដល់ប្រាក់កម្ចីរវាង ADB និងរាជរដ្ឋាភិបាលកម្ពុជា។ |
| IUCN | សហភាពអន្តរជាតិ ដើម្បីការអភិរក្សធម្មជាតិ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស |
| PCU | អង្គភាពសម្របសម្រួលគម្រោង ៖ គណៈកម្មាធិការដែលបង្កើតឡើងក្នុងក្រសួងទេសចរណ៍ ដើម្បីមើលការខុសត្រូវគម្រោងកំពង់ផែទេសចរណ៍កំពត។ |
| PIU | អង្គភាពអនុវត្តគម្រោង ៖ គណៈកម្មាធិការដែលបង្កើតឡើងក្នុងមន្ទីរទេសចរណ៍ក្នុងខេត្តកំពត ដើម្បីមើលការខុសត្រូវការអនុវត្តគម្រោងកំពង់ផែទេសចរណ៍កំពត។ |

| | |
|---|---|
| UN DRIP | សេចក្តីប្រកាសអង្គការសហប្រជាជាតិ ស្តីពី សិទ្ធិជនជាតិដើមភាគតិច |
| UNEP | កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ |
| VGGT | គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ ដី ជលផល និងព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀងជាតិ |

# សេចក្តីផ្តើម និងសេចក្តីសង្ខេប

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ហៅកាត់ថា ADB) បានព្រមព្រៀងគ្នាលើការផ្តល់ប្រាក់កម្ចីមួយចំនួនសម្រាប់សាងសង់កំពង់ផែទេសចរណ៍ក្បែរក្រុងកំពត នាទិសខាងត្បូងនៃប្រទេសកម្ពុជា។ កម្ចីនេះផ្តល់មូលនិធិសាងសង់កំពង់ផែ និងអាគារបរិក្ខារ នៅលើដីទំហំប្រមាណ ៤ ហិកតា នៅមាត់ស្ទឹងទឹកឈូ និងជួសជុលពង្រីកផ្លូវ ៦,៥ គីឡូម៉ែត្រដើម្បីភ្ជាប់កំពង់ផែនេះទៅផ្លូវជាតិលេខ ៣៣។

របាយការណ៍នេះនឹងវាយតម្លៃលើផលប៉ះពាល់ដែលនឹងអាចកើតមាន ដោយសារគម្រោងសាងសង់កំពង់ផែ មកលើសិទ្ធិដីធ្លី ជីវភាពរស់នៅប្រចាំថ្ងៃ និងសិទ្ធិចូលរួមក្នុងកិច្ចពិគ្រោះយោបល់របស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំក្បែរៗគ្នាចំនួនបី គឺឃុំជុំគ្រៀល ត្រពាំងសង្កែ និងកូនសត្វ។ បើទោះបីជាកំពង់ផែនេះ អាចមើលទៅហាក់ដូចជាមិនប៉ះពាល់ដល់សិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នេះ តែការសាងសង់ និងការដាក់កំពង់ផែនេះឲ្យប្រើប្រាស់ អាចនឹងប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីដែលងាយរងការបំផ្លិចបំផ្លាញក្នុងឆកសមុទ្រកំពត ដែលជាប្រភពផ្គត់ផ្គង់ដល់ជីវភាពរបស់ប្រជាពលរដ្ឋរាប់ពាន់ ឬអាចថារាប់ម៉ឺននាក់។ រដ្ឋាភិបាលបានស្នើវិធានការលម្អិតមួយចំនួនដើម្បីកាត់បន្ថយផលប៉ះពាល់ និងតាមដានការបំពុលបរិស្ថាននានា។ ដោយសារតែសិទ្ធិរបស់ប្រជាពលរដ្ឋអាចនឹងរងផលប៉ះពាល់ អ្នកនេសាទគួរតែត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចពិគ្រោះយោបល់អោយបានពេញលេញស្តីពីផែនការទាំងអស់នេះ។ ប្រជាពលរដ្ឋដែលក្រុមការងារស្រាវជ្រាវសម្ភាសន៍ក្នុងរបាយការណ៍នេះ កំពុងតែរង់ចាំព័ត៌មានដែលពេញលេញ និង មានខ្លឹមសារពី រដ្ឋាភិបាលពាក់ព័ន្ធនឹងគម្រោងនេះ និងគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត ក្នុងឆកសមុទ្រកំពតនេះ។

អនុសាសន៍សំខាន់ៗ ដែលរកឃើញក្នុងការស្រាវជ្រាវនេះគឺ ក្រសួងទេសចរណ៍ ដែលជាក្រសួងសាមីទទួលខុសត្រូវក្នុងការអនុវត្តគម្រោងកំពង់ផែទេសចរណ៍កំពត គួរតែពង្រីកវិសាលភាពនៃកិច្ចពិគ្រោះយោបល់ ដែលអាចរួមបញ្ចូលប្រជាពលរដ្ឋដែលនឹងអាចរងផលប៉ះពាល់ទាំងអស់ ជាពិសេស អ្នកនេសាទ ក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ។ កិច្ចពិគ្រោះយោបល់ដែលរៀបចំឡើង គួរតែផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋ ដើម្បីឲ្យពួកគាត់អាចវាយតម្លៃផលប៉ះពាល់នៃគម្រោងមកលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ និងអនុញ្ញាតឲ្យពួកគាត់ផ្តល់មតិយោបល់ត្រលប់មកលើផែនការគូរប្លង់កំពង់ផែ ក៏ដូចជា មកលើសំណើទាក់ទងនឹងការតាមដាន និងរាយការណ៍ស្តីពីផលប៉ះពាល់ និងរបៀបដែលពួកគាត់អាចដាក់ពាក្យបណ្តឹងបាន។

## គម្រោងកំពង់ផែទេសចរណ៍កំពត

ក្រសួងទេសចរណ៍ ជាអ្នកទទួលខុសត្រូវគ្រប់គ្រង និងអនុវត្តគម្រោងកំពង់ផែទេសចរណ៍កំពត នេះ។ ក្រសួងបានកំណត់ផែនការគម្រោង ក្នុងឯកសារដែលបានដាក់ស្នើទៅ ADB កាលពី ឆ្នាំ ២០១៤ រួមទាំងឯកសារការសិក្សាបរិស្ថានបឋម (IEE) និងផែនការតាមដានបរិស្ថាន (EMP)។ ADB បានយល់ព្រមផ្ដល់ថវិកាកំចីចំនួន ៩៥,៩ ភាគរយ នៃទឹកប្រាក់សរុបចំនួន ៩,៦២ លាន ដែលនេះជាថ្លៃចំណាយសរុបប៉ាន់ស្មានក្នុងការអនុវត្តគម្រោងនេះ។ របាយការណ៍នេះ ផ្អែកលើព័ត៌មានមានក្នុងឯកសារគម្រោងដែលមានស្រាប់ និងព័ត៌មានដែលទទួលបានតាមការសម្ភាសន៍ជាមួយ ក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ខេត្តកំពត និងបុគ្គលិក ADB ។ ទីប្រឹក្សាដែលក្រសួងទេសចរណ៍ជួលឲ្យមកធ្វើការលើគម្រោងនេះ កំពុងតែបញ្ចប់ចំណុចលម្អិតមួយចំនួនក្នុងផែនការសាងសង់កំពង់ផែនេះ និងធ្វើបច្ចុប្បន្នភាពលើផែនការតាមដានបរិស្ថាន (EMP)។ អនុសាសន៍នៅក្នុងរបាយការណ៍នេះ គួរតែដាក់បញ្ចូលទៅក្នុងឯកសារគម្រោង។ នៅពាក់កណ្ដាលដើម ឆ្នាំ២០១៧ មានការរំពឹងថានឹងត្រូវជួលក្រុមហ៊ុនម៉ៅការសាងសង់ឲ្យមកធ្វើការ ហើយការសាងសង់នឹងរំពឹងថាត្រូវបានបញ្ចប់នៅក្នុងត្រីមាសដំបូងនៃឆ្នាំ២០១៨។

## ក្របខ័ណ្ឌច្បាប់

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ចែងពីសិទ្ធិទទួលបានលំនៅឋានសមរម្យ សិទ្ធិទទួលបានសន្តិសុខសៀង និងសិទ្ធិចូលរួមក្នុងកិច្ចពិគ្រោះយោបល់ពេញលេញ ។ រដ្ឋធម្មនុញ្ញកម្ពុជាក៏បានបញ្ចូលនូវច្បាប់អន្តរជាតិទាំងនេះចូលក្នុងច្បាប់ជាតិដោយផ្ទាល់ផងដែរ មិនតែប៉ុណ្ណោះច្បាប់កម្ពុជាក៏ផ្ដល់នូវក្របខ័ណ្ឌមួយដែលសិទ្ធិទាំងនេះត្រូវបានការពារ គោរព និងបំពេញបន្ថែមដោយរដ្ឋាភិបាល។ ដើម្បីការពារជីវភាពប្រជាពលរដ្ឋដែលអាចនឹងកើតមានដោយសារការបំផ្លាញបរិស្ថាន ក្នុងច្បាប់ស្តីពី កិច្ចការពារបរិស្ថាន តម្រូវឲ្យគម្រោងស្នើរតែទាំងអស់រៀបចំ ការវាយតម្លៃផល ប៉ះពាល់បរិស្ថាន ដែលក្រសួងបរិស្ថានគួរតែជានាការអនុវត្តតាមច្បាប់នេះ។ អង្គការអន្តរជាតិ រួមមាន ADB មានកាតព្វកិច្ចគោរពច្បាប់អន្តរជាតិ រួមទាំងកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្សផងដែរ។

## សិទ្ធិដីធ្លី

អាជ្ញាធរខេត្តកំពត បានទិញដីទំហំប្រមាណបួនហិកតា ដើម្បីសាងសង់កំពង់ផែនេះពីអ្នកមានជីវភាពធូរធារម្នាក់កាលពីខែតុលា ឆ្នាំ២០១៥។ គម្រោងនេះហាក់ដូចជា មិនមានផលប៉ះពាល់អវិជ្ជមានមកលើសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋនោះទេ។ ក្នុងសហគមន៍ទាំងបី ដែលត្រូវបានសិក្សាសម្រាប់របាយការណ៍នេះ មានប្រជាពលរដ្ឋតែមួយចំនួនតូចប៉ុណ្ណោះដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់។ ប៉ុន្តែក្នុង ឆ្នាំ២០១៤ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចាប់ផ្តើមដំណើរការចុះបញ្ជីដីដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិក្នុងឃុំទាំងនេះ។ ប្រជាពលរដ្ឋភាគច្រើនកំពុងតែស្ថិតក្នុងដំណាក់កាលនៃនីតិវិធីចុះបញ្ជី

ដីធ្លីនៅឡើយ។ រដ្ឋាភិបាលគួរតែបន្តដំណើរការចុះបញ្ជីដី និងផ្តល់ប័ណ្ណកម្មសិទ្ធិ ដើម្បីធានាថាប្រជាពលរដ្ឋទាំងអស់មានប័ណ្ណកម្មសិទ្ធិដីធ្លីដែលមានសុវត្ថិភាព។ ក្នុងឃុំទាំងនេះ មានប្រជាពលរដ្ឋមួយចំនួនកំពុងតែរស់នៅលើដីរបស់រដ្ឋ។ ដំណោះស្រាយផ្សេងៗ គួរតែត្រូវបានពិចារណាជាមុន មុននឹងសម្រេចអោយមានការផ្លាស់ប្តូរលំនៅឋានរបស់ពួកគេ ដោយមានរៀបចំកិច្ចពិគ្រោះយោបល់ជាមួយអ្នកដែលអាចរងផលប៉ះពាល់ ហើយពួកគេក៏គួរតែទទួលបានការការពារអតិបរិមា ដូចបានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

## ជីវភាពប្រជាពលរដ្ឋ

ប្រជាពលរដ្ឋរាប់ពាន់ ឬអាចរាប់ម៉ឺននាក់ ពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ី ក្នុងឆកសមុទ្រកំពតដើម្បីជីវភាពរបស់ពួកគាត់។ មូលដ្ឋាន នៃប្រព័ន្ធអេកូឡូស៊ី មានគម្របស្មៅសមុទ្រច្រើនជាង ៨,៤៣៥ ហិកតា និងព្រៃកោងកាងប្រមាណ ១,៩៦០ ហិកតា។ ក្នុងចំណោមផលប្រយោជន៍ផ្សេងៗដែលទទួលបានមានដូចជា គម្របស្មៅសមុទ្រ និងព្រៃកោងកាងផ្តល់ជម្រកសម្រាប់បង្កាត់ពូជ របស់ត្រី និងសត្វសមុទ្រផ្សេងៗទៀតដែលអ្នកនេសាទអាចចាប់យកបាន ដែលពូជសត្វខ្លះកំពុងជិតផុតពូជ ។ ការប៉ាន់ស្មានគ្រួសៗ បានរកឃើញថាតម្លៃផ្នែកសេដ្ឋកិច្ចដែលបានមកពីគម្របស្មៅសមុទ្រ គឺប្រហែលជា ១០ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។[1]

ប្រជាពលរដ្ឋប្រហែលជា ៩,០០០ នាក់ ក្នុងឃុំត្រពាំងសង្កែ និងកូនសត្វ ប្រកបរបរនេសាទ ឬក៏ពឹងផ្អែកលើការនេសាទ ក្នុងឆកសមុទ្រកំពតសម្រាប់ជីវភាពរបស់ពួកគេ។ មានអ្នកនេសាទច្រើនជាង ១,១០០ នាក់ បានរួមគ្នាបង្កើតសហគមន៍នេសាទត្រពាំងសង្កែ និងសហគមន៍នេសាទកំពង់សាមគ្គី ដែលបានវិនិយោគលើប្រព័ន្ធអេកូឡូស៊ី និងការពារប្រព័ន្ធនេះពីការនេសាទខុសច្បាប់។ ប្រជាពលរដ្ឋទាំងប្រុស និងស្រី ប្រកបមុខរបររាវគ្រែង និងចាប់ក្តាមក្នុងព្រៃកោងកាង និងគម្របស្មៅសមុទ្រ ក្នុងទឹករាក់ៗតាមបណ្តោយឆ្នេរ។ អ្នកផ្សេងៗ ទៀតរុញឈឺបក្នុងសមុទ្រដោយដៃដើម្បីចាប់បង្គា ឬត្រីដោយប្រើទូកតូចៗ។

## *ជីវភាព៖ហានិភ័យនៃការបំពុលបរិស្ថាន*

ឯកសារគម្រោងរបស់ក្រសួងទេសចរណ៍ បានកំណត់ហានិភ័យដែលនឹងអាចកើតមានមកលើបរិស្ថាន តាមរយៈការបំពុលបរិស្ថាន ក្នុងអំឡុងដំណើរការសាងសង់ និងអំឡុងពេលប្រើប្រាស់កំពង់ផែ។ ការបំពុលបរិស្ថានអាចបំផ្លាញប្រព័ន្ធអេកូឡូស៊ី ដូច្នេះ នឹងកាត់បន្ថយប្រភពចំណីអាហាររបស់ប្រជាពលរដ្ឋ ដែលជាធាតុផ្សំសំខាន់មួយនៃសិទ្ធិក្នុងការទទួលបានសន្តិសុខស្បៀង។ ក្រសួងទេសចរណ៍បានស្នើវិធានការដើម្បីកាត់បន្ថយហានិភ័យនៃការបំពុលបរិស្ថាន។ វិធានការទាំងនេះគួរតែត្រូវបានអនុវត្តឲ្យបានពេញលេញ និងមានការតាមដានឲ្យ

[1] ផ្អែកលើតម្លៃប៉ាន់ប្រមាណរបស់គម្របស្មៅសមុទ្រ នៅកម្ពុជាក្នុងមួយហិកតា ពីកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ និងការប៉ាន់ប្រមាណថ្មីបំផុតពីទំហំលាតសន្ធឹងរបស់ស្មៅសមុទ្រ ដែលបានពីសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ។ សូមអាន ជំពូកទី ៤ នៃរបាយការណ៍នេះដើម្បីព័ត៌មានបន្ថែម។

ទៀងទាត់ និងជានាការអនុវត្តឲ្យបានត្រឹមត្រូវ។

*__ជីវភាព៖ ការធ្វើដំណើរទៅរក ធនធានជលផល__*

អ្នកនេសាទ ព្រួយបារម្ភថាកំពង់ផែថ្មីនេះ នឹងរារាំងពួកគេមិនឲ្យចូលទៅនេសាទនៅម្តុំកោះស្មៅ ឬក៏តំបន់នេសាទជុំវិញភ្នំដូង នៅទិសខាងលិចទីក្រុងកំពត។ ការរារាំងនេះ នឹងកាត់បន្ថយលទ្ធភាពនេសាទ ដែលជាផ្នែកមួយនៃសិទ្ធិទទួលបានសន្តិសុខស្បៀង។ ក្រសួងទេសចរណ៍បានស្នើឲ្យបង្កើត ផែនការគ្រប់គ្រងនាវាចរណ៍ ដែលនឹងចែងពីបទប្បញ្ញត្តិក្នុងការប្រើប្រាស់ផ្លូវទឹក។ ផែនការនេះគួរតែជានាថាសហគមន៍ ដែលនៅទិសខាងកើតនៃកំពង់ផែនឹងនៅតែអាចឆ្លងកាត់ផ្លូវទឹកដែលនៅចំពីមុខកំពង់ផែនេះបាន។ អ្នកនេសាទដែលប្រើផ្លូវទឹកនេះ គួរតែមានអ្នកតំណាងចូលរួមក្នុងគណៈកម្មាធិការ បង្កើតផែនការគ្រប់គ្រងនាវាចរណ៍នេះ ដើម្បីឲ្យពួកគេអាចការពារផលប្រយោជន៍របស់ពួកគេ
បាន។

*__ជីវភាព៖ ការតាមដាន__*

ក្រសួងទេសចរណ៍ បានរកឃើញផលប៉ះពាល់ផ្នែកបរិស្ថានដែលអាចនឹងកើតមាន ដោយសារតែការអនុវត្តគម្រោង និងបានស្នើវិធានការដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ។ បន្ថែមពីលើនេះ ក្រសួងបានស្នើថាការសាងសង់នឹងត្រូវបានតាមដានដោយប្រុងប្រយ័ត្នពី ទីប្រឹក្សាតាមដានបរិស្ថាន ឯករាជ្យ(EMC) និងមន្ទីរទេសចរណ៍។ ប៉ុន្តែ ឯកសារគម្រោងបានកត់សម្គាល់នូវអវត្តមានរបស់អ្នកជំនាញដែលមានចំណេះដឹងក្នុងមន្ទីរនេះ និងមិនបានបញ្ជាក់ថា តើមានជំហានអ្វីខ្លះនឹងត្រូវអនុវត្ត ប្រសិនបើរកឃើញភស្តុតាងបញ្ជាក់ពីការបំផ្លិចបំផ្លាញបរិស្ថាន។ ផែនការតាមដានបរិស្ថាន(EMP) កំពុងត្រូវបានកែលម្អជាថ្មី ហើយនឹងដាក់ជូនទៅក្រសួងបរិស្ថាន ជា ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) របស់គម្រោង។ ផែនការនេះគួរតែបន្ថែមនូវព័ត៌មានស្តីពីវិធីសាស្ត្រ ដែលមន្ទីរទេសចរណ៍នឹងរៀបចំការបណ្តុះបណ្តាល និងជំហានដែលត្រូវអនុវត្ត ក្នុងករណីដែលរកឃើញផលប៉ះពាល់បរិស្ថាន។ របាយការណ៍ទាំងអស់គួរតែចែករំលែកជាមួយ មន្ទីរបរិស្ថាន ដើម្បីឲ្យពួកគេអាចបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់របស់ពួកគេ ក្នុងកិច្ចការពារបរិស្ថាន។

**សិទ្ធិចូលរួមកិច្ចពិគ្រោះយោបល់ពេញលេញ**

IEE និង EMP ត្រូវបានបង្កើតឡើងបន្ទាប់ពីមានកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ រួមទាំងប្រជាពលរដ្ឋចំនួន ១០០ នាក់ មកពីឃុំជុំគ្រៀល និងឃុំកំពង់កណ្តាល។ កិច្ចពិគ្រោះយោបល់បឋមទាំងនេះ មិនបានបញ្ចូលឃុំត្រពាំងសង្កែ និងឃុំកូនសត្វនោះទេ។ អាជ្ញាធរខេត្តកំពត ក៏បានជូនដំណឹងដល់ប្រធានក្រុមប្រឹក្សាឃុំ និងប្រធានគណៈកម្មាធិការ សហគមន៍នេសាទ ស្តីពីគម្រោងសាងសង់កំពង់ផែ ក្នុងអំឡុងកិច្ចប្រជុំអំពីគម្រោងផ្សេងៗក្នុង ឆ្នាំ២០១៤។ រដ្ឋាភិបាលពុំទាន់បានខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីការពារ លើកស្ទួយ និងគោរពសិទ្ធិអ្នកនេសាទក្នុងការទទួលបានព័ត៌មាន និងចូលរួមក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ជីវភាព

របស់ពួកគេ នៅឡើយទេ។ កិច្ចពិគ្រោះយោបល់បន្ថែមទៀតត្រូវបានដាក់ក្នុងផែនការ។ ពួកគេគួរតែជានាថាប្រជាពលរដ្ឋដែលនឹងអាចរងផលប៉ះពាល់ទាំងអស់ទទួលបានព័ត៌មាន និងចូលរួមក្នុងកិច្ចពិគ្រោះយោបល់ដ៏មានអត្ថន័យ ពាក់ព័ន្ធនឹងគម្រោង រួមទាំងអ្នកនេសាទ ក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ។

***កិច្ចពិគ្រោះយោបល់៖ ការប្រាស្រ័យទាក់ទង***

ប្រជាពលរដ្ឋដែលក្រុមអ្នកស្រាវជ្រាវបានសម្ភាសន៍ភាគច្រើន យល់ថាគម្រោងនេះអាចនឹងផ្តល់ផលប្រយោជន៍ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេព្រួយបារម្ភថា ពួកគេមិនមាន ចំណេះដឹងគ្រប់គ្រាន់ដើម្បីប្រកួតប្រជែង និងទទួលបានការងារដែលបង្កើតដោយគម្រោងកំពង់ផែទេសចរណ៍នេះបានទេ ឬអាចថាផលប្រយោជន៍ដែលពួកគាត់នឹងទទួលបានមានដូចជា ការទាក់ទាញភ្ញៀវទេសចរណ៍ ប្រហែលជាបានប្រាក់ចំណូលទាបជាងការនេសាទ។ ក្នុងករណីមួយចំនួន ការព្រួយបារម្ភរបស់ប្រជាពលរដ្ឋត្រូវបានដោះស្រាយរួចរាល់ហើយ នៅក្នុងសំណើដែលមានស្រាប់។ កង្វះខាតផ្នែកព័ត៌មាន គូសបញ្ជាក់ពីតម្រូវការឲ្យមានការប្រាស្រ័យទាក់ទងបន្ថែមទៀត។ អ្នកដែលត្រូវបានសម្ភាសន៍ ស្នើថារដ្ឋាភិបាលគួរតែផ្តល់ដំណឹងនិងព័តមានឲ្យពួកគាត់ដឹងអំពីគម្រោង និងពិគ្រោះយោបល់ជាមួយពួកគាត់ក្នុងវេទិកាសាធារណៈតាមរយៈអាជ្ញាធរមូលដ្ឋាន ឬក៏សហគមន៍នេសាទ។

***កិច្ចពិគ្រោះយោបល់៖ យន្តការដាក់ពាក្យបណ្តឹង***

គម្រោងនឹងបង្កើតយន្តការសារទុក្ខ ដើម្បីអនុញ្ញាតឲ្យប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងពីផលប៉ះពាល់ដែលកើតឡើងដោយសារគម្រោង។ ផ្នែកមួយនៃកិច្ចពិគ្រោះយោបល់ជាបន្តបន្ទាប់ គឺអ្នកអនុវត្តគម្រោងគួរតែសុំយោបល់ពីក្រុមអ្នកនេសាទ ពី យន្តការនៃការាយការណ៍ និងដាក់ពាក្យបណ្តឹង អោយបានសមរម្យ ។

**គម្រោង អភិវឌ្ឍន៍ផ្សេងៗទៀត**

កាលពីប្រាំឆ្នាំមុន ការអភិវឌ្ឍន៍នៅលើទីតាំងគម្រោងបានបង្កផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ក្នុងឆកសមុទ្រកំពត។ ការចាក់ដីបំពេញបានបង្កមហន្តរាយដល់ព្រៃកោងកាងនៅតាមឆ្នេរសមុទ្រ ព្រៃនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាប្រព័ន្ធអេកូឡូស៊ីសម្រាប់អ្នកនេសាទក្នុងតំបន់។ រយៈពេលជាច្រើនឆ្នាំមកនេះ ឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូត្រូវបានស្តារ ដែលបានបំផ្លាញគម្របស្មៅ សមុទ្រ និងរារាំងអ្នកនេសាទមិនឲ្យចូលទៅតំបន់ដែលសម្បូរធនធាននៅឆកសមុទ្រកំពត។ ការស្តារឃ្លោងសមុទ្រនេះគួរតែផ្អាកជាបណ្តោះអាសន្ន និងគួរតែរៀបចំកិច្ចពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាននៃការស្តារនេះ។

រដ្ឋាភិបាលកម្ពុជាកំពុងតែពិចារណាលើសំណើមួយចំនួន ទាក់ទងនឹងគម្រោងទេសចរណ៍ថ្មីៗក្នុងឆកសមុទ្រកំពត។ សំណើទាំងនោះរួម

បញ្ចូល "ក្រុងកំពតថ្មី" ជាកោះទេសចរណ៍ដែលនឹងត្រូវសាងសង់នៅលើដីសមុទ្រដែលត្រូវបានចាក់បំពេញ ទំហំប្រមាណ ២៤៨ ហិកតា និង "French Riveria City" ជាកោះទេសចរណ៍ចំនួនពីរ នឹងត្រូវបានសាងសង់លើដីសមុទ្រដែលត្រូវបានចាក់បំពេញ ទំហំប្រហែល ៤.០០០ ហិកតា រវាងខេត្តកែប និងកំពត។ គម្រោងទាំងនោះ គឺផ្សេងពី គម្រោងកំពង់ផែទេសចរណ៍កំពត។ ប្រសិនបើគម្រោងនេះត្រូវបានសាងសង់ផលប៉ះពាល់ដ៏ធ្ងន់ធ្ងរមកលើជីវភាពប្រជាពលរដ្ឋរាប់ពាន់នាក់ ពិតជាមិនអាចចៀសវាងនោះទេ។ រដ្ឋាភិបាលត្រូវតែធានាថាមានកិច្ចពិគ្រោះយោបល់ពេញលេញជាមួយប្រជាពលរដ្ឋដែលនឹងទទួលផលប៉ះពាល់ មុនពេលដែលគម្រោងទាំងនេះត្រូវបានអនុម័ត។

## អនុសាសន៍

ពាក់ព័ន្ធនឹងផលប៉ះពាល់ដែលនឹងអាចកើតមានមកលើជីវភាពប្រជាពលរដ្ឋ របាយការណ៍នេះផ្តោតអនុសាសន៍របស់ខ្លួន លើការកាត់បន្ថយផលប៉ះពាល់ផ្សេងៗ និងដើម្បីធានាថាអ្នកនេសាទអាចចូលរួមក្នុងកិច្ចពិគ្រោះយោបល់ដ៏ពេញលេញមួយ។ ក្រសួងទេសចរណ៍ ជាអ្នកទទួលខុសត្រូវដើម្បីធានាថាវិធានការសម្រាលផលប៉ះពាល់គឺគ្រប់គ្រាន់ក្នុងការទប់ស្កាត់ការបំពុលបរិស្ថាន ហើយវិធានការទាំងនេះគួរតែត្រូវបានអនុវត្តអោយបានត្រឹមត្រូវ ។ ក្រសួងបរិស្ថានគួរតែអនុម័តលើរបាយការណ៍វាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន( EIA) ប្រសិនបើវិធានការដែលបានដាក់ស្នើនោះ គ្រប់គ្រាន់ក្នុងការទប់ស្កាត់ការខាតបង់នៃជីវភាពប្រជាពលរដ្ឋ និងគួរតែរៀបចំយន្តការតាមដានផ្ទាល់ខ្លួនលើប្រព័ន្ធអេកូឡូស៊ីនៅឆកសមុទ្រកំពត។ ក្រសួងទេសចរណ៍គួរតែរៀបចំកិច្ចពិគ្រោះយោបល់អោយបានពេញលេញ ជាមួយប្រជាពលរដ្ឋទាំងអស់ ដែលអាចនឹងរងផលប៉ះពាល់ ជាពិសេសប្រជាពលរដ្ឋក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ។ ពួកគេគួរតែអាចចូលរួមពិគ្រោះយោបល់ពាក់ព័ន្ធនឹងការគូរប្លង់កំពង់ផែ ក៏ដូចជា ប្រព័ន្ធតាមដាន និងរាយការណ៍ទៅលើផលប៉ះពាល់នៃគម្រោង និងរបៀបដាក់ពាក្យបណ្តឹង។ ADB គួរតែគាំទ្រក្រសួងទេសចរណ៍ ដើម្បីអនុវត្តអនុសាសន៍ទាំងអស់នេះ។

គម្រោងកំពង់ផែទេសចរណ៍កំពត អាចធ្វើឲ្យតម្លៃដីកើនឡើង ហើយគម្រោងអភិវឌ្ឍន៍ផ្សេងទៀតក្នុងពេលអនាគតអាចនឹងបង្កហានិភ័យដល់សិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋ។ មន្ទីររៀបចំដែនដី គួរតែបញ្ចប់ដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធក្នុងឃុំតាមឆ្នេរសមុទ្រ ដើម្បីធានាសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ។

### *អនុសាសន៍លម្អិតនឹងត្រូវបានកំណត់ដូចខាងក្រោម ៖*

### *<u>សិទ្ធិដីធ្លី</u>*

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖**

- ថ្វីបើមន្ទីរនេះមិនពាក់ព័ន្ធដោយផ្ទាល់ក្នុងគម្រោងកំពង់ផែទេសចរណ៍កំពតក៏ដោយ ប៉ុន្តែមន្ទីរនេះ គួរតែចាប់ផ្តើមដំណើរការចុះបញ្ជីដីធ្លី ក្នុងភូមិដែលនៅសេសសល់ក្នុងឃុំ

កូនសត្វ និងធានាថាប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំជុំគ្រៀល ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ ឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដើម្បីធានាសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លី។

- សម្រាប់ប្រជាពលរដ្ឋដែលរស់នៅលើដីរដ្ឋអាជ្ញាធរគួរតែស្វែងរកមធ្យោបាយផ្សេងទៀត ក្រៅពីការផ្លាស់ប្តូរលំនៅឋានរបស់ពួកគេ ហើយគួរតែពិគ្រោះយោបល់ ជាមួយពួកគេអោយបានពេញលេញ ហើយពួកគេគួរតែទទួលបានកិច្ច ការពារជាអតិបរមាដូចមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

<u>ជីវភាព</u>

### ក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍ ៖

- ធានាថាវិធានការសម្រាលផលប៉ះពាល់ ក្នុងរបាយការណ៍ EMP/IEE ចុងក្រោយបង្អស់សម្រាប់គម្រោងកំពង់ផែទេសចរណ៍កំពតគ្រប់គ្រាន់ក្នុងការទប់ស្កាត់ផលប៉ះពាល់មកលើជីវភាពអ្នកនេសាទនៅក្នុងតំបន់ឆកសមុទ្រកំពត។
- តាមដានយ៉ាងទៀតទាត់ និងធានាការអនុវត្តឲ្យត្រឹមត្រូវនូវយន្តការដែលបានកំណត់ក្នុង របាយការណ៍ EMP/IEE ចុងក្រោយបង្អស់។
- បញ្ចូលសេចក្តីណែនាំ ក្នុងរបាយការណ៍ EMP/IEE ចុងក្រោយបង្អស់ ពីសកម្មភាពដែលនឹងត្រូវអនុវត្តដោយ អង្គភាពអនុវត្តគម្រោង (PIU) និង អង្គភាពសម្របសម្រួលគម្រោង (PCU) ប្រសិនបើមានភស្តុតាងបញ្ជាក់ពីការបំផ្លាញបរិស្ថាន។
- ប្រសិនបើការស្តារ ឬពង្រីកឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូបន្ថែម នឹងចាំបាច់ក្នុងអនាគត ដើម្បីអាចឲ្យទូកចូលទៅកាន់កំពង់ផែថ្មី ការសិក្សាលើបរិស្ថានលម្អិត និងកិច្ចពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ គួរត្រូវបានធ្វើឡើងជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់។
- ធានាថាគម្រោងគ្រប់គ្រងនាវាចរណ៍ អាចឲ្យអ្នកនេសាទឆ្លងកាត់ផ្លូវទឹក ដោយមិនប៉ះពាល់ដល់លទ្ធភាពនេសាទរបស់ពួកគាត់។
- ធានាថាអ្នកនេសាទដែលឆ្លងកាត់ផ្លូវទឹក មានអ្នកតំណាងក្នុងគណៈកម្មាធិការ ដែលបង្កើតផែនការគ្រប់គ្រងនាវាចរណ៍ ដើម្បីឲ្យពួកគេអាចការពារផលប្រយោជន៍របស់ពួកគេ។
- រួមបញ្ចូលព័ត៌មាន ស្តីពីការរាយការណ៍ទៅកាន់ភាគីពាក់ព័ន្ធ ជាសូចនាករតាមដានការអនុវត្តគម្រោង ដែលគួរតែបញ្ចូលក្នុងរបាយការណ៍ប្រចាំត្រីមាសរបស់ PIU។
- ចែករំលែករបាយការណ៍តាមដានបរិស្ថាន រួមទាំងទិន្នន័យបឋមដែលប្រមូលដោយ EMC ជូនក្រសួងបរិស្ថាន ដូចបានដាក់ស្នើក្នុង EMP/IEE។

### ក្រសួងបរិស្ថាន និងមន្ទីរបរិស្ថាន ៖

- ដាក់ទិន្នន័យបរិស្ថានដែលពាក់ព័ន្ធទាំងអស់ស្តីពីឆកសមុទ្រកំពត ជាសាធារណៈ រួមទាំង EIAs ដែលពាក់ព័ន្ធនឹងគម្រោងនានាក្នុងឆកសមុទ្រនេះ។

- ធានាថា EIA សម្រាប់គម្រោងកំពង់ផែទេសចរណ៍កំពត ត្រូវបានតាមដានយ៉ាងទៀងទាត់ និងធានាការអនុវត្តឲ្យបានត្រឹមត្រូវ។
- ធានាថាមានធនធានគ្រប់គ្រាន់ដែលអាចឲ្យមន្ទីរបរិស្ថាន សហការណ៍ជាមួយរដ្ឋបាលជលផល ដើម្បីប្រមូលព័ត៌មានជាទៀងទាត់ ស្តីពីសូចនាករវាស់វែងបរិស្ថាន ដូចជា គុណភាពទឹក និងទំហំគ្របដណ្តប់ និងគុណភាពគម្របស្មៅសមុទ្រ និងព្រៃកោងកាង។
- ធានាថាមានធនធានគ្រប់គ្រាន់ដែលអាចឲ្យមន្ទីរបរិស្ថាន តាមដានការអនុវត្ត EIA ឲ្យបានគ្រប់គ្រាន់ (ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យស្តីពី ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩)។

## ព័ត៌មាន និងកិច្ចពិគ្រោះយោបល់

### ក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍ ៖

- បញ្ចូលអ្នកនេសាទរស់នៅក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ ជាប្រជាពលរដ្ឋដែលនឹងរងផលប៉ះពាល់ ក្នុងកិច្ចពិគ្រោះយោបល់ និងផែនការព័ត៌មាន សម្រាប់គម្រោងកំពង់ផែទេសចរណ៍កំពត។
- រៀបចំការវាយតម្លៃបន្ថែមទៀត ដើម្បីកំណត់ចំនួនសហគមន៍ដែលអាចនេសាទ នៅក្នុងតំបន់កោះស្មោ ឬក៏ធ្វើដំណើររវាងកោះស្មោ និងតំបន់ឆ្នេរ ដើម្បីផ្គត់ផ្គង់ជីវភាពពួកគេ និងរួមបញ្ចូលប្រជាពលរដ្ឋទាំងនេះក្នុងកិច្ចពិគ្រោះយោបល់ និងផែនការរាយការណ៍។
- បកប្រែសេចក្តីសង្ខេបរបស់ IEE ជាភាសាខ្មែរ និងដាក់បង្ហាញនៅ លើគេហទំព័រ(អ៊ីនធើណិត)។
- ធានាកិច្ចពិគ្រោះយោបល់ដ៏ពេញលេញ ជាមួយសហគមន៍ដែលនឹងរងផលប៉ះពាល់ ដែល អនុលោមទៅនឹងគោលការណ៍ការស្តីអំពីការជូនដំណឹងជាមុន និងព្រមព្រៀងដោយសេរី រួមមានដូចជា ៖
    - រៀបចំកិច្ចប្រជុំជាសាធារណៈ ក្នុងសហគមន៍ដែលនឹងរងផលប៉ះពាល់ និងចែកចាយព័ត៌មានជាលាយលក្ខណ៍អក្សរជាភាសាខ្មែរក្នុងកិច្ចប្រជុំទាំងនេះ នៅសាលាឃុំ ទាំងអនឡាញតាមរយៈបណ្តាញសង្គម
    - ពន្យល់ពីគម្រោងកំពង់ផែទេសចរណ៍កំពត ស្តីពីស្ថានភាពបច្ចុប្បន្ន ផែនការសម្រាប់តាមដាន និងរាយការណ៍ ស្តីពីផលប៉ះពាល់របស់គម្រោង និងយន្តការដាក់ពាក្យបណ្តឹងដែលបានដាក់ស្នើ និង
    - ស្នើសុំ និងលៃលកពេលវេលាឲ្យបានគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋផ្តល់មតិយោបល់ លើផ្នែកផ្សេងៗនៃគម្រោង រួមទាំង ផែនការតាមដាន និងការរាយការណ៍ និងយន្តការដាក់ពាក្យបណ្តឹង។
- យ៉ាងហោចណាស់ ក្នុងការរាយការណ៍ទៅកាន់ប្រជាពលរដ្ឋដែលនឹងរងផលប៉ះពាល់ គួរតែរួមបញ្ចូលនូវការបើកចំហជាសាធារណៈ នៃរបាយការណ៍ប្រចាំត្រីមាសរបស់

PIU ដែលផ្ញើទៅ PCU ដោយភ្ជាប់របាយការណ៍ដែលបានមកពី EMC និងក្រុមហ៊ុនម៉ៅការសាងសង់ ជាឧបសម្ព័ន្ធ។

- តម្រូវថារាល់ឯកសារស្តីពីពាក្យបណ្តឹង នឹងត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំត្រីមាស របស់ PIU ដែលផ្ញើទៅ PCU។
  - ធានាថាប្រជាពលរដ្ឋបានយល់ដឹងថាពួកគេអាចដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការគ្រប់ពេលវេលា ហើយការចូលរួមក្នុងយន្តការដាក់ពាក្យបណ្តឹង នឹងមិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ពួកគេនោះទេ។

**ធនាគារអភិវឌ្ឍន៍អាស៊ី ៖**

- ធានាថាប្រជាពលរដ្ឋដែលនឹងរងផលប៉ះពាល់ ដឹងពីយន្តការទំនួលខុសត្រូវ និងតម្លាភាពរបស់ ADB ។
- គាំទ្រដល់ក្រសួងទេសចរណ៍ ដើម្បីអនុវត្តអនុសាសន៍ដែលបានកំណត់ក្នុងរបាយការណ៍នេះ។

**<u>គម្រោងអភិវឌ្ឍន៍ផ្សេង</u>**

**អាជ្ញាធរខេត្តកំពត ៖**

- ចាប់ផ្តើមកិច្ចពិគ្រោះយោបល់ដែលពេញលេញស្តីពីការស្តារឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូ ជាមួយអ្នកនេសាទដែលកំពុងតែប្រើប្រាស់ផ្លូវទឹកនោះ។
- ផ្អាកការស្តារឃ្លោងសមុទ្រ រហូតទាល់តែកិច្ចពិគ្រោះយោបល់ត្រូវបានរៀបចំរួចរាល់។
- ខណៈដែល អាជ្ញាធរខេត្តកំពត អភិវឌ្ឍន៍ផែនការសម្រាប់គម្រោងក្រុងកំពតថ្មី ពួកគាត់គួរតែបញ្ចេញព័ត៌មានទាំងនេះ និងបើកកិច្ចពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋដែលនឹងអាចរងផលប៉ះពាល់។

**ក្រសួងបរិស្ថាន ៖**

- រៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈ ស្តីអំពី EIAs ជាមួយប្រជាពលរដ្ឋដែលនឹងរងផលប៉ះពាល់ រួមទាំងការវាយតម្លៃផលប៉ះពាល់បរិស្ថានគម្រោងក្រុងកំពតថ្មី និង French Riviera City។

**ទីប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៖**

- ខណៈដែល ទីប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិវឌ្ឍន៍ផែនការសម្រាប់គម្រោង French Riviera City ពួកគាត់គួរតែបញ្ចេញព័ត៌មានទាំងនេះ និងបើកកិច្ចពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋដែលនឹងអាចរងផលប៉ះពាល់។

## វិធីសាស្ត្រ

គោលបំណងនៃការស្រាវជ្រាវមាន ៤ គឺ ៖

- "ចងក្រងជាឯកសារស្ដីពីសិទ្ធិកាន់កាប់ របស់សហគមន៍នេសាទត្រពាំងសង្កែ និងសហគមន៍នេសាទកំពង់សាមគ្គី ក្នុងការគ្រប់គ្រង និងការចាប់យកធនធានជលផល
- កំណត់ និងចងក្រងជាឯកសារស្ដីពីដំណើរការអភិវឌ្ឍន៍ ហើយមើលថាតើគោលការណ៍ការស្ដីអំពីការជូនដំណឹងជាមុន និងព្រមព្រៀងដោយសេរី (FPIC) ត្រូវបានអនុវត្តក្នុងករណីនេះដែរឬទេ
- ដើម្បីវាយតម្លៃផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ចដោយផ្ទាល់ និងដោយប្រយោល និងផលប៉ះពាល់ដែលនឹងអាចកើតមាននាពេលអនាគត មកលើអ្នកនេសាទ និងសហគមន៍នេសាទ និង
- កំណត់នូវវិធីសាស្ត្រ និងយុទ្ធសាស្ត្របែបស្ថាបនាដើម្បី ១) កាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ច នៃគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង ២) ធ្វើការជាមួយភាគីពាក់ព័ន្ធផ្សេងៗដើម្បីកំណត់យន្តការដែលសហគមន៍ អាជ្ញាធរ និងអ្នកវិនិយោគ អាចជួបពិភាក្សាគ្នាដើម្បីកាត់បន្ថយនូវផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ច លើជីវភាពរបស់សហគមន៍នេសាទ"។[2]

ដោយសារតែគម្រោងកំពង់ផែទេសចរណ៍កំពតមិនទាន់បានចាប់ផ្ដើមនៅឡើយ ក្រុមអ្នកស្រាវជ្រាវព្យាយាមកំណត់ប៉ះពាល់ដែលនឹងអាចកើតមានដោយសារគម្រោង ដោយបានសាកសួរអ្នកចូលរួមក្នុងការស្រាវជ្រាវនេះ អំពីផលប៉ះពាល់ដែលពួកគេទទួលរង ក្នុងគម្រោងអភិវឌ្ឍន៍ថ្មីៗកន្លងមកនេះ និងការរំពឹងទុករបស់ពួកគេពីគម្រោងកំពង់ផែទេសចរណ៍កំពត។ ក្នុងអំឡុងបទសម្ភាសន៍ ក្រុមអ្នកស្រាវជ្រាវបានទទួលព័ត៌មាន អំពីគម្រោងផ្អែកលើឯកសារដែលអាចស្វែងរកបានលើគេហទំព័ររបស់ ADB និងព័ត៌មានដែលទទួលបានក្នុងកិច្ចប្រជុំជាមួយក្រសួងទេសចរណ៍ អាជ្ញាធរខេត្តកំពត និងបុគ្គលិក ADB។

អំឡុងខែសីហា និងខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមការងារស្រាវជ្រាវបានសិក្សាលើឯកសារពាក់ព័ន្ធផ្សេងៗ សម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ និងចុះទៅកាន់ទីតាំងគម្រោងក្នុងឃុំជុំគ្រៀល។ ក្រុមអ្នកស្រាវជ្រាវបានជួបជាមួយមន្ត្រី ADB និងក្រសួងទេសចរណ៍ នៅទីក្រុងភ្នំពេញ និងមន្ទីរទេសចរណ៍ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរបរិស្ថាន និងរដ្ឋបាលជលផល នៅខេត្តកំពត។ ការិយាល័យអភិបាលខេត្តកំពតពុំបានឆ្លើយតបនឹងសំណូមពរសុំជួបរបស់ក្រុមការងារស្រាវជ្រាវនោះទេ។ ក្រុមស្រាវជ្រាវបានសម្ភាសន៍ប្រធានក្រុមប្រឹក្សាឃុំ ក្នុងឃុំជុំគ្រៀល ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ ប្រធានភូមិ ឬអនុប្រធានភូមិចំនួន ៣នាក់ និងគណៈកម្មាធិ

[2] អង្គការ ActionAid កម្ពុជា "លក្ខខ័ណ្ឌអនុវត្តគម្រោង ៖ ការសិក្សាបែបស៊ើបអង្កេត មកលើការទន្ទ្រានយកធនធានក្នុងខេត្តកំពត៖ 'ករណីសហគមន៍នេសាទត្រពាំងសង្កែ និងកំពង់សាមគ្គី'" ខែកក្កដា ឆ្នាំ២០១៦។

ការ សហគមន៍នេសាទត្រពាំងសង្កែ និងសហគមន៍នេសាទកំពង់សាមគ្គី។ ក្រុមការងារបានសម្ភាសន៍ប្រជាពលរដ្ឋចំនួន ១១នាក់មកពីឃុំត្រពាំងសង្កែ និង ១១ នាក់ទៀតមកពីឃុំកូនសត្វ។ ក្នុងចំណោមអ្នកសម្ភាសន៍ទាំងនេះ មានអ្នកចូលរួមជាបុរសចំនួន ៩ នាក់ និងជាស្ត្រីចំនួន ១៣ នាក់ ក្នុងនោះមាន ១៧ នាក់ ជាជនជាតិខ្មែរ និង៥ នាក់ ទៀតជាជនជាតិចាម។ ពួកគេត្រូវបានជ្រើសរើសដោយសារតែជីវភាពគ្រួសាររបស់ពួកគេពឹងផ្អែកមួយផ្នែក ឬទាំងស្រុងទៅលើការនេសាទ (រួមទាំង ការអូសបង្គា និងរាវគ្រែង និងក្តាម)។

បន្ទាប់ពីបានបញ្ចប់ការស្រាវជ្រាវ ក្រុមអ្នកស្រាវជ្រាវបានរៀបចំសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផលចំនួន ៣ ដើម្បីធ្វើបទបង្ហាញអំពីរបកគំហើញទាំងនេះ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មាន ឬទិន្នន័យវិភាគណាមួយ និងដើម្បីស្វែងរកមតិយោបល់ពីអ្នកចូលរួម។ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ក្រុមការងារស្រាវជ្រាវបានរៀបចំសិក្ខាសាលាមួយជាមួយគណៈកម្មាធិការមកពីសហគមន៍នេសាទចំនួន ២ និងសិក្ខាសាលាលើកទីពីរជាមួយ មន្ត្រីមកពីមន្ទីរទេសចរណ៍ មន្ទីរបរិស្ថាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលជលផលនៅខេត្តកំពត។ នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមការងារបានរៀបចំសិក្ខាសាលានៅទីក្រុងភ្នំពេញ។ ថ្វីបើមានការអញ្ជើញមន្ត្រីមកពីក្រសួងទេសចរណ៍ និង ADB ឲ្យចូលរួមក៏ដោយ តែក៏ពុំមានវត្តមានពួកគាត់ក្នុងសិក្ខាសាលានេះទេ។

## ជំពូក ១៖ គម្រោងកំពង់ផែនេសាទរណ៍កំពត




រូបទី១ ៖ រូបភាពបង្ហាញពីទីតាំងស្នើសម្រាប់សាងសង់គម្រោងកំពង់ផែ បានមកពីការសិក្សាបរិស្ថានបឋម ដែលបានដាក់ជូនទៅ ADB ។

## សាវតារគម្រោង

ធនាគារអភិវឌ្ឍន៍អាស៊ី (ហៅកាត់ថា ADB) គឺជាធនាគារថ្នាក់តំបន់ ដោយមានសាខានៅប្រទេសចំនួន ៦៧។ ធនាគារនេះបានផ្តល់ថវិកាចំនួន ២,៦៥ ពាន់លាន ដុល្លារអាមេរិក ដល់កម្ពុជាក្នុងទម្រង់ជាប្រាក់កម្ចី ជំនួយឥតសំណង និងជំនួយផ្នែកបច្ចេកទេសតាំងពី ឆ្នាំ១៩៦៦។[3] បច្ចុប្បន្ននេះ ADB កំពុងផ្តល់ជំនួយដល់គម្រោងនានាដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សម្រាប់ទាំងអស់គ្នាដោយគ្មានការរើសអើង ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មថ្នាក់តំបន់។[4] នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ADB យល់ព្រមផ្តល់ប្រាក់កម្ចីដើម្បីគាំទ្រ គម្រោងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ក្នុងមហាអនុតំបន់ទន្លេមេគង្គ សម្រាប់ការលូតលាស់ប្រកបដោយបរិយាបន្ន។[5] គម្រោងនឹងបញ្ចូល ការសាងសង់ផ្សារនៅខេត្តកែប និងការសាងសង់កំពង់ផែនៅក្បែរក្រុងកំពត។




រូបទី១ ៖ រូបភាពបង្ហាញពីទីតាំងស្នើសម្រាប់សាងសង់គម្រោងកំពង់ផែ

គម្រោងកំពង់ផែទេសចរណ៍កំពត គ្រោងថានឹងត្រូវចំណាយថវិកាប្រមាណ ៩.៦២ លាន ដុល្លារអាមេរិក ហើយកម្ចីបានមកពី ADB នឹងរួមចំណែក ៩៥.៩ ភាគរយ នៃប្រាក់ចំណាយនៃគម្រោងសរុប។ គម្រោងត្រូវបានគូរប្លង់ឡើង ដើម្បីទាក់ទាញអ្នកទេសចរណ៍ ឲ្យមកខេត្តកំពត និងទីកន្លែងទាក់ទាញទេសចរណ៍ ផ្សេងទៀតនៅកម្ពុជា។ បន្ថែមពីលើការសាងសង់កំពង់ផែសម្រាប់អ្នកដំណើរហើយ គម្រោងនេះនឹងសាងសង់អាគារផ្សេងៗ រួមទាំងអាគារគយ និងអន្តោប្រវេសន៍ អាគារ និងតូបសម្រាប់សួរព័ត៌មាន ចំណតរថយន្ត អំពូលភ្លើង និងបង្គន់សាធារណៈ។ គម្រោងនេះក៏នឹងជួសជុលពង្រីកផ្លូវចូលមកកាន់កំពង់ផែ ប្រវែង ៦,៥ គីឡូម៉ែត្របថែមទៀតផង។ ផែនការណ៍នេះនឹងបញ្ចូល "ការធ្វើបទបង្ហាញពន្យល់ពីតំបន់ព្រៃកោងកាង

---

[3] ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) "ធនាគារអភិវឌ្ឍន៍អាស៊ី និងកម្ពុជា ៖ សលាកប័ត្រព័ត៌មាន" ខែមេសា ឆ្នាំ២០១៦។ អាចរកបាន ៖ https://www.adb.org/publications/cambodia-fact-sheet.

[4] ADB "ADB នៅកម្ពុជា ៖ យុទ្ធសាស្រ្តប្រចាំប្រទេស ឆ្នាំ២០១៤-២០១៨" ខែវិច្ឆិកា ឆ្នាំ២០១៤។ អាចរកបាន ៖ https://www.adb.org/documents/cambodia-country-partnership-strategy-2014-2018.

[5] ADB "កិច្ចសន្យាប្រាក់កម្ចី (កិច្ចប្រតិបត្តិការពិសេស) សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ក្នុងមហាអនុតំបន់ទន្លេមេគង្គ សម្រាប់ការលូតលាស់ប្រកបដោយបរិយាបន្ន" ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤។ អាចរកបាន ៖ https://www.adb.org/projects/documents/loan-agreement-special-operations-gms-tourism-infrastructure-inclusive-growth-project-cambodia.

...ដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីសារៈសំខាន់ ក្នុងការរួមចំណែកក្នុងប្រព័ន្ធអេកូឡូស៊ី" របស់ព្រៃកោងកាង។[6]

គម្រោងនេះនឹងត្រូវសាងសង់នៅលើដីទំហំបួនហិកតា នៅមាត់ស្ទឹងទឹកឈូ ក្នុងឃុំជុំគ្រៀល ចម្ងាយប្រហែល ១០ គីឡូម៉ែត្រពីក្រុងកំពត (មើលរូបទី ១)។ ដីទាំងនេះបានទិញបន្តពីបុគ្គលឯកជន ដែលបានលក់ដីកន្លែងនេះទៅអាជ្ញាធរខេត្តកំពត នៅខែតុលា ឆ្នាំ២០១៥។ សំណង់នេះនឹងរួមបញ្ចូលនូវការលើកច្រាំងដើម្បីទប់ដីប្រវែង ១៥០ ម៉ែត្រ និងទំនប់រលកប្រវែង ៥០ ម៉ែត្រ ក្នុងទំហំដី ១,៥០០ ម៉ែត្រការ៉េ។

គម្រោងនេះត្រូវបានគូរប្លង់ នឹងត្រូវ អនុវត្តដោយ ក្រសួងទេសចរណ៍។ ទីប្រឹក្សាដែលធ្វើការជំនួសឲ្យក្រសួងទេសចរណ៍ រៀបចំការសិក្សាបរិស្ថានបឋម (IEE) និងផែនការតាមដានបរិស្ថាន (EMP) ក្នុងខែមីនា ឆ្នាំ២០១៤ និងផែនការសកម្មភាពសម្រាប់ការតាំងទីលំនៅថ្មី ក្នុងខែសីហា ឆ្នាំ២០១៥ និងផែនការសកម្មភាពយេនឌ័រ ដែលឯកសារទាំងនេះរួមគ្នាបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយ ADB ។ ក្រសួងទេសចរណ៍បានបង្កើត អង្គភាពសម្របសម្រួលគម្រោង (PCU) នៅភ្នំពេញ និងអង្គភាពអនុវត្តគម្រោង (PIU) នៅមន្ទីរទេសចរណ៍ខេត្តកំពត។ ទីប្រឹក្សាផ្នែកគ្រប់គ្រង និងគូរប្លង់លម្អិតត្រូវបានជួលក្នុងខែមីនា ឆ្នាំ២០១៦ ហើយកំពុងតែរៀបចំឯកសារដេញថ្លៃ និងប្លង់វិស្វកម្មលម្អិតដើម្បីរកក្រុមហ៊ុនម៉ៅការសាងសង់។[7] ក្រុមហ៊ុនម៉ៅការសាងសង់ នឹងត្រូវបានជួលនៅដើម ឆ្នាំ២០១៧ ដើម្បីអនុវត្តគម្រោង។[8]

## ផលប៉ះពាល់ និងវិធានការការពារ

ឯកសារគម្រោងបានបញ្ជាក់ថា គម្រោងនេះនឹងមានផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចជាវិជ្ជមាន ដែលនឹងធ្វើឲ្យជីវភាពរបស់ប្រជាពលរដ្ឋប្រសើរឡើង។ IEE ក៏បានរកឃើញផលប៉ះពាល់ជាអវិជ្ជមានមួយចំនួនទៅលើបរិស្ថានផងដែរ។ ផលប៉ះពាល់ទាំងនោះមាន ការបំពុលបរិស្ថានក្នុងអំឡុងពេលសាងសង់ និងផលប៉ះពាល់មកលើប្រព័ន្ធអេកូឡូស៊ីក្នុងឆកសមុទ្រកំពត ដោយសារតែកំណើនចរាចរណ៍ផ្លូវទឹក។ IEE កត់សម្គាល់ថា "ជម្រកដ៏សំខាន់នេះ ផ្តល់ការគាំពារដល់ពពួកសត្វដែលជិតផុត

[6] ទំព័រ i ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។ អាចរកបាន ៖ https://www.adb.org/projects/documents/gms-tourism-infrastructure-inclusive-growth-project-kampot-and-kep-provinces-iee.

[7] "តារាងទិន្នន័យគម្រោង" របស់ ADB ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦។ អាចរកបាន ៖ https://www.adb.org/projects/46293-004/main#project-pds.

[8] កិច្ចប្រជុំជាមួយក្រសួងទេសចរណ៍ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦។

ពូជ និងសត្វកម្រ ដូចជា ថនិកសត្វសមុទ្រ ភេសមុទ្រ អណ្តើកសមុទ្រ និងត្រី ក្តាម បង្គាចម្រុះ ក៏ដូចជាការនេសាទទាំងតាមឆ្នេរសមុទ្រ និងក្នុងសមុទ្រ"។[9]

ដើម្បីជួយសម្រាលហានិភ័យទាំងនេះ គម្រោងនេះនឹងបែងចែកទំនួលខុសត្រូវសម្រាប់អនុវត្តវិធានការការពារជាមួយតួអង្គផ្សេងៗគ្នា ដែលពាក់ព័ន្ធនឹងគម្រោង ដាក់ស្នើយន្តការកាត់បន្ថយផលប៉ះពាល់ជាក់លាក់ និងផ្តល់យោបល់ឲ្យរៀបចំកិច្ចពិគ្រោះយោបល់ និងដំណើរការតាមដាន រាយការណ៍ និងដាក់ពាក្យបណ្តឹង។

នៅក្នុង PCU នៅក្រសួង នឹងមានអង្គភាពសម្របសម្រួលវិធានការការពារ និងនៅក្នុង PIU នៅមន្ទីរក្នុងខេត្តកំពត នឹងមានអ្នកជំនាញផ្នែកការពារ។ អ្នកជំនាញផ្នែកការពារនឹងធ្វើការជាមួយមន្ត្រីបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការសាងសង់។ ទីប្រឹក្សាផ្នែកគ្រប់គ្រង និងគួរប្លង់លម្អិត នឹងរួមបញ្ចូលទាំងអ្នកជំនាញផ្នែកបរិស្ថានថ្នាក់ជាតិ និងអន្តរជាតិ ហើយពួកគេនឹងជួលទីប្រឹក្សាគ្រប់គ្រងបរិស្ថាន (EMC) ដើម្បីរៀបចំការស្រាវជ្រាវលក្ខណៈបច្ចេកទេសបែបវិទ្យាសាស្ត្រ។

EMP កំណត់វិធានការណ៍ជាក់លាក់មួយចំនួនដែលនឹងត្រូវអនុវត្ត ដើម្បីបញ្ចៀសផលប៉ះពាល់បរិស្ថានជាអវិជ្ជមាន។ ក្នុងច្បាប់កម្ពុជា គម្រោងនីមួយៗ តម្រូវឲ្យធ្វើការវាយតម្លៃផល ប៉ះពាល់បរិស្ថាន (EIA) ដែលនឹងត្រូវអនុម័តពីក្រសួងបរិស្ថាន។ EMP នឹងត្រូវបានពិនិត្យ និងកែសម្រួល នៅពេលដែលប្លង់លម្អិតនៃកំពង់ផែសម្រេចជាចុងក្រោយ និងដាក់ស្នើទៅក្រសួងបរិស្ថាន ជាការវាយតម្លៃផលប៉ះពាល់បរិស្ថានរបស់គម្រោង។

## កិច្ចពិគ្រោះយោបល់

ក្នុងឯកសារគម្រោង បានសំដៅដល់កិច្ចពិគ្រោះយោបល់ដែលអាចនឹងបានរៀបចំរួចរាល់ហើយ ឬនឹងត្រៀមរៀបចំ។ សៀវភៅមគ្គុទេសក៍រដ្ឋបាលគម្រោង បានចែងថា "ការសិក្សាបរិស្ថានបឋម និងផែនការតាមដានបរិស្ថាន ត្រូវបានរៀបចំក្នុងកិច្ចពិគ្រោះយោបល់ជាមួយនឹងសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធថ្នាក់ខេត្ត"។[10] EMP បញ្ជាក់ថា កិច្ចពិគ្រោះយោបល់បន្ថែមទៀតនឹងត្រូវរៀបចំឡើង មុនពេល ក្នុងអំឡុងពេល និងក្រោយពេល ការសាងសង់កំពង់ផែ។

[9] ទំព័រ ii ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

[10] ទំព័រ ៤២ ក្នុង "សៀវភៅមគ្គុទេសក៍រដ្ឋបាលគម្រោង" របស់ ADB ខែតុលា ឆ្នាំ២០១៤។ អាចរកបាន ៖ https://www.adb.org/projects/documents/cam-gms-tourism-infrastructure-inclusive-growth-project-pam.

**តាមដាន រាយការណ៍ និងដាក់ពាក្យបណ្ដឹង**

ក្រុមហ៊ុនម៉ៅការសាងសង់នឹងតម្រូវឲ្យរាយការណ៍ទៅ PIU ស្ដីពីការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់។ EMC នឹងតាមដានការគោរពតាមបទដ្ឋានបរិស្ថាន តាមរយៈការសិក្សាមើលទិន្នន័យមូលដ្ឋាន និងការតាមដានប្រចាំត្រីមាស ក្នុងដំណាក់កាលសាងសង់។ ទីប្រឹក្សានេះក៏តម្រូវឲ្យផ្ញើរបាយការណ៍ប្រចាំត្រីមាសទៅកាន់ PIU ផងដែរ។ ជាមួយគ្នានោះដែរ PIU នឹងត្រូវផ្ញើរបាយការណ៍ប្រចាំត្រីមាសទៅកាន់ PCU និងរៀបចំកិច្ចប្រជុំ ជាទៀងទាត់ជាមួយភាគីពាក់ព័ន្ធ។

គម្រោងនឹងបង្កើតគណៈកម្មាធិការទទួលពាក្យបណ្ដឹង ដែលនឹងទទួលខុសត្រូវដោះស្រាយនូវពាក្យបណ្ដឹងផ្សេងៗ។ សមាជិកសហគមន៍អាចដាក់ពាក្យបណ្ដឹងទៅកាន់គណៈកម្មាធិការទទួលពាក្យបណ្ដឹងថ្នាក់ឃុំ និងអាចដាក់បណ្ដឹងឧទ្ធរណ៍ទៅកាន់គណៈកម្មាធិការទទួលពាក្យបណ្ដឹងថ្នាក់ស្រុក និងខេត្តបាន។ ពួកគេក៏អាចប្រើប្រាស់ប្រព័ន្ធតុលាការកម្ពុជា និងយន្តការដាក់ពាក្យបណ្ដឹងរបស់ ADB បានដែរ។

**ជំហានបន្ទាប់**

នៅក្នុងកិច្ចប្រជុំក្នុងខែកញ្ញា ឆ្នាំ២០១៦ ក្រសួងទេសចរណ៍បានផ្ដល់ដំណឹងដល់ក្រុមការងារ អំពីស្ថានភាពបច្ចុប្បន្ននៃគម្រោង។ ទីប្រឹក្សាផ្នែកគ្រប់គ្រង និងគូរប្លង់លម្អិត កំពុងតែធ្វើការលើប្លង់លម្អិតសម្រាប់កំពង់ផែ និងឯកសារដេញថ្លៃដើម្បីរើសក្រុមហ៊ុនម៉ៅការសាងសង់។ ដំណើរការដេញថ្លៃនឹងត្រូវរៀបចំឡើង ក្នុងឆមាសទី១ ឆ្នាំ២០១៧។ ទីប្រឹក្សាជាតិ និងអន្តរជាតិ បានដាក់ស្នើកំណែផែនការតាមដានបរិស្ថាន(EMP) ដែលកែរួចទៅក្រសួងបរិស្ថាន និងកំពុងតែបញ្ចូលនូវមតិយោបល់របស់ក្រសួងទៅក្នុងផែនការនោះ។ ទីប្រឹក្សាគ្រប់គ្រងបរិស្ថាននៅមិនទាន់បានជ្រើសរើសនៅឡើយទេ។

ក្រសួងទេសចរណ៍ ក៏បានបញ្ជាក់ដែរថាផែនការដែលកំពុងស្ថិតក្រោមការពិចារណា មានបញ្ចូលគម្រោងសង់ផ្សារលើទីតាំងកំពង់ផែ ដែលជាគម្រោងដាច់ដោយឡែកពីគម្រោងកំពង់ផែទេសចរណ៍កំពត រដ្ឋាភិបាលកំពុងស្វែងរកឱកាសក្នុងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងខ្នាតមធ្យម ដើម្បីអនុញ្ញាតឲ្យប្រជាពលរដ្ឋអាចទទួលបានផលប្រយោជន៍ពីកំណើនទេសចរណ៍នេះផងដែរ។

យោងតាម ឯកសារមគ្គុទេសក៍រដ្ឋបាលគម្រោង គម្រោងនេះនឹងត្រូវបានបញ្ចប់នៅក្នុងត្រីមាសទី ១ ក្នុងឆ្នាំ ២០១៨។[11]

[11] ទំព័រ ១៣ ក្នុង "សៀវភៅមគ្គុទេសក៍រដ្ឋបាលគម្រោង" ខែតុលា ឆ្នាំ២០១៤។

# ជំពូក ២ ៖ ក្របខ័ណ្ឌច្បាប់

## ច្បាប់អន្តរជាតិ

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការពារសិទ្ធិទទួលបានកម្រិតជីវភាពសមរម្យ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) ដែលកម្ពុជាបានចុះសច្ចាប័នក្នុង ឆ្នាំ ១៩៩២ ការពារសិទ្ធិនេះ ដែលរួមមាន "ចំណីអាហារ សំលៀកបំពាក់ និងទីលំនៅសមរម្យ" (មាត្រា ១១)។

គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (CESCR) ផ្តល់ការបកស្រាយដែលអាចទទួលយកបាន ស្តីពីកាតព្វកិច្ចរបស់រដ្ឋពាក់ព័ន្ធនឹងសិទ្ធិទទួលបានទីលំនៅសមរម្យ។ CESCR បញ្ជាក់ថាសិទ្ធិនេះរាប់បញ្ចូលនូវសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ដោយសុវត្ថិភាព ដែលតម្រូវឲ្យមានការធានាស្របច្បាប់ប្រឆាំងនឹងការបណ្តេញចេញ។[12] CESCR បានសង្កត់ធ្ងន់លើវិធានការការពារ ដែលគួរតែត្រូវបានដាក់ចេញដើម្បីបញ្ចៀសការបណ្តេញចេញដោយបង្ខំ រួមមាន កិច្ចពិគ្រោះយោបល់ឲ្យបានគ្រប់គ្រាន់ក្នុងការស្វែងរកឧបាស្រ័យស្របច្បាប់ និងការផ្តល់សំណងគ្រប់គ្រាន់។

CESCR ក៏បានបញ្ជាក់នូវកាតព្វកិច្ចរបស់រដ្ឋពាក់ព័ន្ធនឹងសិទ្ធិទទួលបានសន្តិសុខស្បៀងផងដែរ។ សិទ្ធិទទួលបានសន្តិសុខស្បៀង រួមបញ្ចូលទាំងភាពសម្បូរនៃប្រភពចំណីអាហារសំដៅដល់ "ភាពដែលអាចទៅរួច...ក្នុងការចិញ្ចឹមខ្លួនឯងដោយប្រើប្រាស់ភោគផលដាំដុះនៅលើដីដែលមានដីជាតិ ឬក៏ធនធានធម្មជាតិផ្សេងទៀត"។[13] ទំនួលខុសត្រូវរបស់រដ្ឋក្នុងការការពារសិទ្ធិទទួលបានសន្តិសុខស្បៀង តម្រូវឲ្យរដ្ឋ "ចាត់វិធានការសមរម្យមួយចំនួនដើម្បីធានាថាសកម្មភាពរបស់ វិស័យឯកជន និងសង្គមស៊ីវិលអនុលោមទៅនឹងសិទ្ធិទទួលបានសន្តិសុខស្បៀង"។[14]

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក៏ការពារសិទ្ធិប្រជាពលរដ្ឋក្នុងការចូលរួមក្នុងសេចក្តីសម្រេចចិត្តដែលនឹងអាចប៉ះពាល់ដល់សិទ្ធិពួកគេផងដែរ។ ចំណុចនេះបានមកពី សិទ្ធិសេរីភាពបញ្ចេញមតិ ដែលត្រូវបានធានាក្នុងមាត្រា ១៩ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ដែលរួមមានសិទ្ធិ

---

[12] កថាខ័ណ្ឌ ៨ ក្នុង "សេចក្តីពន្យល់ទូទៅលេខ ៤ ៖ សិទ្ធិទទួលបានលំនៅឋានសមរម្យ" របស់ CESCR ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១។ អាចរកបាន ៖ http://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=INT%2fCESCR%2fGEC%2f4759&Lang=en.

[13] កថាខ័ណ្ឌ ១២ ក្នុង "សេចក្តីពន្យល់ទូទៅលេខ ១២ ៖ សិទ្ធិទទួលបានចំណីអាហារសមរម្យ" របស់ CESCR ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩។ អាចរកបាន ៖ http://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=E%2fC.12%2f1999%2f5&Lang=en.

[14] កថាខ័ណ្ឌ ២៧ ក្នុង "សេចក្តីពន្យល់ទូទៅលេខ ១២ ៖ សិទ្ធិទទួលបានចំណីអាហារសមរម្យ" របស់ CESCR ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩។

ទទួលព័ត៌មាន និងសិទ្ធិក្នុងការចូលរួមក្នុងបញ្ហាសាធារណៈ (ICCPR, មាត្រា ២៥)។

CESCR បញ្ជាក់ថាសហគមន៍ជនជាតិដើមភាគតិច មានសិទ្ធិក្នុងការចូលរួមក្នុងជីវភាពវប្បធម៌ (ICESCR, មាត្រា ១៥) ទាមទារឲ្យគោរពគោលការណ៍ការស្តីអំពីការជូនដំណឹងជាមុន និងព្រមព្រៀងដោយសេរី (FPIC) ក្នុងបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសិទ្ធិ។[15] សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពី សិទ្ធិជនជាតិដើមភាគតិច ក៏បានបញ្ជាក់ដែលថា FPIC គួរតែត្រូវបានអនុវត្តជាមុន សម្រាប់គម្រោងណាដែលទាមទារឲ្យមានការព្រមព្រៀងលើសំណងត្រឹមត្រូវ (មាត្រា ១០) ឬ "មុននឹងអនុម័តលើគំរោងណាមួយ ដែលប៉ះពាល់ដល់ដីធ្លី ឬដែនដី និងធនធាននានារបស់ពួកគេ" (មាត្រា ៣២(២)។

FPIC ត្រូវបានចាត់ទុកថាជាឧបករណ៍ដ៏សំខាន់ដើម្បីធានាថាសិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានគោរពក្នុងបរិបទនៃគម្រោងអភិវឌ្ឍន៍។ អង្គការ ActionAid លើកកម្ពស់ FPIC ថាជាលក្ខខ័ណ្ឌចម្បងក្នុងការអនុម័តគម្រោងអភិវឌ្ឍន៍ផ្សេងៗពាក់ព័ន្ធនឹងដីធ្លី និងធនធាន ក្នុងគោលបំណងធានាថាសហគមន៍ដែលរងផលប៉ះពាល់ អាចចូលរួមយ៉ាងពេញលេញនៅ ក្នុងសេចក្តីសម្រេចសំខាន់ៗ ដែលប៉ះពាល់ដល់ជីវិត និងជីវភាពរបស់ពួកគេ។

សេចក្តីណែនាំអន្តរជាតិផ្សេងទៀត ក៏បានស្នើនូវបទដ្ឋានសម្រាប់ "កិច្ចពិគ្រោះយោបល់ពេញលេញ" ក្នុងគម្រោង ដែលប៉ះពាល់ដល់សិទ្ធិរបស់សហគមន៍ដែលមិនមែនជាជនជាតិដើមភាគតិច។ គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចការប្រកបដោយការទទួលខុសត្រូវនៃការកាន់កាប់ដី ដលផល និងព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀងជាតិ (VGGT) ត្រូវបានគាំទ្រដោយ គណៈកម្មាធិការ អង្គការសហប្រជាជាតិស្តីពីសន្តិសុខស្បៀង ពិភពលោក ឆ្នាំ២០១២ បន្ទាប់ពីមានកិច្ចចរចាអន្តររដ្ឋាភិបាល។ VGGT បញ្ជាក់ថាកិច្ចពិគ្រោះយោបល់ និងការចូលរួម ជាគោលការណ៍ចាំបាច់ក្នុងការអនុវត្ត ដោយបានកំណត់និយមន័យថាជា "ការធ្វើការជាមួយ និងស្វែងរកការគាំទ្រសម្រាប់អ្នកដែល...អាចនឹងរងផលប៉ះពាល់ដោយសារតែសេចក្តីសម្រេចចិត្ត មុននឹងធ្វើការសម្រេច និងឆ្លើយតបទៅនឹងការរួមចំណែករបស់ពួកគេ ពិចារណាលើវិសមភាពអំណាចដែលមានស្រាប់ រវាងភាគីពាក់ព័ន្ធ និងធានាឲ្យមានការចូលរួមដោយប្រាប់ឲ្យដឹងជាមុនយ៉ាងពេញលេញ ប្រកបដោយប្រសិទ្ធភាព ដោយសេរី និងយ៉ាងសកម្ម សម្រាប់បុគ្គល ឬក្រុមដែលពាក់ព័ន្ធនឹងដំណើរការធ្វើការសម្រេចចិត្ត"។[16]

[15] កថាខ័ណ្ឌ ៣៧ ក្នុង "សេចក្តីពន្យល់ទូទៅលេខ ២១ ៖ សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការចូលរួមក្នុងជីវភាពវប្បធម៌" ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩។ អាចរកបាន ៖ http://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=E%2fC.12%2fGC%2f21&Lang=en.

[16] អង្គការកសិកម្ម និងចំណីអាហារ "គោលការណ៍ណែនាំស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចការទទួលខុសត្រូវនៃការកាន់កាប់ដីធ្លី ដលផល និងព្រៃឈើ ក្នុងបរិបទសុវត្ថិភាពចំណីអាហារ" ឆ្នាំ២០១២។ អាចរកបាន ៖

និយមន័យនេះឆ្លុះបញ្ចាំងពីធាតុផ្សំរបស់ FPIC ។

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស បញ្ជាក់បន្ថែមពីកាតព្វកិច្ចរដ្ឋក្នុងការគោរពសិទ្ធិមនុស្សស្តីពីសកម្មភាពរបស់វិស័យឯកជន និងបង្ហាញពីភាពជាប់ពាក់ព័ន្ធនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិសម្រាប់សហគ្រាសធុរកិច្ច។ គោលការណ៍ណែនាំ កត់សម្គាល់ថាបុគ្គលណាដែលអាចរងផលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ ដោយសារតែសកម្មភាពធុរកិច្ច គួរតែត្រូវបានពិគ្រោះយោបល់យ៉ាងពេញលេញ (គោលការណ៍ ១៨ ខ) រាល់ផលប៉ះពាល់មកលើសិទ្ធិគួរតែត្រូវបានតាមដានជាបន្តបន្ទាប់ ដោយមានការចូលរួមពីបុគ្គលដែលរងផលប៉ះពាល់ (គោលការណ៍ ២០ខ) ហើយធុរកិច្ចគួរតែរាយការណ៍អំពីរបៀបដែលខ្លួនដោះស្រាយការប៉ះពាល់ទាំងនោះទៅកាន់ភាគីពាក់ព័ន្ធ (គោលការណ៍ ២១)។[17]

## ច្បាប់ជាតិ

ICESCR និង ICCPR បានបញ្ចូលទៅក្នុងច្បាប់ជាតិកម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបញ្ជាក់ថាកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុង សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និង "កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ ទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

រដ្ឋធម្មនុញ្ញកម្ពុជាអនុញ្ញាតឲ្យរូបវន្តបុគ្គល និងនីតិបុគ្គលមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ហើយការរឹបអូសទ្រព្យសម្បត្តិរបស់ជនណា នឹងអាចធ្វើទៅបាន លុះត្រាតែអនុលោមទៅនឹងច្បាប់ដើម្បីប្រយោជន៍សាធារណៈ និងត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ (មាត្រា ៤៤)។ ច្បាប់ភូមិបាល ឆ្នាំ២០០១ បានលើកជាថ្មីម្តងទៀត ពាក់ព័ន្ធនឹងសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីឯកជន (មាត្រា ៨) និងបង្កើតដំណើរការសម្រាប់ប្រជាពលរដ្ឋដែលគ្មានប័ណ្ណកម្មសិទ្ធិ តែបានកាន់កាប់លើដីនោះជាបន្តបន្ទាប់ ដោយសន្តិវិធី និងជាសាធារណៈ អាចមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិ (មាត្រា ៣០)។

ច្បាប់ភូមិបាលក៏បានចែងថា អ្នកកាន់កាប់អចលនវត្ថុដោយខុសច្បាប់ អាចនឹងត្រូវបានអាជ្ញាធរមានសមត្ថកិច្ចបណ្តេញចេញ តាមការបង្គាប់របស់តុលាការ យោងតាមពាក្យបណ្តឹងរបស់បុគ្គលដែលបានប្តឹងទាមទារទ្រព្យ (មាត្រា ៣៥)។ ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ ២០១០ កំណត់នូវយន្តការដែលបុគ្គលអាចនឹងត្រូវបានបណ្តេញចេញដោយស្របច្បាប់ និងវិធានការណ៍ការពារការបណ្តេញចេញ រួមទាំង កិច្ចពិគ្រោះយោបល់ពី 'គ្រប់ភាគីពាក់ព័ន្ធ' (មាត្រា ១៦) និងការផ្តល់សំណង (មាត្រា ១៩ និង ២១)។

---

http://www.fao.org/docrep/016/i2801e/i2801e.pdf.

[17] OHCHR "គោលការណ៍ណែនាំ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស"។ អាចរកបាន ៖ http://www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf.

ច្បាប់ស្តីពីជលផល ឆ្នាំ២០០៦ បង្កើតសេចក្តីសន្និដ្ឋានមួយថា ការនេសាទដើម្បីចិញ្ចឹមជីវិតគឺត្រូវបានអនុញ្ញាត (មាត្រា ៣១)។ សិទ្ធិក្នុងការនេសាទអាចនឹងត្រូវបានរឹតត្បិត ប្រសិនបើនេសាទក្នុងតំបន់អភិរក្ស (មាត្រា ១៩) គំរាមកំហែងដល់ស្តុកធនធានជលផល ឬរំខានដល់ការលូតលាស់នៃស្មៅសមុទ្រ និងផ្កាថ្ម (មាត្រា ៤៨ និង ៥២) ឬរាំងស្ទះផ្លូវជលយាន (មាត្រា ៤៦)។ ពលរដ្ឋកម្ពុជាក៏មានសិទ្ធិបង្កើត 'សហគមន៍នេសាទ' ដើម្បី "ចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផល" (មាត្រា ៥៩)។ សហគមន៍នេសាទ ត្រូវបានគ្រប់គ្រងដោយ អនុក្រឹត្យលេខ ៨០ ស្តីពីការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ច្បាប់កម្ពុជាក៏បានការពារបរិស្ថាន ពីសកម្មភាពដែលអាចនឹងធ្វើឲ្យអន្តរាយដល់ការនេសាទផងដែរ។ រដ្ឋធម្មនុញ្ញចែងថារដ្ឋាភិបាលគួរតែ "ការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងអោយមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង ដីធ្លី ទឹក... ប្រព័ន្ធអេកូឡូស៊ី...មច្ឆជាតិ និង ធនធានជលផល" (មាត្រា ៥៩)។ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ តម្រូវឲ្យមាន 'ការវាយតម្លៃផលប៉ះពាល់បរិស្ថានដំបូង' អមជាមួយនឹងពាក្យស្នើសុំធ្វើគម្រោងវិនិយោគ (មាត្រា ៧)។ អនុក្រឹត្យ ស្តីពីដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន កំណត់ភារកិច្ចឲ្យក្រសួងបរិស្ថានក្នុងការរៀបចំដំណើរការវាយតម្លៃ តាមដាន និងអនុលោមទៅតាមរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន (មាត្រា ៣) ហើយ ដែលរួមបញ្ចូលនូវផលប៉ះពាល់នៃគម្រោងស្តីពី "ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី សុខភាព និងសុខុមាលភាពសាធារណៈ" (មាត្រា ៨)។ ក្រៅពីគោលបំណងផ្សេងទៀត អនុក្រឹត្យនេះបញ្ជាក់ពីគោលបំណងរបស់ខ្លួនថា "បំផុសឲ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថានព្រមទាំងទទួលយកមតិយោបល់ មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង" (មាត្រា ១)។

## ធនាគារអភិវឌ្ឍន៍អាស៊ី និងសិទ្ធិមនុស្ស

អង្គភាពអន្តរជាតិ ត្រូវចងភ្ជាប់នឹងគោលការណ៍ទូទៅរបស់ច្បាប់អន្តរជាតិ រួមទាំងកាតព្វកិច្ចក្នុងការគោរពបទដ្ឋានសិទ្ធិមនុស្ស។ CESCR បានបញ្ជាក់ថាភ្នាក់ងារអន្តរជាតិគួរតែខិតខំប្រឹងប្រែងឲ្យអស់លទ្ធភាព "ក្នុងដំណាក់កាលនីមួយៗនៃគម្រោងអភិវឌ្ឍន៍ ដើម្បីជានាថាសិទ្ធិដែលមានក្នុងកតិកាសញ្ញា នឹងត្រូវបានយកមកពិចារណាឲ្យដិតដល់"។[18]

ADB ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានរដ្ឋជាសមាជិក។ CESCR បញ្ជាក់ច្បាស់ថារដ្ឋភាគីដែលជាសមាជិក នៃស្ថាប័នអន្តរជាតិបែបនេះ ត្រូវមានកាតព្វកិច្ចធានាថាស្ថាប័នទាំងនេះអនុលោមទៅនឹងបទដ្ឋានសិទ្ធិ

[18] កថាខ័ណ្ឌ ១៧ ក្នុង "សេចក្តីពន្យល់ទូទៅលេខ ៧ ៖ សិទ្ធិទទួលបានលំនៅឋានសមរម្យ ៖ ការបណ្តេញចេញ" របស់ CESCR ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧។

មនុស្ស។[19]

ADB បានបោះពុម្ពផ្សាយ សេចក្តីថ្លែងគោលនយោបាយស្តីពីការការពារសុវត្ថិភាព ដើម្បីជានាថាកិច្ចប្រតិបត្តិការរបស់ ADB "លើកកម្ពស់ចីរភាពនៃលទ្ធផលគម្រោង តាមរយៈការការពារបរិស្ថាន និងប្រជាពលរដ្ឋ ពីផលប៉ះពាល់ធ្ងន់ធ្ងរនៃគម្រោងដែលនឹងអាចកើតមាន"។[20] គោលនយោបាយ នេះរួមបញ្ចូល វិធានការណ៍ការពារ ដើម្បីទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស និងប្រានចោលការឧបត្ថម្ភថវិកាជាចំហ ចំពោះគម្រោងណាដែលមិនអនុលោមតាមលក្ខខ័ណ្ឌគោលនយោបាយ និង "ច្បាប់ជាតិដែលអនុវត្តកាតព្វកិច្ចប្រទេសម្ចាស់ផ្ទះតាមច្បាប់អន្តរជាតិ"។ តាមវិធីនេះ ADB ទទួលស្គាល់នូវតម្រូវការក្នុងការអនុលោមជាមួយក្របខ័ណ្ឌសិទ្ធិមនុស្សកម្ពុជា។ តាមរយៈគោលនយោបាយយន្តការគណនេយ្យភាព ADB បានបង្កើតប្រព័ន្ធមួយដែលប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោងដែលឧបត្ថម្ភថវិកាដោយ ADB អាចដាក់ពាក្យប្តឹងស្តីពីការអនុលោមរបស់ ADB នឹងគោលនយោបាយរបស់ខ្លួន។[21]

[19] កថាខ័ណ្ឌ ៥៦ ក្នុង "សេចក្តីពន្យល់ទូទៅលេខ ១៧ ៖ សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបានការការពារប្រយោជន៍ផ្នែកសម្ភារៈ និងសីលធម៌ បានមកពីផលិតផលបែបសិល្បៈ អក្សរសាស្ត្រ ឬវិទ្យាសាស្ត្រដែលគាត់ជាអ្នកនិពន្ធ" របស់ CESCR ថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ និងកថាខ័ណ្ឌ ៥៦ ក្នុង "សេចក្តីពន្យល់ទូទៅលេខ ១៣ ៖ សិទ្ធិទទួលបានការអប់រំ" របស់ CESCR ។ អាចរកបាន ៖ http://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=E%2fC.12%2fGC%2f17&Lang=en និង http://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=E%2fC.12%2f1999%2f10&Lang=en.

[20] "សៀវភៅមគ្គុទេសក៍ផ្នែកប្រតិបត្តិ។ គោលនយោបាយធនាគារ។ សេចក្តីថ្លែងការណ៍គោលនយោបាយការពារ" របស់ ADB ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៣ (OM Section F1/BP)។ អាចរកបាន ៖ http://www.adb.org/sites/default/files/institutional-document/31483/om-f1-20131001.pdf

[21] "សៀវភៅមគ្គុទេសក៍ផ្នែកប្រតិបត្តិ។ គោលនយោបាយធនាគារ។ យន្តការទំនួលខុសត្រូវ" របស់ ADB ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ (OM Section L1/BP)។

## ជំពូក ៣ ៖ ដីធ្លី





រូបទី ២ ៖ រូបខាងមុខ និងខាងក្រោយនៃបង្កាន់ដៃ ទទួលស្គាល់ការចុះបញ្ជី ដែលចេញដោយមន្ទីររៀបចំដែនដី សម្រាប់ប្រជាពលរដ្ឋរស់នៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ។ ឈ្មោះបុគ្គលត្រូវបានលុបចេញ។

## សិទ្ធិដីធ្លីនៅកម្ពុជា

ក្នុងអំឡុងពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាបានជួបប្រទះនូវភាពចម្រូងចម្រាស់ឥតឈប់ឈរ ទាក់ទងនឹងការទន្ទ្រានយកដីដើម្បីគម្រោងអភិវឌ្ឍន៍ផ្សេងៗ។ ចាប់តាំងពីការលុបចោលកម្មសិទ្ធិឯកជន និងការជម្លៀសប្រជាពលរដ្ឋក្នុងទ្រង់ទ្រាយធំ ក្នុងអំឡុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) ប្រជាពលរដ្ឋជាច្រើនជួបផលលំបាកក្នុងការទទួលបានសិទ្ធិកាន់កាប់ដីធ្លីដោយសុវត្ថិភាព។ រដ្ឋាភិបាលបានអនុញ្ញាតឲ្យមានសិទ្ធិជាម្ចាស់កម្មសិទ្ធិឯកជនជាថ្មីម្តងទៀត ក្នុងឆ្នាំ ១៩៨៩ ប៉ុន្តែ មានប្រជាពលរដ្ឋភាគតិចណាស់ដែលមានលទ្ធភាពទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់។ អង្គការសិទ្ធិមនុស្សបានចងក្រងឯកសារពីលំនាំនៃការបណ្តេញចេញ បន្ទាប់ពីមានការចាត់ឲ្យមានសម្បទានដីសេដ្ឋកិច្ច ក្នុងតំបន់ជនបទ និងគម្រោងអភិវឌ្ឍន៍កែលម្អក្រុងក្នុងទីប្រជុំជន។[22] ជាការឆ្លើយតប រដ្ឋាភិបាលបានបង្កើតវិធានការ ដើម្បីបង្កើនសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លី។ ដំណើរការចុះបញ្ជីដីធ្លីជាបន្តបន្ទាប់ បានផ្តល់ប័ណ្ណកម្មសិទ្ធិច្រើនជាង ៤ លានប័ណ្ណ គិតត្រឹមខែមករា ឆ្នាំ២០១៦ យោងតាមការបញ្ជាក់របស់រដ្ឋាភិបាល។[23] អង្គការសិទ្ធិមនុស្ស និងអង្គការសហប្រជាជាតិ បានរិះគន់ដំណើរការទាំងនេះដែលមិនបញ្ចូលដីដែលកំពុងមានជម្លោះក្នុងដំណើរការនេះ ហើយជនរងគ្រោះភាគច្រើនគឺក្រុមសំឡេងភាគតិចជាពិសេស សហគមន៍ជនជាតិដើមភាគតិច ដែលមានជម្លោះជាមួយផលប្រយោជន៍ពាណិជ្ជកម្ម និងនយោបាយ។[24]

នៅទូទាំងពិភពលោក ស្ត្រីភាគច្រើនតែងតែរងផលប៉ះពាល់ជាអវិជ្ជមានដោយសារតែកំណើនជម្លោះដីធ្លី។[25] ការស្រាវជ្រាវក្នុងស្រុកមួយដែលធ្វើឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានរកឃើញថា

---

[22] សូមអានដើម្បីជាឧទាហរណ៍ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) "កម្ពុជា៖ជម្លោះដីធ្លី៖ ទិដ្ឋភាពនៃស្ថានភាពដីធ្លី" ខែធ្នូ ឆ្នាំ២០១៣ និង OHCHR "ការបណ្តេញចេញ និងការដោះស្រាយសំណងនៅកម្ពុជា ៖ តម្លៃមនុស្ស ផលប៉ះពាល់ និងដំណោះស្រាយ" ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២។ អាចរកបាន ៖ http://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=104&id=3 និង http://cambodia.ohchr.org/sites/default/files/Thematic-reports/Resettlement_Study-28_Feb_2012_Eng.pdf.

[23] អគ្គលេខាធិការ អ.ប.ស "តួនាទី និងការសម្រេចបាន របស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស" ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦។ អាចរកបាន http://cambodia.ohchr.org/sites/default/files/Ohchr-report/A_HRC_33_39_en.pdf.

[24] កថាខ័ណ្ឌ ៥៥ - ៥៩ អគ្គលេខាធិការ អ.ស.ប "តួនាទី និងភាពជោគជ័យ របស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស" ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦។ សូមអានបន្ថែម អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា ៖ យុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិអាចនឹងត្រូវបានបំពាន" ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ និង អាដហុក "ពេលវេលាដែលត្រូវផ្លាស់ប្តូរ? សិទ្ធិដីធ្លី ផ្ទះសម្បែង និងធនធានធម្មជាតិ នៅកម្ពុជា ឆ្នាំ២០១២" ខែកុម្ភៈ ឆ្នាំ២០១៣។ អាចរកបាន ៖ https://www.hrw.org/news/2013/06/12/cambodia-land-titling-campaign-open-abuse and http://www.adhoc-cambodia.org/report-a-turning-point-land-housing-and-natural-resources-rights-in-cambodia-in-2012/.

[25] សម្ព័ន្ធភាពដីធ្លីអន្តរជាតិ "យុទ្ធសាស្ត្រដើម្បីបញ្ច្រាបយេនឌ័រក្នុងរបៀបវារៈនៃកិច្ចពិភាក្សា "ទន្ទ្រានយកដី"" ខែមីនា ឆ្នាំ២០១១។ អាចរកបាន ៖ http://www.landcoalition.org/sites/default/files/documents/resources/6_PBs_mokoro.pdf.

ស្ត្រីរងផលប៉ះពាល់ជាពិសេស តាមរយៈ "កំណើននៃអំពើហិង្សាក្នុងគ្រួសារ ការវាយប្រហារក្នុងជម្លោះដីធ្លីកាន់តែធ្ងន់ធ្ងរឡើង ការធ្លាក់ខ្សោយនៃសុខភាពផ្លូវចិត្តដោយសារតែជម្លោះដីធ្លី" ខណៈដែលកុមារក៏រងផលប៉ះពាល់តាមរយៈ "កំណើននៃ...ការមើលឃើញអំពើហិង្សាក្នុងគ្រួសារ ការថយចុះនៃ...លទ្ធភាពចូលរៀន និងកំណើននៃការប្រើប្រាស់កម្លាំងពលកម្មកុមារ"។[26]

## ការចុះបញ្ជីដីធ្លី ក្នុងខេត្តកំពត

ក្នុងឃុំទាំងបី ដែលត្រូវបានសិក្សាសម្រាប់របាយការណ៍នេះ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ("មន្ទីររៀបចំដែនដី") បានបង្កើតដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ មន្ត្រីមកពីមន្ទីរ បានចុះមកសួរសុខទុក្ខប្រជាពលរដ្ឋក្នុងឃុំ ដើម្បីចងក្រងចំនួនប្រជាពលរដ្ឋដែលសំអាងថាមានកម្មសិទ្ធិលើដី។ ពួកគេសួរប្រជាពលរដ្ឋថាប្រជាពលរដ្ឋទាំងនោះកាន់កាប់ដីតាមរបៀបណា ស្នើសុំសំណៅឯកសារដើម្បីបញ្ជាក់ពីការរស់នៅលើដីនោះជាបន្តបន្ទាប់ និងដៅទីតាំងដីនោះ។ មន្ទីរបានចេញបង្កាន់ដៃដើម្បីបញ្ជាក់ថាដីនោះបានចុះបញ្ជីរួចរាល់ និងព័ត៌មានលម្អិតទាក់ទិននឹងព្រំដី (មើលរូបទី ២)។

ប្រសិនបើដីនោះ មានជម្លោះរឿងព្រំដី ដីនោះនឹងមិនត្រូវបានចុះបញ្ជីនោះទេ។ ម្ចាស់ដីគួរតែព្រមព្រៀងគ្នាលើព្រំដី មុននឹងមន្ទីរអាចចុះបញ្ជីដីឲ្យបាន។ ម្ចាស់ដីអាចស្វែងរកការផ្សះផ្សា ពីសំណាក់ប្រធានភូមិ ឬប្រធានក្រុមប្រឹក្សាឃុំ ប៉ុន្តែ មន្ទីរនឹងមិនជ្រៀតជ្រែកនោះទេ។



រូបទី ២ ៖ រូបខាងមុខ និងខាងក្រោយនៃបង្កាន់ដៃ ទទួលស្គាល់ការចុះបញ្ជី ដែលចេញដោយមន្ទីររៀបចំដែនដី សម្រាប់ប្រជាពលរដ្ឋរស់នៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ។ ឈ្មោះបុគ្គលត្រូវបានលុបចេញ។

មន្ទីរនឹងបិទប្រកាសព័ត៌មានអំពីដីដែលបានចុះបញ្ជីបន្ទាប់ពីដំណើរការចុះបញ្ជីចប់សព្វគ្រប់។ ម្ចាស់ដីនឹងមានពេលវេលា ១៥ ថ្ងៃដើម្បីដាក់ពាក្យបណ្តឹង ប្រសិនបើពួកគេគិតថាមានព័ត៌មានខុសមិនត្រឹមត្រូវ។ បន្ទាប់មក មន្ទីរនឹងចេញប័ណ្ណកម្មសិទ្ធិដល់ម្ចាស់ដី។

ក្នុងឃុំជុំគ្រៀល មន្ទីរកំពុងតែបន្តចេញប័ណ្ណកម្មសិទ្ធិសម្រាប់ប្រជាពលរដ្ឋ បន្ទាប់ពីដំណើរការចុះបញ្ជីរួចរាល់។ ភូមិទាំង៣ ក្នុងឃុំត្រពាំងសង្កែ ត្រូវបានចុះបញ្ជីក្នុងអំឡុង ឆ្នាំ២០១៤ និង ២០១៥។ ភូមិ

[26] ទំព័រ ១៩ ក្នុងរបាយការណ៍ "ស្ត្រីកម្ពុជាក្នុងជម្លោះដីធ្លី" របស់ ម.ស.ម.ក ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦។ អាចរកបាន ៖ http://cchrcambodia.org/index_old.php?title=Cambodia-s-Women-in-Land-Conflict&url=media/media.php&p=report_detail.php&reid=116&id=5&lang=eng.

ចំនួន២ ក្នុងចំណោមភូមិចំនួន៤ ក្នុងឃុំកូនសត្វ គឺភូមិកំពង់ត្នោត និងកំពង់នង់ ត្រូវបានចុះបញ្ជីកាលពីខែកុម្ភៈ ឆ្នាំ២០១៦។ យោងតាមមន្ទីររៀបចំដែនដី ភូមិចំនួន២ ដែលនៅសល់នឹងត្រូវចុះបញ្ជីចាប់ពីខែមេសា ឆ្នាំ២០១៧។[27] ប្រជាពលរដ្ឋ និងមន្ទីររៀបចំដែនដីបានប្រាប់ក្រុមការងារថា មានជម្លោះដីធ្លីខ្លះពាក់ព័ន្ធនឹងរឿងព្រំដី ក្នុងឃុំចំនួន ៣ ហើយដែលម្ចាស់ដីកំពុងតែចរចាគ្នា។


រូបទី ៣ ៖ លោក ជា សុវ៉ាត អ្នកនេសាទមកពីភូមិត្រពាំងសង្កែ។

ការផ្តល់ព័ត៌មាន ពីដំណើរការចុះបញ្ជីដីធ្លីរបស់ប្រជាពលរដ្ឋត្រូវគ្នានឹង ការរៀបរាប់របស់មន្ទីររៀបចំដែនដី។ ចំពោះអ្នកដែលបានចុះបញ្ជីដីរួចរាល់ ប៉ុន្តែមិនទាន់បានប័ណ្ណកម្មសិទ្ធិ បានយល់យ៉ាងច្បាស់ពីជំហានបន្ទាប់ ថានឹងត្រូវធ្វើបែបណា។ ឧទាហរណ៍ លោក ជា សុវ៉ាត អ្នកនេសាទ អាយុ ៣៨ ឆ្នាំ រស់នៅក្នុង ភូមិត្រពាំងសង្កែ ជាមួយប្រពន្ធ និងកូន៣ នាក់ បានពន្យល់ពីដំណើរការចុះបញ្ជីដល់ក្រុមការងារស្រាវជ្រាវ ៖

> *"ដីរបស់ខ្ញុំបានចុះបញ្ជីរួចរាល់ហើយ ប៉ុន្តែខ្ញុំមិនទាន់ទទួលបានប័ណ្ណនៅឡើយ។ ខ្ញុំមានបង្កាន់ដៃពី [មន្ទីររៀបចំដែនដី] ពេលដែលពួកគេចុះមកដល់ភូមិកាលពីមួយឆ្នាំមុន។ ខ្ញុំត្រូវតែបង្ហាញអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងសំបុត្រកំណើត។ មុនពួកគេផ្តល់ប័ណ្ណកម្មសិទ្ធិ ពួកគេនឹងបិទប្រកាសពីផែនទីនៅសាលាឃុំ។ ពួកគេនឹងបិទប្រកាសពីផែនទីជាមួយនឹងឈ្មោះម្ចាស់ដី អញ្ចឹងអ្នកអាចពិនិត្យមើលទីតាំងដីធៀបនឹងបង្កាន់ដៃបាន។ ប្រសិនបើមានព័ត៌មានមិនត្រឹមត្រូវ ប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹង ហើយពួកគេនឹងផ្តល់ពេលវេលាសម្រាប់កែតម្រូវ មុនពេលដែលពួកគេចេញប័ណ្ណកម្មសិទ្ធិចុងក្រោយ។ ប្រសិនបើមានជម្លោះ យើងនឹងដោះស្រាយ និងចរចា។ ប្រសិនបើយើងមិនយល់ព្រម [មន្ទីរ] នឹងមិនចុះបញ្ជីដីនោះទេ។ ពួកគេនឹងត្រលប់មកវិញពេលដែលជម្លោះបានបញ្ចប់។"[28]*

ប្រជាពលរដ្ឋភាគច្រើនដែលបានចូលរួមសម្ភាសន៍ក្នុងការស្រាវជ្រាវនេះ បានរៀបការរួចហើយ។ ក្នុងអំឡុងដំណើរការចុះបញ្ជី ពួកគេសម្រេចចុះបញ្ជីដីដោយប្រើទាំងឈ្មោះស្វាមី និងភរិយា។ ប្រសិនបើដីនោះជាមរតកមកពីឪពុកម្តាយខាងប្រពន្ធ ឬប្តី ពេលខ្លះដីនោះនឹងចុះបញ្ជីដោយប្រើតែឈ្មោះប្រពន្ធ ឬប្តី។

[27] កិច្ចប្រជុំជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខែកញ្ញា ឆ្នាំ២០១៦។
[28] សម្ភាសន៍ជាមួយ ជា សុវ៉ាត ឃុំត្រពាំងសង្កែ ខែកញ្ញា ឆ្នាំ២០១៦។

ប្រជាពលរដ្ឋស្ទើរតែទាំងអស់ដែលបានចូលរួមសម្ភាសន៍ក្នុងការស្រាវជ្រាវ ជឿជាក់ថាសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេមានសុវត្ថិភាព។ ក៏ប៉ុន្តែ ប្រជាពលរដ្ឋមួយចំនួនក្នុងឃុំនេះ រស់នៅលើដីរដ្ឋ។ ក្រុមការងារស្រាវជ្រាវ សម្ភាសន៍ស្ត្រីម្នាក់មកពី ភូមិកំពង់ត្នោត ដែលរស់នៅជាមួយកូនទាំង ៦នាក់របស់គាត់។ គាត់បាននិយាយថាមន្ត្រីមន្ទីរបានប្រាប់គាត់ថា គាត់បានរស់នៅលើដីរដ្ឋ ក្នុងអំឡុងដំណើរការចុះវាស់វែងដីធ្លី តាំងពី ៣ ទសវត្សរ៍មុនមកម្លេះ។ ដីនេះពុំត្រូវបានចាត់ជាផ្នែកមួយនៃដំណើរការចុះបញ្ជីដីធ្លីក្នុងពេលបច្ចុប្បន្ននេះទេ។ មន្ទីររៀបចំដែនដី បានអះអាងថាប្រជាពលរដ្ឋរស់នៅលើដីរដ្ឋ ពុំមានសិទ្ធិរស់នៅទីនោះទេ រួចនិយាយថារដ្ឋាភិបាលនឹងធ្វើការជាមួយពួកគេដើម្បីស្វែងរកដីកន្លែងផ្សេងទៀត។ ក្នុងឃុំទាំងនេះ ពុំមានសម្បទានដីសេដ្ឋកិច្ចនោះទេ ដូច្នេះក៏ពុំមានការគំរាមកំហែងបណ្តេញចេញពីប្រភពនេះនោះដែរ។

## ការទិញដីសម្រាប់គម្រោងកំពង់ផែទេសចរណ៍កំពត

គម្រោងកំពង់ផែទេសចរណ៍កំពត រំពឹងថានឹងត្រូវបានសាងសង់នៅលើដីចំនួន បួនហិកតា ជាដីឯកជន ក្នុងឃុំជុំគ្រៀល។ ឃុំនេះ ខាងត្បូងមានព្រំជាប់នឹងឆ្នេរសមុទ្រ ខាងលិចជាប់ស្ទឹងទឹកឈូ និងខាងកើតជាប់នឹងស្ទឹងមួយទៀត។ ដីមួយភាគធំ ដែលនៅចន្លោះផ្លូវជាតិលេខ ៣៣ និងឆ្នេរសមុទ្រ គឺជាដីស្រែអំបិល។ ទោះបីជាដីដែលនៅជាយប្រាំង ទាំងនេះ ជាដីរដ្ឋក៏ដោយ តែដីប៉ែកខាងក្នុងជាកម្មសិទ្ធិរបស់បុគ្គលឯកជន




រូបភាពទី ៤ ៖ ផ្លូវចូលទៅកាន់ទីតាំងគម្រោង ក្នុងឃុំជុំគ្រៀល បង្ហាញពីរូបភាពនៃដីដែលបានទិញសម្រាប់គម្រោង។

ដែលមានទ្រព្យសម្បត្តិច្រើន។ មន្ទីររៀបចំដែនដី បានបញ្ជាក់ថាអាជ្ញាធរខេត្តកំពត បានទិញដីបួនហិកតានេះមកពីបុគ្គលឯកជន កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥។ ដូច្នេះ គម្រោងនេះមើលទៅហាក់មិនប៉ះពាល់ដោយផ្ទាល់ទៅលើសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋនោះទេ។

ការសិក្សាបរិស្ថានបឋម កត់សម្គាល់ថា "ការអភិវឌ្ឍន៍ទីក្រុង និងការអភិវឌ្ឍន៍ពាណិជ្ជកម្ម ដែលបង្កើតឡើងដើម្បីបម្រើ និងទាញយកផលប្រយោជន៍ពីវិស័យទេសចរណ៍ដែលបង្កើតដោយគម្រោងនេះ"

អាចនឹងមានផលប៉ះពាល់លើសពីវិសាលភាពនៃគម្រោងកំពង់ផែទេសចរណ៍កំពត។[29] ជំពូក ៦ ពិនិត្យមើលលើគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត ដែលគ្រោងសាងសង់លើឆកសមុទ្រកំពត ដែលអាចនឹងបង្កើនតម្លៃដីនៅក្នុងឃុំនេះ។ គម្រោងទាំងនេះ អាចទាក់ទាញភ្នាក់ងារដែលមានអំណាចសេដ្ឋកិច្ច និងនយោបាយ ដើម្បីវិនិយោគ និងទិញយកដីក្នុងតំបន់នេះ។ ដោយសារតែ បទពិសោធន៍ជម្លោះដីធ្លីថ្មីៗជាច្រើននៅកម្ពុជា ដូចបានកត់សម្គាល់កាលពីដើមដំបូងនៃជំពូកនេះ ការបញ្ចប់ដំណើរការចុះបញ្ជីដីធ្លីនឹងផ្តល់ការការពារដល់ប្រជាពលរដ្ឋ ពីការគំរាមកំហែងនានាដែលនឹងអាចកើតឡើងចំពោះដីធ្លីរបស់ពួកគេ។

**អនុសាសន៍ ៖**

**មន្ទីររៀបចំដែនដី ៖**

- ចាប់ផ្តើមដំណើរការចុះបញ្ជីដីធ្លី ក្នុងភូមិដែលនៅសេសសល់ នៅឃុំកូនសត្វ និងធានាថាប្រជាពលរដ្ឋទាំងអស់ ក្នុងឃុំជុំគ្រៀល ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដើម្បីផ្តល់សុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លី។
- ចំពោះប្រជាពលរដ្ឋដែលរស់នៅលើដីរដ្ឋ ជម្រើសផ្សេងទៀតក្រៅពីការបណ្តេញចេញគួរតែត្រូវបានពិចារណា ដោយមានកិច្ចពិគ្រោះយោបល់ពីបុគ្គលទាំងអស់នោះ ហើយពួកគេគួរតែទទួលបានកិច្ចការពារជាអតិបរមា ដូចមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

[29] ទំព័រ ៣០ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

# ជំពូក ៤៖ ជីវភាព



រូបភាពទី ៥ ៖ ស្ត្រីម្នាក់ កំពុងរាវគ្រែងក្នុងគម្របស្មៅសមុទ្រនៅឆកសមុទ្រកំពត។

*“ពួកគេចាក់ដីបំពេញលើព្រៃកោងកាងដែលពួកយើងធ្លាប់នេសាទ... កាលពីមុនមានមនុស្សរាប់រយនាក់នេសាទនៅទីនោះ ប៉ុន្តែឥឡូវគ្មាននរណាទៅទេ។ គេទៅនេសាទនៅក្នុងដែនសហគមន៍នេសាទវិញម្តង។ ពីមុនមានកន្លែងនេសាទធំទូលាយ តែឥឡូវកន្លែងនេសាទរួមតូច ហើយចំនួនទូកនៅដដែល... មិនថា [គម្រោងកំពង់ផែទេសចរណ៍កំពតធ្វើអ្វីខ្លះទេ] ពួកយើងចង់ទៅកែម្តុំភ្នំដូង។ ប្រសិនបើគេបិទផ្លូវនេះ នោះនឹងប៉ះពាល់ដល់ឃុំមួយចំនួន”។*

អ្នកនេសាទ អាយុ ៥៣ ឆ្នាំ នៅភូមិត្រពាំងសង្កែ។

## ប្រព័ន្ធអេកូឡូស៊ី ឆកសមុទ្រកំពត

តំបន់ឆកសមុទ្រកំពត ក្នុងរបាយការណ៍នេះ គឺសំដៅដល់ឆ្នេរសមុទ្រដែលលាតសន្ធឹងរវាងភ្នំដូង និងឃុំត្រើយកោះ ក្នុងស្រុកកំពត និងព្រំប្រទល់ជាប់ខេត្តកែប។ តំបន់នេះរួមបញ្ចូលទាំងមាត់ស្ទឹងទឹកឈូ ដែលហូរពីទីក្រុងកំពតមកក្នុងឆកសមុទ្រ។ ចាប់ពីទិសខាងលិចទៅខាងកើត ឆ្នេរសមុទ្រនេះលាតសន្ធឹងក្នុងឃុំជាច្រើន ដូចជា ឃុំត្រើយកោះ ស្រុកកំពត ឃុំជុំគ្រៀល ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ ក្នុងស្រុកទឹកឈូ។

ក្រុមការងារស្រាវជ្រាវ ពុំអាចរកទិន្នន័យបានគ្រប់ជ្រុងជ្រោយ បង្ហាញពីចំនួនប្រជាពលរដ្ឋទាំងអស់ដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីក្នុងឆកសមុទ្រកំពត ដើម្បីជីវភាពរបស់ពួកគេនោះទេ។ ការស្ទង់មតិរបស់សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ក្នុងភូមិទាំង៤ តាមបណ្តោយឆ្នេរ ក្នុងខេត្តកំពត ដែលមានប្រជាពលរដ្ឋសរុប ៧,៣៩១ នាក់ រកឃើញថាអ្នកចូលរួមក្នុងការស្ទង់មតិទាំងអស់ពឹងផ្អែកលើរបរនេសាទ ដើម្បីផ្គត់ផ្គង់លើជីវភាពពួកគេ។[30] ក្នុងខេត្តកំពតមានសហគមន៍នេសាទសរុប ១០ សហគមន៍ មានសមាជិកសរុប ៣,០៥៤ នាក់។[31] ជាធម្មតា ក្នុងសហគមន៍នេសាទនីមួយៗ មានប្រជាពលរដ្ឋតែមួយភាគប៉ុណ្ណោះ ដែលពឹងផ្អែកលើរបរនេសាទដើម្បីជីវភាព។ ឧទាហរណ៍ សហគមន៍នេសាទត្រពាំងសង្កែ មានសមាជិក ៧៣៤ នាក់ ប៉ុន្តែប្រជាពលរដ្ឋសរុបក្នុងឃុំត្រពាំងសង្កែគឺ ៥,៨៥៩ នាក់។ ប្រជាពលរដ្ឋរាប់ពាន់ ឬអាចរាប់ម៉ឺននាក់ ពឹងផ្អែកលើធនធានក្នុងឆកសមុទ្រកំពត ដើម្បីផ្គត់ផ្គង់ជីវភាពរបស់ពួកគេ។

---

[30] ទំព័រ ២៨ Kaarlep, A., “ការស្ទង់មតិផ្នែកសង្គមសេដ្ឋកិច្ច ស្តីពីសារៈសំខាន់នៃគម្របស្មៅសមុទ្រ មកលើសហគមន៍រស់នៅតាមបណ្តោយឆ្នេរ ក្នុងខេត្តកំពត” ឆ្នាំ២០១៤។ អាចរកបាន ៖ http://cmsdata.iucn.org/downloads/jan_2015_bcr_kampot_seagrass_report__final_draft_26_3_15__final.pdf

[31] ទំព័រ ២០ Supkong, P. និង Bourne, L., “ការស្ទង់មតិលើ តមេរេតៅតមេទក្នុងខេត្តកំពត កម្ពុជា” ឆ្នាំ ២០១៤។ អាចរកបាន ៖ http://cmsdata.iucn.org/downloads/bcrsurve ៣១ in_kampot__final_25_3_15___final.pdf.



រូបភាពទី ៥ ៖ ស្ត្រីម្នាក់ កំពុងរាវគ្រែងក្នុងគម្របស្មៅសមុទ្រ នៅឆកសមុទ្រកំពត។

ប្រព័ន្ធអេកូឡូស៊ី ក្នុងឆកសមុទ្រកំពតទ្រទ្រង់ដោយគម្របស្មៅសមុទ្រ និងព្រៃកោងកាង។ គម្របស្មៅសមុទ្រ ជាជម្រក និងកន្លែងបង្កាត់ពូជរបស់ពពួកត្រី សត្វក្តាម បង្គា និងឧរង្គសត្វ ជាច្រើនប្រភេទទៀត ស្មៅទាំងនេះជាប្រភពចំណីអាហារ របស់សត្វ អណ្តើក ភេសមុទ្រ និងពូជត្រីដែលស៊ីរុក្ខជាតិជាអាហារ ឯត្រីផ្សេងៗទៀត រស់នៅក្នុងគម្របស្មៅសមុទ្រស៊ីស្លែ និងពួកឧរង្គសត្វដែលរស់នៅ និងធំធាត់លើស្លឹកស្មៅសមុទ្រ។ គម្របស្មៅសមុទ្រនៅក្នុងខេត្តកំពត ជាជម្រករបស់សត្វមួយចំនួនដែលជិតដាច់ពូជ ដូចជា ភេសមុទ្រ សេះសមុទ្រ និងអណ្តើកបៃតង។ IUCN រកឃើញថាពូជសត្វចំនួន ៨៩ % ដែលត្រូវបានអ្នកនេសាទចាប់បានក្នុងខេត្តកំពត គឺពឹងផ្អែកលើស្មៅសមុទ្រដើម្បីចិញ្ចឹមជីវិត។[32] គម្របស្មៅសមុទ្រ ក៏ជួយការពារភាពសឹករិចរិលតាមឆ្នេរសមុទ្រ ការពារឆ្នេរពីព្យុះភ្លៀង និងជួយផ្ទុកជាតិកាបូនឌីអុកស៊ីត ដើម្បីការពារបម្រែបម្រួលអាកាសធាតុផងដែរ។[33]

ឆកសមុទ្រកំពត មានគម្របស្មៅសមុទ្រលាតសន្ធឹងធំបំផុតក្នុងសមុទ្រចិនខាងត្បូង។ យោងតាមរបាយការណ៍របស់ កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (UNEP) ឆ្នាំ២០១៤ ក្នុងឆកសមុទ្រកំពត មានគម្របស្មៅសមុទ្រប្រមាណ ២៥,២៤០ ហិកតា។ ចំណែកឯការសិក្សាថ្មីៗបំផុតរបស់ IUCN ក្នុងឆ្នាំ២០១៣ វាស់វែងទំហំលាតសន្ធឹងគម្របស្មៅសមុទ្របាន ៨,៤៣៥ ហិកតាក្នុងឆកសមុទ្រកំពត។[34] តម្លៃសេដ្ឋកិច្ចរបស់គម្របស្មៅនេះ ពិបាកវាយតម្លៃជាចំនួនណាស់។ ក្នុង ឆ្នាំ២០០៧ UNEP ប៉ាន់ស្មានតម្លៃផ្នែកសេដ្ឋកិច្ចប្រចាំឆ្នាំរបស់គម្របស្មៅសមុទ្រ ថាមានប្រមាណ ១,១៨៦ ដុល្លារអាមេរិក ក្នុងមួយហិកតា។ ប៉ុន្តែ ICUN ប្រកែកថា ការប៉ាន់ស្មានតម្លៃនេះគ្របដណ្តប់តែចំនួនត្រី និងធនធានផ្សេងៗប៉ុណ្ណោះ ដោយពុំបានរាប់បញ្ចូល "តម្លៃក្នុងការការពារឆ្នេរខ្សាច់ តួនាទីជាជម្រកសត្វសមុទ្រ ការស្រូបយកកាបូន ការបញ្ចេញអុកស៊ីហ្សែន និងការកំចាត់សារធាតុចិញ្ចឹម" នេះជាការប៉ាន់ប្រមាណដែលនៅស្ទើរនៃតម្លៃគម្របស្មៅសមុទ្រ។[35] ប្រសិនបើយកតម្លៃប៉ាន់ស្មាន របស់ UNEP និងការប៉ាន់ស្មាននៃទំហំលាតសន្ធឹងគម្របស្មៅសមុទ្រនាពេលថ្មីៗនេះ តម្លៃសេដ្ឋកិច្ចរបស់គម្របស្មៅសមុទ្រនៅកំពត គឺយ៉ាងហោចណាស់ ១០ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ ថ្វីបើគម្របស្មៅសមុទ្រ

[32] ទំព័រ ៣៣ និង ៤២, Kaarlep, A., "ការស្ទង់មតិផ្នែកសង្គមសេដ្ឋកិច្ច ស្តីពីសារៈសំខាន់នៃគម្របស្មៅសមុទ្រ មកលើសហគមន៍រស់នៅតាមបណ្តោយឆ្នេរ ក្នុងខេត្តកំពត" ឆ្នាំ២០១៤។

[33] ទំព័រ ៩, Supkong, P. និង Bourne, L., "ការស្ទង់មតិលើ គម្របស្មៅសមុទ្រក្នុងខេត្តកំពត កម្ពុជា" ឆ្នាំ ២០១៤។

[34] ទំព័រ ២៧, Supkong, P. និង Bourne, L., "ការស្ទង់មតិលើ គម្របស្មៅសមុទ្រក្នុងខេត្តកំពត កម្ពុជា" ឆ្នាំ ២០១៤។

[35] ទំព័រ ១៨, Kaarlep, A., "ការស្ទង់មតិផ្នែកសង្គមសេដ្ឋកិច្ច ស្តីពីសារៈសំខាន់នៃគម្របស្មៅសមុទ្រ មកលើសហគមន៍រស់នៅតាមបណ្តោយឆ្នេរ ក្នុងខេត្តកំពត" ឆ្នាំ២០១៤។

មានសារៈសំខាន់យ៉ាងខ្លាំងចំពោះប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចបែបនេះក៏ដោយ ក៏ស្មៅទាំងនោះកំពុងតែរងការគំរាមកំហែងពីការនេសាទខុសច្បាប់ ការនេសាទហួសកម្រិត ការបំពុលបរិស្ថាន និងការកកើតកំណក ជាលទ្ធផលមកពីគម្រោងអភិវឌ្ឍន៍តាមឆ្នេរសមុទ្រ។[36]

ព្រៃកោងកាងគឺជាធនធានដ៏សំខាន់មួយទៀតសម្រាប់ប្រព័ន្ធអេកូឡូស៊ី។ ព្រៃកោងកាង គឺជាជម្រកសម្រាប់ត្រីតូចៗ ហើយព្រៃទាំងនេះក៏ជួយរារាំងការកកើតកំណកនៅលើគម្របស្មៅសមុទ្រ ហើយជួយឲ្យស្មៅទាំងនេះអាចទទួលពន្លឺព្រះអាទិត្យដើម្បីរស់រានមានជីវិត។ ព្រៃកោងកាងក៏ការពារការសឹករិចរិលនៃឆ្នេរសមុទ្រ និងការពារឆ្នេរពីព្យុះភ្លៀងផងដែរ។[37] នៅតាមបណ្តោយឆ្នេរសមុទ្រកំពត មានព្រៃកោងកាងប្រមាណជា ១,៩៦០ ហិកតា។ ក្រុមការងារស្រាវជ្រាវ មិនអាចស្វែងរកព័ត៌មានស្តីពីការប៉ាន់ប្រមាណតម្លៃផ្នែកសេដ្ឋកិច្ចនៃព្រៃកោងកាងទាំងអស់នេះបានទេ។ ព្រៃកោងកាងក៏កំពុងតែរងការគំរាមកំហែង ពីគម្រោងអភិវឌ្ឍន៍តាមឆ្នេរសមុទ្រដែរ (សូមមើល ជំពូក ៦)។

## ជីវភាព

របាយការណ៍នេះ ផ្តោតលើផលប៉ះពាល់ដែលនឹងកើតមាន ដោយសារគម្រោងកំពង់ផែទេសចរណ៍កំពតមកលើប្រជាពលរដ្ឋក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ។ ក្នុងឃុំទាំងនេះ ការនេសាទជារបរដ៏សំខាន់មួយសម្រាប់ជីវភាពរបស់ប្រជាពលរដ្ឋមួយភាគធំ។ ក្នុងឆ្នាំ២០១៦ មានប្រជាពលរដ្ឋតិចជាង ១៥,០០០ នាក់ រស់នៅក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ (មើលតារាងខាងក្រោម)។ បើតាមការសម្ភាសន៍របស់ក្រុមស្រាវជ្រាវជាមួយប្រធានក្រុមប្រឹក្សាឃុំទាំងនេះ មានភូមិតែពីរប៉ុណ្ណោះ ដែលអ្នកភូមិមិនប្រកបរបរនេសាទទាល់តែសោះ គឺភូមិកូនសត្វ និងភូមិបុស្សញិញ។ ប្រសិនបើមិនរាប់ភូមិទាំងពីរនេះ មានប្រជាពលរដ្ឋប្រមាណ ៩,០០០ នាក់ នៅក្នុងឃុំទាំងពីរនេះ ពឹងផ្អែកលើការនេសាទជាចម្បងដើម្បីទទួលបានប្រាក់ចំណូល។

ទឹករាក់ៗជុំវិញព្រៃកោងកាង និងគម្របស្មៅសមុទ្រ ជាកន្លែងអ្នកភូមិទាំងប្រុសទាំងស្រីមកពីឃុំទាំងនេះ ដើររាវគ្រែង និងក្តាម។ ពួកគេចុះក្នុងទឹកសមុទ្រ ពេលដែលទឹកនាច ហើយរាវគ្រែង និងក្តាមទាំងនោះពីបាតសមុទ្រដោយប្រើដៃ ឬប្រសិនបើទឹករាងជ្រៅបន្តិច ពួកគេប្រើជើង។ អ្នករាវមួយចំនួនជិះទូករួមគ្នា ដើម្បីធ្វើដំណើរទៅតំបន់ដែលសម្បូរគ្រែង និងក្តាម។ ជាទូទៅ ពួកគេអាចរាវគ្រែង និងក្តាមពីមាត់ស្ទឹងទឹកឈូ និងជុំវិញកោះស្មៅ។ ជារៀងរាល់ថ្ងៃ ពេលដែលពួកគេត្រលប់មកឆ្នេរវិញពួកគេលក់

[36] ទំព័រ ៤៨-៥១, Supkong, P. និង Bourne, L., "ការស្ទង់មតិផ្នែកសង្គមសេដ្ឋកិច្ច ស្តីពីសារៈសំខាន់នៃគម្របស្មៅសមុទ្រ មកលើសហគមន៍រស់នៅបណ្តោយឆ្នេរ ក្នុងខេត្តកំពត" ឆ្នាំ២០១៤។

[37] ទំព័រ ៨, Paul - Emmanuel Muylaert, "វាយតម្លៃលទ្ធភាពត្រលប់មកសភាពដូចមុននៃឆ្នេរសមុទ្រកំពត៖ ផ្លូវដើរទៅកាន់ការសម្របសម្រួលនឹងបម្រែបម្រួលអាកាសធាតុ" ឆ្នាំ២០១៥។ អាចរកបាន ៖ https://www.iucn.org/sites/dev/files/import/downloads/iucnbcr_resilience__final_draft_14_7_15.pdf.

គ្រែង និងក្តាមទាំងនេះទៅឈ្មួញដែលនឹងយកអាហារសមុទ្រទាំងនេះទៅលក់នៅឯផ្សារ។

អ្នកអូសបង្គា រុញឈើបដែលចងនឹងឫស្សីតាមបណ្តោយឆកសមុទ្រ។ អ្នកអូសបង្គាភាគច្រើន ជាបុរស។ ក្រុមអ្នកអូសបង្គា យកកូនទូកតូចចេញទៅតាមបណ្តោយឆ្នេរ ពេលព្រលប់ៗ និងចំណាយពេលក្នុងយប់នោះរុញឈើបតាមទឹករាក់ៗ ពួកគេត្រលប់មកច្រាំងវិញ ប្រហែលជាម៉ោង ៣ ឬ ៤ ទៀបភ្លឺ។ ពួកគេលក់បង្គាដែលគេអូសបានទៅឈ្មួញកណ្តាល ពេលឡើងមកដល់ឆ្នេរភ្លាម។ ប៉ុន្តែ ប្រសិនបើតម្លៃទាប ពួកគេ ឬភរិយារបស់ពួកគេនឹងលក់បង្គាទាំងនោះនៅផ្សារ ឬក៏សម្ងួតរួចសឹមលក់ពេលក្រោយ។ ក្នុងឃុំដែលក្រុមអ្នកស្រាវជ្រាវបានចុះទៅដល់ ជាធម្មតា អ្នកអូសបង្គាធ្វើដំណើរទៅក្បែរមាត់ស្ទឹងទឹកឈូ កោះស្មៅ ឬក៏ឆ្នេរក្បែរភ្នំដូង។

| ឃុំ | ភូមិ | គ្រួសារ | ប្រជា.ព |
|---|---|---|---|
| ត្រពាំងសង្កែ | | ១,០៩២ | ៥,៨៥៩ |
| | ត្រពាំងធំ | ៣០៤ | ១,៥៧៩ |
| | ត្រពាំងសង្កែ | ៤៥៨ | ២,៧២៩ |
| | កំពង់កែស | ៣៣០ | ១,៥៥១ |
| កូនសត្វ | | ១,៨៤៨ | ៨,៩៤៤ |
| | កំពង់ត្នោត | ៥០១ | ២,២១៦ |
| | កំពង់នង់ | ៣៤៤ | ១,៦៦២ |
| | កូនសត្វ | ៣៨៥ | ២,០៦៤ |
| | បុស្សញិញ | ៦១៨ | ៣,០០២ |
| **សរុប** | | **២,៩៤០** | **១៤,៨០៣** |

អ្នកនេសាទដទៃទៀត នៅក្នុងឃុំទាំងនេះប្រើសំណាញ់ដើម្បីចាប់ត្រី ក្នុងឆកសមុទ្រកំពត។ ព្រៃកោងកាងមានភាពចាំបាច់ណាស់សម្រាប់អ្នកនេសាទ ៖ មិនមែនគ្រាន់តែជាធនធានចម្បងក្នុងប្រព័ន្ធអេកូឡូស៊ីនោះទេ ប៉ុន្តែក៏អាចប្រើជាជម្រកនៅពេលមានព្យុះផងដែរ។ ប្រជាពលរដ្ឋភាគតិចណាស់ ដែលធ្វើការលើទូកធំៗ ហើយមានលទ្ធភាពបើកកាត់តាមទឹកជ្រៅទៅកាន់ខេត្តក្បែរៗនោះ។

អ្នកចូលរួមក្នុងការស្រាវជ្រាវនេះ បានពណ៌នាអំពីទំនោរ និងព្រឹត្តិការណ៍ដែលបង្កការគំរាមកំហែងដល់ជីវភាពរបស់ពួកគេ ដូចជា ការផ្លាស់ប្តូរផ្នែកប្រជាសាស្ត្រ ការនេសាទខុសច្បាប់ និងការអភិវឌ្ឍន៍នៅលើឆ្នេរសមុទ្រ (សូមអានជំពូក ៦)។ ក្នុងអំឡុងកិច្ចពិភាក្សាក្រុម ក្នុងឃុំកូនសត្វ អ្នកចូលរួមបានជជែកពីផលប៉ះពាល់នៃកំណើនប្រជាពលរដ្ឋ មកលើប្រាក់ចំណូលរបស់ពួកគេ ៖



រូបភាពទី ៦ ៖ អ្នករុញឈឺប ត្រៀមទូកចេញទៅធកសមុទ្រ កំពតនាពេលយប់

"ចំនួនអ្នកនេសាទកើនឡើង។ ប្រជាពលរដ្ឋមកពីភូមិផ្សេងទៀត និងអ្នកខ្លះរៀបការចូលមកក្នុងសហគមន៍នេះ។ ចំណុចនេះធ្វើឲ្យប្រាក់ចំណូលរបស់យើងថយចុះ។ ពួកគេមកពីភូមិនៅតាមបណ្ដោយឆ្នេរ អ្នកខ្លះ មកពីខេត្តផ្សេងទៀតផង ដោយសារតែនៅទីនេះមានទឹករាក់ៗ និងសម្បូរធនធានជាច្រើន"។[38]

អ្នកផ្សេងទៀត រអ៊ូពីការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ដែលបំផ្លិចបំផ្លាញដល់ប្រព័ន្ធអេកូឡូស៊ី និងប៉ះពាល់ដល់ធនធានត្រី។[39] ស្ត្រីម្នាក់អាយុ ៤៤ ឆ្នាំ មកពីឃុំកូនសត្វ ពន្យល់ពីផលប៉ះពាល់នៃការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់មកលើប្រាក់ចំណូលគ្រួសាររបស់គាត់ ៖

> *"ប្ដីរបស់ខ្ញុំ ជាអ្នកនេសាទ ហើយពួកយើងក៏ដាំដំណាំនៅជុំវិញផ្ទះដែរ។ យើងមានទូកម៉ូទ័រតូចមួយ សម្រាប់ចាប់ក្ដាមក្បែរកោះស្មៅ។ យើងអាចលក់ក្ដាមក្នុងមួយគីឡូក្រាម ប្រហែលជា ១០,០០០ រៀល [២,៥ ដុល្លារអាមេរិក]។ ប្រសិនបើក្ដាមមានសាច់ច្រើន យើងអាចលក់បានប្រហែលជា ៥ ដុល្លារអាមេរិក ក្នុងមួយគីឡូក្រាម។ មានឆ្នាំខ្លះកាក់កប ហើយឆ្នាំខ្លះក៏មិនសូវ។ ឆ្នាំមុននេះ រកមិនសូវបានទេ។ មានទូកជាច្រើនដែលមានសំណាញ់ប្រភេទពិសេសៗ ដែលអាចស្រវ៉ាចាប់សត្វសមុទ្រគ្រប់ប្រភេទ ពួកគេចាប់ បង្គា មឹក និងត្រីតូចៗ។ អ្នកនេសាទទាំងនោះមកពីក្រៅសហគមន៍។ ភាគច្រើនគេមកចាប់ត្រីពេលយប់ ដោយសារតែពួកគេប្រើឧបករណ៍ខុសច្បាប់។ ប្រសិនបើយើងដឹង យើងនឹងរាយការណ៍ទៅប៉ូលីស។ រឿងបែបនេះកើតឡើងជាបន្តបន្ទាប់ អស់រយៈពេល ២ ទៅ ៣ ឆ្នាំហើយ។ ចំនួនក្ដាមដែលចាប់បានក៏ធ្លាក់ចុះពី ៣ គីឡូក្រាម ទៅត្រឹម ១ គីឡូក្រាម អញ្ចឹងប្រាក់ចំណូលរបស់យើងធ្លាក់ចុះ។ យើងសង្ឃឹមថាពួកគេនឹងមិនត្រលប់មកវិញទេ។ ក្នុងឆ្នាំដែលរកមិនសូវបាន យើងដាំបន្លែ យើងត្រូវការប្រាក់សម្រាប់ការអប់រំរបស់កូនៗយើង។"[40]*

គ្រួសារមួយភាគធំ រកប្រាក់ចំណូលបន្ថែមទៅលើការនេសាទ ដោយធ្វើកសិកម្ម ៖ ធ្វើស្រែក្បែរផ្ទះ ចិញ្ចឹមសត្វ និងដាំបន្លែ។ ប្រជាពលរដ្ឋដែលមានដីដាំដុះ ឬក៏សត្វចិញ្ចឹម ពួកគេអាចប្រើប្រាស់ធនធាន

[38] កិច្ចពិគ្រោះយោបល់ក្រុម ជាមួយស្ត្រីបីនាក់ និងបុរសបួននាក់ មកពីឃុំកូនសត្វ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦។

[39] សូមអានបន្ថែម ទំព័រ ៣៩, Kaarlep, A., "ការស្ទង់មតិផ្នែកសង្គមសេដ្ឋកិច្ច ស្ដីពីសារៈសំខាន់នៃគម្របស្មៅសមុទ្រ មកលើសហគមន៍រស់នៅតាមបណ្ដោយឆ្នេរ ក្នុងខេត្តកំពត" ឆ្នាំ២០១៤។

[40] កិច្ចសម្ភាសន៍ជាមួយស្ត្រីម្នាក់មកពី ឃុំកូនសត្វ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦។

ទាំងនេះដើម្បីបំពេញបន្ថែមលើប្រាក់ចំណូលពីការនេសាទដែលធ្លាក់ចុះ។ ប្រសិន បើគ្មានធនធានដូចបានរៀបរាប់ទេនោះ ប្រជាពលរដ្ឋ នឹងជួបប្រទះអសន្តិសុខស្បៀង។ ស្ត្រីម្នាក់មកពីឃុំកូនសត្វ ដែលកំពុងតែទម្ងន់កូនទី៧ បានប្រាប់ក្រុមអ្នកស្រាវជ្រាវពីបញ្ហាប្រឈម ខណៈដែលគាត់ពុំមានដីកសិកម្មថា ៖

*"ប្រាក់ចំណូលរបស់យើងឡើងចុះ។ ខែខ្លះរកបាន ខែខ្លះមិនសូវបាន។ ក្នុងរយៈពេលពីរឬបីខែចុងក្រោយគឺពិបាកណាស់។ ពេលដែលចាប់បានច្រើន យើងចំណាយថវិកានេះទិញចំណីជ្រូក និងសាំងក្នុងការធ្វើដំណើរ ហើយយើងទិញអង្ករទៀត ដោយសារតែយើងគ្មានដីស្រែ។ ពេលដែលចាប់មិនសូវបាន យើងក៏ញុំាតិចតាមនឹងទៅ។"*[41]

ក្នុងករណីខ្លះ សមាជិកក្នុងគ្រួសារផ្លាស់ទីលំនៅទៅប៉ែកផ្សេងទៀតក្នុងប្រទេស ឬក៏តំបន់ដើម្បីធ្វើការក្នុងរោងចក្រកាត់សម្លៀកបំពាក់ ស៊ីឈ្នួលនេសាទជាមួយទូកធំៗ ឬក៏វិស័យសេវាកម្ម។

## សហគមន៍នេសាទ

ក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ អ្នកនេសាទបង្កើតជាសហគមន៍នេសាទ។ ការបង្កើតនេះពាក់ព័ន្ធនឹងទំនួលខុសត្រូវ "ដើម្បីចូលរួមក្នុងការគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព" ដោយមានការគ្រប់គ្រងពីអាជ្ញាធរជលផល ភ្នាក់ងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។[42] សហគមន៍នេសាទ ការពារប្រព័ន្ធអេកូឡូស៊ី រួមទាំង រាយការណ៍ពីការនេសាទខុសច្បាប់។ អ្នកនេសាទដែលមិនមែនជាសមាជិកសហគមន៍ អាចអនុញ្ញាតឲ្យប្រើប្រាស់តំបន់នេសាទសហគមន៍បាន ប្រសិនបើពួកគេគោរពតាមលក្ខន្តិកៈរបស់សហគមន៍។ អាជ្ញាធរជលផលទទួលខុសត្រូវក្នុងការបញ្ឈប់បទល្មើសនេសាទ និងដោះស្រាយជម្លោះក្នុងតំបន់នេសាទសហគមន៍។ កិច្ចព្រមព្រៀងរបស់សហគមន៍នេសាទ ត្រូវតែធ្វើឡើងជាថ្មីរៀងរាល់ ៣ ឆ្នាំម្តង។

ខណៈដែលសហគមន៍នេសាទ បង្កើតកិច្ចសហប្រតិបត្តិការរវាងអ្នកនេសាទ និងរដ្ឋាភិបាល តំបន់នេសាទសហគមន៍ នៅតែជាកម្មសិទ្ធិរបស់រដ្ឋ[43] ហើយរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចលុបតំបន់នេសាទសហគមន៍ចោល "ដើម្បីប្រយោជន៍រួម" ដោយមានការជូនដំណឹងទុកជាមុនតែ ៦ ខែប៉ុណ្ណោះ។[44] អ្នកនេសាទនៅតែមានសិទ្ធិនេសាទ 'ជាលក្ខណៈគ្រួសារ' នៅលើផ្ទៃ

[41] កិច្ចសម្ភាសន៍ជាមួយស្ត្រីម្នាក់មកពី ឃុំកូនសត្វ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦។

[42] មាត្រា ៥៩, ច្បាប់ស្តីពីជលផល ឆ្នាំ២០០៦។

[43] មាត្រា ៣ អនុក្រឹត្យលេខ ៨០ ស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ។

[44] សូមអាន មាត្រា ៦៣ ច្បាប់ស្តីពីជលផល "រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិរំសាយកន្លែងនេសាទសហគមន៍ តាមការចាំបាច់ណាមួយសម្រាប់ផលប្រយោជន៍សាធារណៈ" និង មាត្រា ២៧ អនុក្រឹត្យលេខ ៨០ ស្តីពី ការគ្រប់គ្រងសហគមន៍

សមុទ្រ ប្រសិនបើសហគមន៍នេសាទត្រូវបានលុបចោលនោះ។

សហគមន៍នេសាទកំពង់សាមគ្គី បានចុះបញ្ជីក្នុង ឆ្នាំ២០១១ ដោយមានសមាជិក ៣៩៦ នាក់ (ប្រុស ២៥៨ នាក់ និងស្រី១៣៨ នាក់) មកពីភូមិកំពង់ត្នោត និងកំពង់នង់ ក្នុងឃុំកូនសត្វ។ ប្រជាពលរដ្ឋទាំងអស់នៅឃុំកូនសត្វ ជាជនជាតិខ្មែរ។ តំបន់សហគមន៍នេសាទ ដូចបានបង្ហាញក្នុងរូបភាព ទី៧ មានទំហំ ៥៧៧ ហិកតា។ សហគមន៍នេសាទត្រពាំងសង្កែ បង្កើតឡើងក្នុង ឆ្នាំ២០០៩ និងចុះបញ្ជីក្នុង ឆ្នាំ២០១១ ដោយមានសមាជិក ៧៣៤ នាក់ (ប្រុស៣៧១ នាក់ និងស្រី៣៦៣ នាក់) មកពីភូមិទាំង ៣ នៅក្នុងឃុំត្រពាំងសង្កែ ដែលក្នុងនោះមានជនជាតិខ្មែរ និងចាម។ តំបន់សហគមន៍នេសាទ ដូចដែលបានបង្ហាញក្នុងរូបទី ៧ គឺ៣៣៧ ហិកតា។

ប្រជាពលរដ្ឋភាគច្រើន ដែលត្រូវបានសម្ភាសន៍សម្រាប់ការសិក្សានេះ គឺជាសមាជិកនៃសហគមន៍នេសាទ។ អ្នកដែលមិនមែនជាសមាជិក បានលើកឡើង ថាគេមិនចូលរួមជាសមាជិកដោយសារតែគេមិនចង់ចូលរួមប្រជុំជាទៀងទាត់ ឬពួកគេនេសាទជាមួយទូកធំៗ ហើយមិនអាចនេសាទក្នុងឆកសមុទ្រកំពតនោះទេ។ ប្រធានភូមិក៏បាននិយាយថា ប្រជាពលរដ្ឋដែលរស់នៅឆ្ងាយពីទីតាំងរបស់សហគមន៍មិនបានចូលរួម ដោយសារតែពួកគេពិបាកក្នុងការចូលរួមប្រជុំ។





រូបភាពទី ៧ ៖ តំបន់សហគមន៍នេសាទ ក្នុងកំពង់សាមគ្គី (ឆ្វេង) និងត្រពាំងសង្កែ (ស្តាំ)។

## ផលប៉ះពាល់ដែលនឹងកើតមាន ដោយសារគម្រោងកំពង់ផែទេសចរណ៍កំពត ៖ ការបំពុលបរិស្ថាន

ប្រសិនបើការសាងសង់ និងការដាក់កំពង់ផែឲ្យប្រើប្រាស់ មិនត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្នទេនោះ ការបំពុលបរិស្ថានអាចនឹងបំផ្លាញប្រព័ន្ធអេកូឡូស៊ី។ ការសិក្សាបរិស្ថានបឋម ដែលក្រសួងទេសចរណ៍បានដាក់ស្នើទៅ ADB កត់សម្គាល់ថាការបំពុលបរិស្ថានអាចបណ្តាលឲ្យបាត់បង់

---

នេសាទ ៖ "កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អាចបញ្ឈប់ដោយផ្អែកលើ....ការយល់ឃើញរបស់រាជរដ្ឋាភិបាលនូវគោលបំណងផ្សេងមួយទៀត ដែលផ្តល់ផលប្រយោជន៍សាធារណៈ និងសង្គមចំពោះព្រះរាជាណាចក្រកម្ពុជាច្រើនជាង។"

ជីវៈចម្រុះ ដែលជាផលប៉ះពាល់ចម្បងមួយនៃការអនុវត្តគម្រោងនេះ។ ប្រសិនបើសម្ភារៈសំណង់ត្រូវបោះចោលទៅក្នុងសមុទ្រ កំណាកធូលីនឹងកកលើស្មៅសមុទ្រ នឹងបាំងពន្លឺថ្ងៃ និងធ្វើឲ្យស្មៅសមុទ្រមិនអាចធ្វើរស្មីសំយោគបាន ដូច្នេះនឹងបណ្តាលឲ្យខូចខាតដល់គម្របស្មៅសមុទ្រ។ ការសិក្សារបស់ IUCN រកឃើញថាការសាងសង់កំពង់ផែ ក្នុងតំបន់សេដ្ឋកិច្ចពិសេសកំពតនឹងធ្វើឲ្យកករទឹក និងបណ្តាលឲ្យមានការបំផ្លាញមកលើស្មៅសមុទ្រក្នុងឆកសមុទ្រកំពត។[45] ក្នុងអំឡុងពេលបើកកំពង់ផែឲ្យដំណើរការ ការកើនឡើងនៃចំនួនទូក នឹងបង្កើនហានិភ័យនៃការហូរទឹកកខ្វក់ទៅក្នុងទឹក និងការបំផ្លាញជាក់ស្តែងមកលើគម្របស្មៅសមុទ្រ ដោយសារតែស្លាបចក្រកាណូត និងយុថ្កា។

IEE ស្នើថាការគ្រប់គ្រងសកម្មភាពសាងសង់ដោយប្រុងប្រយ័ត្ន តាមរយៈវិធានការគ្រប់គ្រងកាកសំណល់ និងរបាំងដីល្បាប់ក្នុងទឹកនៅជុំវិញទីតាំងសំណង់នោះ អាចកាត់បន្ថយការបំពុលបរិស្ថានដែលជាលទ្ធផលនៃការសាងសង់កំពង់ផែ។ ការសិក្សានេះក៏ស្នើឲ្យបង្កើតបទបញ្ជាសម្រាប់គ្រប់គ្រងទូក និងកាណូត ក្នុងឆកសមុទ្រកំពត តាមរយៈផែនការគ្រប់គ្រងនាវាចរណ៍ដែល "ក្រៅពីសេចក្តីបង្គាប់ផ្សេងៗ គួរតែបង្ហាញច្បាស់ពីជម្រៅ និងប្រវែងអតិបរមារបស់ទូក កំណត់ព្រំឃ្លោង និងច្រកសម្រាប់ទូកប្រភេទផ្សេងៗគ្នា ព្រមទាំងកំណត់ព្រំតំបន់អភិរក្សស្មៅសមុទ្រ និងតំបន់ព្រៃកោងកាងដែលមិនអនុញ្ញាតឲ្យទូកឆ្លងកាត់"។[46]

ដាច់ដោយឡែកពីគម្រោងកំពង់ផែទេសចរណ៍កំពត ឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូកំពុងតែត្រូវបានស្តារ (សូមអាន ជំពូក ៦)។ ប្រសិនបើឃ្លោងសមុទ្រត្រូវពង្រីក ឬស្តារ ឃ្លោងនេះនឹងអាចអនុញ្ញាតឲ្យមានចំនួនទូកច្រើន និងធំៗជាងមុន ចូលមកកំពង់ផែកំពត ការរុកគួនដល់គម្របស្មៅសមុទ្រ នឹងបង្កឲ្យមានកំណាកក្នុងទឹក ដែលនឹងកាន់តែបង្កការខូចខាតដល់ស្មៅសមុទ្រក្នុងឆកសមុទ្រកំពតបន្ថែមទៀត។ ការសិក្សាបរិស្ថានបឋម បញ្ជាក់ក្នុងកំណត់សម្គាល់យោងថា "គម្រោងតូចៗមិនតម្រូវឲ្យមានការបូមខ្សាច់ និងមិនចាំបាច់បូមខ្សាច់ចេញពីស្ទឹងនោះទេ"។[47] មន្ត្រីមកពី ADB និងមន្ទីរទេសចរណ៍បញ្ជាក់ថាការស្តារឃ្លោងសមុទ្រ មិនមែនជាផ្នែកមួយនៃគម្រោងកំពង់ផែកំពតនោះទេ។ ប៉ុន្តែ អាជ្ញាធរអាចសម្រេចចិត្តនឹងស្តារឃ្លោង ក្រៅវិសាលភាពគម្រោងដែលឧបត្ថម្ភដោយ ADB ហើយមានហេតុផលជាច្រើនដែលអះអាងថាពួកគេនឹងស្តារឃ្លោងនេះ។ IEE កត់សម្គាល់ថា "រង្វាស់នៃឃ្លោងសមុទ្រដែលមានប្រវែងប្រមាណ ៨០-១០០ ម៉ែត្រ x ៥គីឡូម៉ែត្រ គួរតែមានការស្ទង់មតិ ដើម្បីធានាថាជម្រៅសមល្មមក្នុងពេលទឹកនាច សម្រាប់ជម្រៅទូកនាពេលអនាគត និងមើលថាតើឃ្លោងទាំងពីរនឹងត្រូវការដាក់ឲ្យប្រើ ដើម្បីសម្របនឹងកំណើនចរាចរណ៍ទូក"។[48] បន្ថែមពីលើនេះ ការសិក្សានេះបានស្នើទៀត

[45] ទំព័រទី ២២, Paul - Emmanuel Muylaert, "វាយតម្លៃលទ្ធភាពត្រលប់មកសភាពដូចមុននៃឆ្នេរសមុទ្រកំពត៖ ផ្លូវដើរទៅកាន់ការសម្របសម្រួលនឹងបម្រែបម្រួលអាកាសធាតុ" ឆ្នាំ២០១៥។

[46] ទំព័រ ii និងទំព័រ ៣៦ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

[47] កំណត់សម្គាល់ ២៥, ទំព័រ ៤១ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

[48] ទំព័រ ៣៧ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

ថា ប្រយោជន៍មួយក្នុងចំណោមប្រយោជន៍ផ្សេងៗនៃគម្រោងគឺ កាណូតដឹកទំនិញ ប្រើប្រាស់កំពង់ផែពីមុន "នឹងមិនចាំបាច់ធ្វើតាមទម្លាប់ចាស់ ដោយទម្លាក់ទំនិញតាមខ្សែទឹកក្នុងអំឡុងពេលទឹកនាច ឬក៏ក្នុងអំឡុងរដូវប្រាំង" ដែលជាការលើកឡើងថាកំពង់ផែនេះនឹងអាចជំរុញឲ្យមានការជីកឈ្លូងនោះឲ្យកាន់តែជ្រៅថែមទៀត។[49]

សកម្មភាពដែលអាចប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ក្នុងឆកសមុទ្រកំពត គឺជាបញ្ហាដ៏ធំរបស់អ្នកនេសាទដែលរស់នៅក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ។ ប្រសិនបើមិនមានការគ្រប់គ្រងឲ្យបានច្បាស់លាស់ទេ ការងារសំណង់នៅលើដី និងការដាក់កំពង់ផែឲ្យប្រើប្រាស់ អាចនឹងបន្តបង្កការខូចខាតដល់គម្របស្មៅសមុទ្រថែមទៀត ហើយនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរបស់ប្រជាពលរដ្ឋ។ ការបន្តស្តារឈ្លូងសមុទ្រទឹកឈូ គួរតែត្រូវបានវាយតម្លៃដោយប្រុងប្រយ័ត្ន ដោយអាជ្ញាធរខេត្តកំពត (សូមអាន ជំពូក ៦)។



រូបភាពទី ៨ ៖ រូបភាពនៃការជីកដីក្នុងឈ្លូងសមុទ្រ ដែលថតពីលើទំនប់។ កោះស្មៅ អាចមើលឃើញនៅខាងឆ្វេងដៃ។ រូបថតមើលពីខាងជើងតម្រង់ទៅទីតាំងកំពង់ផែ។

### ផលប៉ះពាល់ដែលនឹងកើតមាន ដោយសារគម្រោងកំពង់ផែទេចរណ៍កំពត ៖ ការចាប់យកធនធានជលផល

អ្នកនេសាទក៏បារម្ភថា កំពង់ផែថ្មីនេះនឹងរារាំងពួកគេមិនឲ្យចូលទៅកាន់តំបន់កោះស្មៅ ឬតំបន់នេសាទត្រីជុំវិញភ្នំដូង ខាងលិចខេត្តកំពត។ ដើម្បីទៅដល់តំបន់ទាំងនេះ អ្នកនេសាទត្រូវឆ្លងកាត់

[49] ទំព័រ ២៩ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

ទំនប់ដីដែលជីកចេញពីការស្តារឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូ និងទីតាំងគម្រោង។ មានជម្រើសមួយទៀត នោះគឺត្រូវធ្វើដំណើរវាងទំនប់ឃ្លោងនេះ តាមតំបន់ទឹកជ្រៅ។ ការវាងទំនប់នេះនឹងធ្វើឲ្យការធ្វើដំណើរវែងឆ្ងាយជាងមុន ហើយមនុស្សភាគច្រើននិយាយថាការឆ្លងទឹកជ្រៅដោយប្រើទូកតូចបែបនេះពុំមានសុវត្ថិភាពនោះទេ។

កំណើនចរាចរណ៍ទូកនៅទីតាំងកំពង់ផែអាចធ្វើឲ្យត្រូវចំណាយពេលវេលា និងថវិកាច្រើន។ មនុស្សមួយចំនួន ក៏បារម្ភដែរថាពួកគេនឹងត្រូវបានហាមឃាត់មិនឲ្យឆ្លងផ្លូវទឹកវាងឃ្លោងសមុទ្រ និងកំពង់ផែនោះតែម្តង។ ក្នុងអំឡុងកិច្ចពិភាក្សាក្រុម អ្នកចូលរួមបានពន្យល់ថាផលប៉ះពាល់ដែលនឹងអាចកើតមាននៃការកាត់បន្ថយការចូលទៅដល់តំបន់ទាំងនោះ ៖

> *"ប្រហែល ៣ ឬ ៤ឆ្នាំមុន ពួកគេ [ស្តារឃ្លោងសមុទ្រ និងសង់ទំនប់]។ ឥឡូវយើងត្រូវធ្វើដំណើរជុំវិញ។ ប្រសិនបើមានកំពង់ផែ យើងមិនដឹងថាយើងអាចឆ្លងកាត់ [ផ្លូវទឹកវាងឃ្លោង និងឆ្នេរ] បានដែរឬទេ។ ពួកយើងច្បាស់ជាពិបាកណាស់ ប្រសិនបើត្រូវធ្វើដំណើរវាងឃ្លោងនេះ។ មួយទៀត ក៏ជារឿងគ្រោះថ្នាក់ដែរ ប្រសិនបើទូកតូចរបស់យើងត្រូវចូលក្នុងតំបន់ទឹកជ្រៅ។ មិនតែប៉ុណ្ណោះ នៅពេលដែលយើងត្រូវធ្វើដំណើរឆ្ងាយ យើងត្រូវចំណាយច្រើនលើថ្លៃសាំង។ កាលពីមុន យើងចំណាយអស់កន្លះលីត្រ ឥឡូវយើងចំណាយអស់ ១ លីត្រ។ ថ្លៃចំណាយកើនឡើង។ ពេលខ្លះរកមិនបានអ្វីសោះ ហើយក៏នៅតែចំណាយដដែល"*[៥០]

ដោយសារកង្វះខាតព័ត៌មានលម្អិត ប្រជាពលរដ្ឋជាច្រើនមានការព្រួយបារម្ភពីគម្រោងកំពង់ផែកំពតដោយសារថាគម្រោងនេះអាចនឹងហាមឃាត់ប្រជាពលរដ្ឋមិនឲ្យប្រើប្រាស់ច្រកនេះ។

ផែនការតាមដានបរិស្ថាន (EMP) ដែលបានដាក់ស្នើទៅ ADB បានបញ្ជាក់ថា "គណៈកម្មាធិការនឹងត្រូវបានបង្កើត ដោយមានសមាជិកពី [មន្ទីរទេសចរណ៍ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីរបរិស្ថាន] អាជ្ញាធរនាវាចរណ៍ជើងទឹកផ្សេងទៀត និងសមាគមទូកនេសាទ និងទូកទំនិញខេត្តកំពត ដើម្បីពិនិត្យមើលតម្រូវការនាវាចរណ៍ របាយការណ៍ដែលមានស្រាប់ និងការស្រាវជ្រាវដែលចាំបាច់ ក្នុងការផលិតទិន្នន័យ/ព័ត៌មានចាំបាច់ ដើម្បីបង្កើតផែនការ និងបទបញ្ជាគ្រប់គ្រងនាវាចរណ៍"។[51] ពិតជាសំខាន់ខ្លាំងណាស់ ដែលប្រជាពលរដ្ឋប្រើប្រាស់ផ្លូវទឹកនេះ មានតំណាងចូលរួមក្នុងគណៈកម្មាធិការនេះ ហើយផលប្រយោជន៍របស់ពួកគាត់ត្រូវបានឆ្លុះបញ្ចាំងក្នុងផែនការគ្រប់គ្រងនាវាចរណ៍។

[50] កិច្ចពិភាក្សាក្រុម ក្នុងឃុំកូនសត្វ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦។

[51] ទំព័រ ៨ ក្នុង "ផែនការតាមដានបរិស្ថាន" របស់ ADB ខែមីនា ឆ្នាំ២០១៤។ អាចរកបាន ៖ https://www.adb.org/projects/documents/gms-tourism-infrastructure-inclusive-growth-project-kampot-pier-development-emp.

## ការតាមដាន និងរាយការណ៍



រូបភាពទី ៩ ៖ តំបន់ព្រៃកោងកាងក្នុង សហគមន៍នេសាទត្រពាំងសង្កែ។

ដើម្បីធានាថា វិធានការការពារការបំផ្លាញបរិស្ថាន ត្រូវបានអនុវត្ត EMP ស្នើឲ្យមានក្របខ័ណ្ឌតាមដានលម្អិត។ អង្គភាពអនុវត្តគម្រោង (PIU) ក្នុងមន្ទីរទេសចរណ៍ក្នុងខេត្តកំពតទទួលខុសត្រូវដើម្បីអនុវត្ត EMP ។ PIU នឹងត្រួតពិនិត្យលើការងាររបស់ក្រុមហ៊ុនម៉ៅការសាងសង់ និងពិនិត្យមើលរបាយការណ៍ប្រចាំខែពីមន្ត្រីបរិស្ថាន របស់ក្រុមហ៊ុនម៉ៅការសាងសង់។ អ្នកជំនាញផ្នែកបរិស្ថាន ដែលជាសមាជិកនៃទីប្រឹក្សាគ្រប់គ្រង និងគូរប្លង់លម្អិត នឹងផ្តល់ជំនួយបច្ចេកទេស ដើម្បីជួយទ្រទ្រង់ អង្គភាពអនុវត្តគម្រោង ហើយនឹងជួលទីប្រឹក្សាគ្រប់គ្រងបរិស្ថានម្នាក់ផងដែរ ដើម្បីរៀបចំការតាមដាន និងវិភាគតាមលក្ខណៈវិទ្យាសាស្ត្រ។ មុនពេលធ្វើការសាងសង់ ទីប្រឹក្សាគ្រប់គ្រងបរិស្ថាន នឹងរៀបចំវាស់វែងជាបឋមលើគុណភាពទឹក និងកែលម្អទិន្នន័យបឋម ស្តីពីពូជសត្វកម្រ និងជិតជាប់ពូជ ជម្រកសត្វដែលចាំបាច់ ធនធានជលផល និងសកម្មភាពផ្សេងៗទៀត។ ក្នុងអំឡុងពេលសាងសង់ ទីប្រឹក្សាគ្រប់គ្រងបរិស្ថាន នឹងបន្តវាយតម្លៃក្នុងរយៈពេលបីខែម្តង ទៅលើគុណភាពទឹក និងបញ្ជូនរបាយការណ៍ប្រចាំត្រីមាស ទៅ PIU ។ PIU នឹងប្រមូលព័ត៌មានពីក្រុមហ៊ុនម៉ៅការសាងសង់ និងទីប្រឹក្សាគ្រប់គ្រងបរិស្ថាន រួចបញ្ជូនរបាយការណ៍ប្រចាំត្រីមាសទៅកាន់ PCU នៅក្រសួងទេសចរណ៍។ ចំណុចសំខាន់បំផុតគឺត្រូវធានាថា ទីប្រឹក្សាគ្រប់គ្រងបរិស្ថាន និងបញ្ជូនរបាយការណ៍ប្រចាំត្រីមាសទៅកាន់អង្គភាពសម្របសម្រួលគម្រោង នៅក្រសួងទេសចរណ៍។ អ្វីដែលសំខាន់ គឺត្រូវធានាថាទីប្រឹក្សាគ្រប់គ្រងបរិស្ថាន មានសមត្ថភាពផ្នែកបច្ចេកទេស ធនធាន និងឯករាជ្យភាពក្នុងការតាមដាន និងរាយការណ៍រាល់ការបំពុលបរិស្ថាននានា។ គម្រោងនេះនឹងអនុវត្តនូវបទដ្ឋានបរិស្ថានកម្ពុជា ដូចបានចែងក្នុងអនុក្រឹត្យរបស់រដ្ឋាភិបាលស្តីពី ការគ្រប់គ្រងការបំពុលទឹក ឆ្នាំ១៩៩៩ និងអនុវត្តនូវគោលការណ៍ណែនាំស្តីពីសុវត្ថិភាព សុខភាព និងបរិស្ថាន របស់ IFC/ធនាគារពិភពលោក ឆ្នាំ២០០៧ ដោយសារតែការខកខាននូវបទដ្ឋានថ្នាក់ជាតិដែលពាក់ព័ន្ធ។

EMP ទទួលស្គាល់ថា "បច្ចុប្បន្ន ពុំសូវមានអ្នកជំនាញការក្នុងស្រុកដែលមានបទពិសោធន៍ និងសមត្ថភាពដើម្បីវាយតម្លៃ និងគ្រប់គ្រងបរិស្ថាន ដើម្បីអនុវត្តផែនការតាមដានបរិស្ថាននោះទេ"។[52] EMP ស្នើឡើងថាទីប្រឹក្សាផ្នែកគ្រប់គ្រង និងគូរប្លង់លម្អិត នឹងកំណត់តម្រូវការផ្នែកបណ្តុះបណ្តាល និងរៀបចំ

[52] ទំព័រ ២៦ ក្នុង "ផែនការតាមដានបរិស្ថាន" របស់ ADB ខែមីនា ឆ្នាំ២០១៤។

វគ្គបណ្តុះបណ្តាលទៅសមាជិក PIU (បុគ្គលិកក្នុងមន្ទីរទេសចរណ៍)។ ខណៈដែលវគ្គបណ្តុះបណ្តាលនេះ អាចជួយបន្ថែមចំណេះដឹងផ្នែកបច្ចេកទេសក៏ដោយ ប៉ុន្តែប្រសិទ្ធភាពគ្រប់គ្រងរបស់ PIU ក៏ត្រូវអាស្រ័យលើឆន្ទៈរបស់ PIU និង PCU ផងដែរ ក្នុងការចាត់វិធានការ នៅពេលដែលមានភស្តុតាងបង្ហាញពីផលប៉ះពាល់ផ្នែកបរិស្ថាន។ ទោះបីជា EMP មានផែនការតាមដានលម្អិតក៏ដោយ ក៏ EMP មិនបានបញ្ជាក់ពីវិធានការជាក់លាក់ក្នុងការ ឆ្លើយតប ឬដោះស្រាយ ប្រសិនបើក្នុងរបាយការណ៍ប្រចាំត្រីមាស មានភស្តុតាងបង្ហាញពីផលប៉ះពាល់បរិស្ថាននោះទេ។ ចំណុចនេះគួរតែលើកឡើងក្នុងផែនការតាមដានបរិស្ថានដែលបានកែសម្រួល ដែលនឹងបញ្ជូនទៅកាន់ក្រសួងបរិស្ថានដើម្បីអនុម័ត។

ក្នុងច្បាប់ជាតិកម្ពុជា ទំនួលខុសត្រូវខ្ពស់បំផុត ដើម្បីធានាថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានអនុវត្ត ជាទំនួលខុសត្រូវរបស់ក្រសួងបរិស្ថាន។ មន្ទីរបរិស្ថានខេត្តកំពត ទទួលស្គាល់ថា នោះគឺជាទំនួលខុសត្រូវរបស់ពួកគេ ក្នុងការអនុវត្ត ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ទោះបីជាមានការខ្វះខាតធនធានមនុស្ស ឬធនធានថវិកា ដើម្បីពិនិត្យគុណភាពទឹកដោយខ្លួនឯង។[53] មន្ទីរ នឹងស្នើសុំជំនួយផ្នែកជំនាញការ ពីក្រសួងបរិស្ថាន ដើម្បីរៀបចំធ្វើតេស្តដោយខ្លួនឯង។ ដោយសារទីប្រឹក្សាគ្រប់គ្រងបរិស្ថាន រាយការណ៍ទៅ អង្គភាពអនុវត្តគម្រោង និងអង្គភាពសម្របសម្រួលគម្រោង នៅក្រសួងទេសចរណ៍ ដូច្នេះមានតែក្រសួងបរិស្ថានប៉ុណ្ណោះ ដែលអាចធ្វើការគ្រប់គ្រងដោយឯករាជ្យ មកលើផលប៉ះពាល់នៃគម្រោង។ EMP បញ្ជាក់ថា របាយការណ៍របស់អង្គភាពអនុវត្តគម្រោង ដែលផ្ញើទៅអង្គភាពសម្របសម្រួលគម្រោង នឹងត្រូវបានចែករំលែកទៅមន្ទីរបរិស្ថាន។ ការធ្វើបែបនេះ នឹងជួយដល់ក្រសួងបរិស្ថានក្នុងការអនុវត្តតួនាទីមើលការខុសត្រូវរបស់ខ្លួន។

**កំណត់សម្គាល់លើទិន្នន័យមូលដ្ឋាន**

ទិន្នន័យមូលដ្ឋាន ស្តីពីសូចនាករវាស់វែងបរិស្ថាន ក្នុងឆកសមុទ្រកំពត ដែលអាចរកបានជាសាធារណៈមានតិចតួចណាស់។ មន្ទីរបរិស្ថានមិនបានតាមដានគុណភាពទឹក និងប្រព័ន្ធអេកូឡូស៊ី ក្នុងតំបន់ឆកសមុទ្រកំពតឲ្យបានទៀងទាត់នោះទេ។ មន្ទីរបានទទួលការគាំទ្រពី ដានីដា ភ្នាក់ងារអភិវឌ្ឍន៍ដាណេម៉ាក ដើម្បីផលិតរបាយការណ៍ "ស្ថានភាពបរិស្ថាន" ក្នុងឆ្នាំ២០០៩ ដែលត្រូវបានយោង ក្នុងផែនការតាមដានបរិស្ថាន។ ក្រសួងបរិស្ថាន បានបោះពុម្ពផ្សាយ "ស្ថានភាពបរិស្ថាននៅតាមបណ្តោយឆ្នេរ និងស្ថានភាពសង្គមសេដ្ឋកិច្ចនៅកម្ពុជា" ក្នុងខែកញ្ញា ឆ្នាំ២០០៥ និង "ស្ថានភាពនៃរបាយការណ៍បរិស្ថាន ៖ ខេត្តកំពត" ក្នុងខែមេសា ឆ្នាំ២០០២។ ការតាមដានជាទៀងទាត់ ត្រូវបានអនុវត្តនៅពេលរៀបចំ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងផ្សេងៗ។ ទិន្នន័យថ្មីៗបំផុត មានក្នុងរបាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ២០១១។ ក្រុមការងារស្រាវជ្រាវ ពុំអាចស្វែងរកនូវរបាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងគម្រោងផ្សេងៗ ក្នុងឆកសមុទ្រកំពតនោះទេ និងគ្មានព័ត៌មានសាធារណៈថាមានការវាយតម្លៃហេតុប៉ះពាល់ ប៉ុន្មានដែលត្រូវបានធ្វើឡើងនោះដែរ។ បច្ចុប្បន្ន ទិន្នន័យបរិស្ថានដ៏ល្អបំផុត ដែលអាចរកបានគឺមានក្នុង របាយការណ៍ សហជីពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ ស្តីពីគម្របស្មៅសមុទ្រក្នុងខេត្តកំពត ដែលផលិតរួមជាមួយនឹង មន្ទីរបរិស្ថាន និងរដ្ឋបាលជលផល។

[53] កិច្ចសម្ភាសន៍ជាមួយមន្ទីរបរិស្ថាន ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៦។

**អនុសាសន៍ ៖**

**ក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍ ៖**

- ធានាថាវិធានការកាត់បន្ថយដែលលើកឡើងក្នុង ផែនការតាមដានបរិស្ថាន/ការវាយតម្លៃផលប៉ះពាល់បរិស្ថាន សម្រាប់គម្រោងកំពង់ផែកំពត គឺគ្រប់គ្រាន់ដើម្បីការពារផលប៉ះពាល់ធ្ងន់ធ្ងរ មកលើជីវភាពអ្នកនេសាទក្នុងឆកសមុទ្រកំពត។
- តាមដានឲ្យម៉ត់ចត់ និងធានាការអនុវត្តឲ្យបានត្រឹមត្រូវ នូវវិធានការកាត់បន្ថយ ដែលបានកំណត់ក្នុង ផែនការតាមដានបរិស្ថាន/ការវាយតម្លៃផលប៉ះពាល់បរិស្ថាន។
- រួមបញ្ចូលសេចក្ដីណែនាំ ក្នុងការវាយតម្លៃផលប៉ះពាល់បរិស្ថាន នូវសកម្មភាពដែលត្រូវអនុវត្តដោយ អង្គភាពអនុវត្តគម្រោង និងអង្គភាពសម្របសម្រួលគម្រោង ប្រសិនបើមានភស្តុតាងស្ដីពីការបំផ្លិចបំផ្លាញបរិស្ថាន។
- ប្រសិនបើការជីក ឬពង្រីកឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូ យល់ឃើញថាចាំបាច់ដើម្បីសម្របសម្រួលឲ្យទូកបើកចូលទៅកាន់កំពង់ផែថ្មីនាពេលអនាគត ត្រូវតែរៀបចំការសិក្សាលម្អិត និងកិច្ចពិគ្រោះយោបល់ឲ្យបានពេញលេញជាមួយប្រជាពលរដ្ឋដែលនឹងរងផលប៉ះពាល់។
- ធានាថាផែនការគ្រប់គ្រងនាវាចរណ៍ អនុញ្ញាតឲ្យអ្នកនេសាទប្រើប្រាស់ផ្លូវទឹកដោយមិនធ្វើឲ្យធនធានជលផលធ្លាក់ចុះ។
- ធានាថាអ្នកនេសាទ ដែលប្រើប្រាស់ផ្លូវទឹក មានតំណាងក្នុងគណៈកម្មាធិការ បង្កើតផែនការគ្រប់គ្រងនាវាចរណ៍ ដើម្បីឲ្យពួកគេអាចការពារផលប្រយោជន៍របស់ខ្លួនបាន។
- បញ្ចូលព័ត៌មាននៅក្នុងរបាយការណ៍ទៅភាគីពាក់ព័ន្ធ ជាសូចនាកវាស់វែងតាមដានការអនុវត្តការងារ ហើយគួរតែដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំត្រីមាស ក្នុងអង្គភាពអនុវត្តគម្រោង។
- ដាក់របាយការណ៍តាមដានផ្នែកបរិស្ថាន រួមទាំង ទិន្នន័យមូលដ្ឋានដែលប្រមូលបានដោយទីប្រឹក្សាគ្រប់គ្រងបរិស្ថាន ទៅក្រសួងបរិស្ថាន ដូចបាន ដាក់ស្នើក្នុងផែនការតាមដានបរិស្ថាន/ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**ក្រសួងបរិស្ថាន និងមន្ទីរបរិស្ថាន**

- ដាក់របាយការណ៍ទិន្នន័យបរិស្ថានក្នុងឆកសមុទ្រកំពត រួមទាំង ការវាយតម្លៃផលប៉ះពាល់បរិស្ថានពាក់ព័ន្ធនឹងគម្រោងក្នុងឆកសមុទ្រ ជាសាធារណៈ។
- ធានាថាការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថានត្រូវបានតាមដានឲ្យបានម៉ត់ចត់ និងធានាការអនុវត្តឲ្យបានត្រឹមត្រូវ។
- ធានាថាមានធនធានគ្រប់គ្រាន់ ចែកចាយជាមួយមន្ទីរបរិស្ថាន ដើម្បីឲ្យមន្ទីរ មានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលជលផល ក្នុងការប្រមូលព័ត៌មានឲ្យបានទៀងទាត់ស្ដីពីសូចនាករវាស់

វែងបរិស្ថាន ដូចជាគុណភាពទឹក និងការលាតសន្ធឹង និងគុណភាពនៃគម្របស្មៅសមុទ្រ និងព្រៃកោងកាង។

- ធានាថាមានធនធានគ្រប់គ្រាន់ ចែកចាយជាមួយមន្ទីរបរិស្ថាន ដើម្បីអាចតាមដានឲ្យបានគ្រប់ជ្រុងជ្រោយ ស្តីពីការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩)។

## ជំពូក ៥ ៖ កិច្ចពិគ្រោះយោបល់

> *"ពួកគេបានសន្យាថាប្រជាពលរដ្ឋនឹងមានការងារធ្វើ។ ប៉ុន្តែបើមិនមានចំណេះដឹងផង មានអ្នកណាជួលពួកគាត់? យើងចង់ដឹងឲ្យច្បាស់ថា គេនឹងធ្វើអ្វី ហើយប៉ះពាល់ដល់សហគមន៍បែបណា និងប៉ះពាល់ដល់ត្រីបែបណា។ បើមានផលប៉ះពាល់ដល់ធនធានសមុទ្រ គួរតែមានការពិគ្រោះយោបល់ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ។"*
>
> *គណៈកម្មធិការសហគមន៍នេសាទត្រពាំងសង្កែ។*[54]

### ការពិគ្រោះយោបល់កន្លងមក

ដើម្បីរៀបចំការសិក្សាបរិស្ថានបឋម (IEE) និងផែនការតាមដានបរិស្ថាន (EMP) ទីប្រឹក្សាដែលជួលដោយក្រសួងទេសចរណ៍ បានរៀបចំកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដែលនឹងអាចទទួលរងផលប៉ះពាល់។ ក្នុង IEE បញ្ជាក់ថា "យុទ្ធសាស្ត្រក្នុងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ក្នុងអំឡុងពេលរៀបចំគម្រោង បានបញ្ចូលគោលការណ៍ការធ្វើការរួមគ្នាដ៏មានអត្ថន័យ តម្លាភាព ការចូលរួម និងរួមបញ្ចូលមនុស្សទាំងអស់ដោយមិនរើសអើង ដើម្បីធានាថាក្រុមដែលប៉ះពាល់ និងក្រុមដែលងាយរងគ្រោះ ដូចជាស្ត្រី និងជនក្រីក្រត្រូវបានផ្តល់ឱកាសយ៉ាងស្មើភាពក្នុងការចូលរួមតាក់តែងគម្រោង"។[55] ក្នុងឯកសារបានបញ្ជាក់ថា បានសម្ភាសន៍ជាមួយប្រធានភូមិ និងគ្រួសារនៅក្នុងសហគមន៍ដែលប៉ះពាល់រួមទាំង "ក្រុមងាយរងគ្រោះ និង/ឬក្រុមភាគតិច ដែលចាប់អារម្មណ៍ចង់ចូលរួមក្នុងការកំណត់ និងអនុវត្តវិធានការដែលគាំទ្រ និងលើកកម្ពស់ការចូលរួមរបស់ពួកគេនៅក្នុងគម្រោង"។[56] ពួកគេត្រូវបានសំណូមពរឲ្យកំណត់ពីផលប្រយោជន៍ដែលនឹងបានពីគម្រោង និងបង្ហាញពីការព្រួយបារម្ភពីហេតុប៉ះពាល់បរិស្ថាន ដែលពួកគេគិតឃើញ ទាំងក្នុងដំណាក់កាលសាងសង់ និងដំណាក់កាលដាក់ឲ្យប្រើប្រាស់ ព្រមទាំងស្នើវិធានការសម្រាលផលប៉ះពាល់។

តាមរយៈព័ត៌មានដែលផ្តល់ដោយ ADB ទីប្រឹក្សាបានសម្ភាសន៍ប្រជាពលរដ្ឋនៅភូមិជុំគ្រៀល ឃុំជុំគ្រៀល ចំនួន ២៧ នាក់ និងប្រជាពលរដ្ឋ ៧៣ នាក់ នៅភូមិសុវណ្ណសាគរ ឃុំកំពង់កណ្តាល ស្រុកកំពតក្នុងឆ្នាំ ២០១៣ និង២០១៤។ ពុំមានការផ្តល់ព័ត៌មានលម្អិតស្តីពី ភេទ ឬសញ្ជាតិ ឬ អត្តសញ្ញាណរបស់អ្នកដែលចូលរួមសម្ភាសនោះទេ។ទីប្រឹក្សាក៏បានរៀបចំកិច្ចប្រជុំជាមួយមន្ត្រីរដ្ឋាភិបាលផងដែរ។[57]

---

[54] កិច្ចពិភាក្សាជាមួយគណៈកម្មាធិការសហគមន៍នេសាទត្រពាំងសង្កែ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦។

[55] ទំព័រ ២៤ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

[56] ទំព័រ ២៥ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

[57] អ៊ីមែលពីបុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំប្រទេសកម្ពុជា ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦។

ក្នុងកិច្ចប្រជុំនៅខែកញ្ញា ឆ្នាំ២០១៦ ក្រសួងទេសចរណ៍បានប្រាប់ក្រុមអ្នកស្រាវជ្រាវថា មានកិច្ចប្រជុំមួយចំនួនរួចមកហើយជាមួយសមាជិកសហគមន៍ និងប្រធានសហគមន៍ក្នុងខេត្តកំពត ប៉ុន្តែក្រសួងមិនបានផ្តល់ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋដែលបានពិគ្រោះយោបល់ និងកាលបរិច្ឆេទនៃកិច្ចប្រជុំទាំងនេះនោះទេ។

ក្រុមស្រាវជ្រាវសម្ភាសន៍អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំត្រពាំងសង្កែ និងឃុំកូនសត្វ ដើម្បីវាយតម្លៃពីការយល់ដឹងអំពីគម្រោង និងស្វែងរកព័ត៌មានពីកិច្ចពិគ្រោះយោបល់ដែលពួកគាត់ធ្លាប់បានចូលរួម។ ប្រធានក្រុមប្រឹក្សាឃុំមួយចំនួន ប្រធានភូមិម្នាក់ និងសមាជិកគណៈកម្មាធិការសហគមន៍នេសាទ បាននិយាយថា ពួកគេបានចូលរួមកិច្ចប្រជុំមួយ ដែលរៀបចំដោយអាជ្ញាធរខេត្តកំពតក្នុង ឆ្នាំ២០១៤។ នៅក្នុងកិច្ចប្រជុំនោះ អាជ្ញាធរខេត្តបានបង្ហាញពីផែនការសម្រាប់ការអភិវឌ្ឍន៍ដ៏ធំមួយឈ្មោះថា "ក្រុងកំពតថ្មី" (សូមអានជំពូក ៦) និងផ្នែកមួយនៃផែនការនោះគឺ គម្រោងកំពង់ផែទេសចរណ៍កំពត។ នៅក្នុងកិច្ចប្រជុំ អ្នកចូលរួមមិនបានទទួលឯកសារ ឬត្រូវបានសុំមតិយោបល់ ឬក៏ស្នើសុំឲ្យទៅសុំមតិយោបល់ពីសមាជិកសហគមន៍នោះទេ។

នៅខែសីហា ឆ្នាំ២០១៦ បុគ្គលិកក្រសួងទេសចរណ៍បានជួបជាមួយមន្ត្រីមកពីមន្ទីរផ្សេងៗក្នុងក្រុងកំពត ដើម្បីពិភាក្សាពីការគូរប្លង់លម្អិត។ ទីប្រឹក្សាអន្តរជាតិ ក៏បានជួបអាជ្ញាធរមូលដ្ឋាននៅឃុំជុំគ្រៀល ដើម្បីពិភាក្សាពីប្លង់កំពង់ផែលម្អិត និងទៅមើលទីតាំងកំពង់ផែផងដែរ។

ក្រុមស្រាវជ្រាវមិនអាចរកភស្តុតាងដែលបង្ហាញថាអ្នកនេសាទនៅឃុំត្រពាំងសង្កែ និងឃុំកូនសត្វ បានចូលរួមកិច្ចពិគ្រោះយោបល់ក្នុងអំឡុងពេលតាក់តែងគម្រោងនោះទេ។ ប្រធានក្រុមប្រឹក្សាឃុំទាំងពីរបានបញ្ជាក់ប្រាប់ក្រុមស្រាវជ្រាវថា គម្រោងកំពង់ផែនឹងមិនប៉ះពាល់ដល់ប្រជាពលរដ្ឋនៅក្នុងឃុំរបស់ពួកគេទេ ព្រោះទីតាំងគម្រោងស្ថិតនៅក្នុងឃុំជុំគ្រៀល។ បើទោះបីជាពុំមានការប៉ះពាល់លើសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋក៏ដោយ អ្នកនេសាទនៅក្នុងឃុំទាំងនេះពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅជុំវិញទីតាំងគម្រោងដើម្បីជីវភាពរបស់ពួកគេ ហើយពួកគេមានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តទាំងឡាយដែលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។ អ្នកទទួលខុសត្រូវលើគម្រោងគួរធានាថាមានការចូលរួមយ៉ាងពេញលេញពីអ្នកដែលអាចនឹងរងផលប៉ះពាល់ ក្នុងអំឡុងពេលតាក់តែងគម្រោង និងគ្រប់ដំណាក់កាលនៃការសាងសង់គម្រោង។

### ផែនការពិគ្រោះយោបល់បន្ថែមទៀត

EMP បានបញ្ជាក់ថានឹងមានការពិគ្រោះយោបល់បន្ថែមទៀតក្នុងដំណាក់កាលមុនការសាងសង់គម្រោង។ ជំហានដំបូងគឺការបង្ហាញពី IEE ទៅកាន់ដៃគូពាក់ព័ន្ធ និងត្រលប់មកពិគ្រោះយោបល់ម្តងទៀតជាមួយអ្នកដែលបានចូលរួមក្នុងកិច្ចពិភាក្សាលើកទីមួយ ដើម្បីកែសម្រួល EMP។ ទោះបីជានៅក្នុង IEE

បញ្ជាក់ថាសេចក្តីសង្ខេប គួរតែត្រូវបកប្រែជាភាសាខ្មែរ និងចែកចាយទៅអ្នកដែលរងផលប៉ះពាល់ទាំងអស់ក៏ដោយ តែជាក់ស្តែងពុំមានការចែកចាយឯកសារនេះទេ។ IEE និង "របាយការណ៍គម្រោងទាំងអស់ ដែលមានភ្ជាប់ឯកសារយោងដាក់លាក់ពីកំណត់ត្រាការពិគ្រោះយោបល់ ការតាមដានបរិស្ថាន និងរបាយការណ៍ការអនុវត្ត EMP" គួរតែអាចស្វែងរកបាននៅការិយាល័យក្រសួង និងមន្ទីរទេសចរណ៍ លើគេហទំព័រ សាលាស្រុក និងនៅក្នុងទីតាំងគម្រោង។ ក្នុងពេលបច្ចុប្បន្ន IEE មានដាក់បង្ហាញជាសាធារណៈនៅលើគេហទំព័រ របស់ ADB តែមួយប៉ុណ្ណោះ។

ទីប្រឹក្សាតាមដានបរិស្ថាន នឹងត្រូវរៀបចំកិច្ចពិគ្រោះយោបល់ជាមួយសហគមន៍ ដើម្បីប្រមូលទិន្នន័យបឋមស្តីពីបរិស្ថាន។ តំលៃប៉ាន់ស្មាន នៃការតាមដានបរិស្ថានគឺប្រមាណ ៣,០០០ ដុល្លារអាមេរិក សម្រាប់ការប្រមូលព័ត៌មានអំពី "ការទទួលដឹងពីវប្បធម៌" ក្នុងដំណាក់កាលមុនសាងសង់ និងតម្លៃបន្ថែម ២,០០០ ដុល្លារអាមេរិក សម្រាប់រៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈអំឡុងពេលសាងសង់។ ក្រសួងទេសចរណ៍បានប្រាប់ក្រុមអ្នកស្រាវជ្រាវសម្រាប់របាយការណ៍នេះថា ការពិគ្រោះយោបល់បន្ថែមទៀតត្រូវបានដាក់ក្នុងផែនការរួចហើយ តែមិនបានផ្តល់ព័ត៌មានបន្ថែមទៀតនោះទេ។

អ្វីដែលសំខាន់នោះគឺ អ្នកនេសាទនៅឃុំត្រពាំងសង្កែ និងឃុំកូនសត្វ និងអ្នកផ្សេងៗ ទៀតដែលសិទ្ធិរបស់ពួកគេនឹងរងប៉ះពាល់ដោយសារគម្រោង អាចចូលរួមក្នុងកិច្ចពិគ្រោះយោបល់ដោយពេញលេញ។ ប្រជាពលរដ្ឋគួរតែបានទទួលព័ត៌មានស្តីពីគោលបំណង និងព័ត៌មានពេញលេញឲ្យទាន់ពេលវេលា និងតាមវិធីសាស្ត្រដែលអាចទទួលព័ត៌មានបានដោយងាយស្រួលបំផុត។ ប្រជាពលរដ្ឋគួរមានឱកាសពិចារណាពីព័ត៌មាននេះ និងផ្តល់យោបល់ពាក់ព័ន្ធនឹងសំណើសាងសង់ ដែលគួរត្រូវបានពិចារណា និងឆ្លុះបញ្ចាំងក្នុងការតាក់តែងគម្រោង ឬក៏បានដោះស្រាយដោយត្រឹមត្រូវ។ កិច្ចពិគ្រោះយោបល់គួរតែដាក់បញ្ចូលជំហានមួយចំនួនដែលអាចឲ្យស្ត្រី និងក្រុមភាគតិចអាចចូលរួមដោយពេញលេញ។

កិច្ចពិគ្រោះយោបល់គួរតែផ្អែកលើគោលការណ៍យល់ព្រមដោយសេរី និងដោយមានការប្រាប់ឲ្យដឹងជាមុន។ "សេរី" ក្នុងបរិបទនេះមានន័យថា ការព្រមព្រៀងដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ គ្មានការបំផិតបំភ័យ និងគ្មានឧបាយកល។ ពេលវេលានៃដំណើរការ និងរចនាសម្ព័ន្ធនៃការសម្រេចចិត្ត គួរតែយោងតាមការសម្រេចរបស់ម្ចាស់សិទ្ធិ។ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិចូលរួមដោយសេរី ដោយមិនប្រកាន់យេនឌ័រ អាយុ ឬអត្តសញ្ញាណផ្សេងទៀតឡើយ។ "ជាមុន" មានន័យថា ការសុំការយល់ព្រមនោះគឺធ្វើឡើងជាមុន មុនពេលការអនុម័ត ឬចាប់ផ្តើមសកម្មភាព គឺនៅដំណាក់កាលដំបូងនៃផែនការអភិវឌ្ឍន៍។ ការកំណត់ពេលវេលាគួរតែឆ្លុះបញ្ចាំង រយៈពេលដែលចាំបាច់ដើម្បីស្វែងយល់ព័ត៌មាន ទទួលបានព័ត៌មាន និងវិភាគព័ត៌មាន ចំពោះសកម្មភាពដែលបានស្នើ រួចធ្វើការសម្រេចចិត្ត។ "ប្រាប់ឲ្យដឹង" មានន័យថាព័ត៌មានគួរតែមិនលម្អៀង ពេញលេញ អាចស្វែងរកបាន និងត្រូវបានផ្តល់ឲ្យជាបន្តបន្ទាប់ក្នុងរាល់ដំណាក់កាលនៃគម្រោង។ "ការព្រមព្រៀង" មានន័យថាការសម្រេចចិត្តរួម ថាតើគួរ

ទទួល ឬមិនទទួលយកសំណើ ប្រសិនបើការព្រមព្រៀងនោះអាចត្រូវបានផ្តល់ដោយភ្ជាប់លក្ខខណ្ឌ និងអាចដកហូតវិញនៅពេលក្រោយ។[58]

## ការយល់ឃើញរបស់អ្នកភូមិនៅឃុំត្រពាំងសង្កែ និងឃុំកូនសត្វ

អ្នកចូលរួមសម្ភាសន៍ខ្លះ ធ្លាប់ឮពាក្យចចាមអារ៉ាមពីគម្រោងកំពង់ផែទេសចរណ៍កំពត ឬធ្លាប់ឃើញផ្លាកផ្សព្វផ្សាយបង្ហាញពីគម្រោងនៅលើផ្លូវជាតិលេខ ៣៣។ មនុស្សភាគច្រើន ទើបនឹងបានដឹងពីគម្រោងជាលើកទីមួយ ក្នុងពេលសម្ភាសន៍ជាមួយក្រុមការងារស្រាវជ្រាវនេះ។ នៅពេលដែលក្រុមស្រាវជ្រាវបានសួរប្រជាពលរដ្ឋអំពីគម្រោងកំពង់ផែទេសចរណ៍កំពត អ្នកចូលរួមសម្ភាសន៍ស្ទើរតែទាំងអស់មើលឃើញពីអត្ថប្រយោជន៍នៃគម្រោង។ ពួកគេកត់សម្គាល់ថា កំពង់ផែអាចបង្កើតការងារ ទាក់ទាញភ្ញៀវទេសចរណ៍ ឲ្យមកចាយលុយបង្កើនសេដ្ឋកិច្ចក្នុងស្រុក និងអាចបង្កើនតម្រូវការសម្រាប់គម្រោងអេកូទេសចរណ៍ផ្សេងៗទៀតនាពេលអនាគតក្នុងសហគមន៍។ ទន្ទឹមនឹងនោះ អ្នកខ្លះមានមន្ទិលសង្ស័យថា តើផលប្រយោជន៍ទាំងនេះអាចនឹងមកដល់ពួកគេដោយផ្ទាល់ឬយ៉ាងណា។ ប្រជាពលរដ្ឋខ្លះបានកត់សម្គាល់ថា ពួកគេ និង ប្រជាពលរដ្ឋភាគច្រើនក្នុងឃុំមិនបានទទួលការអប់រំឲ្យបានជ្រៅជ្រះ ហើយប្រហែលជាមិនអាចប្រកួតប្រជែងដណ្តើមការងារដែលកំពង់ផែបង្កើតនោះទេ។

អ្នកដែលត្រូវបានសម្ភាសស្ទើរតែទាំងអស់ បានលើកឡើងពីកង្វល់អំពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានពីគម្រោង ទោះបីជាពួកគេពុំមានព័ត៌មានគ្រប់គ្រាន់ពីគម្រោងដើម្បីធ្វើការសម្រេចចិត្តប្រកបដោយការពិចារណាក៏ដោយ។ ការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ជាទូទៅ ផ្អែកលើបទពិសោធន៍របស់ពួកគេ ក្នុងការអភិវឌ្ឍន៍ផ្សេងទៀតក្នុងតំបន់ឆកសមុទ្រកំពត (សូមអានជំពូក ៦)។ សំនួរមួយចំនួនដែលលើកឡើងដោយប្រធានភូមិម្នាក់ក្នុងឃុំកូនសត្វជាបញ្ហាដែលត្រូវបានលើកឡើងជាទូទៅ ៖

> *“ខ្ញុំចង់ដឹងថាតើគម្រោងនោះពិតជាធ្វើឡើងក្នុងទំហំដីប្ដូរហិកតាមែនឬយ៉ាងណា។ តើវានឹងប៉ះពាល់សហគមន៍នេសាទ និងប្រជាពលរដ្ឋដែលពឹងផ្អែកលើការនេសាទដែរឬទេ? តើនឹងមានការបូមខ្សាច់ទៀតទេ? ប្រជាពលរដ្ឋអាចបាត់បង់ការងារ ព្រោះពួកគេមិនអាចនេសាទតទៅទៀត។ ពួកគេប្រហែលជានាំអ្នកជំនាញមកធ្វើការ ដូច្នេះប្រជាពលរដ្ឋនៅទីនេះមិនអាចរកការងារធ្វើបាន។ ប្រសិនបើទីតាំងនោះត្រូវអភិវឌ្ឍ នោះនឹងមានគម្រោងថ្មីកើតឡើងបន្តៗទៀត ដែលអាចនឹងប៉ះពាល់ដល់សហគមន៍។ ផ្លូវទឹកឆ្លងកាត់តំបន់នោះអាចនឹងត្រូវបិទ។ ប្រសិនបើគេបិទផ្លូវទឹកសម្រាប់នាវាដឹកអ្នកដំណើរ នោះប្រជាពលរដ្ឋមិនអាចនេសាទបានទេ”*[59]

[58] សូមអានជាឧទាហរណ៍កម្មវិធី UN REDD “គោលការណ៍ការយល់ព្រមដោយសេរី និងដោយមានការប្រាប់ឲ្យដឹងជាមុន (FPIC)” ខែមករា ឆ្នាំ២០១៣។ អាចរកបាន ៖ http://www.uncclearn.org/sites/default/files/inventory/un-redd05.pdf.

[59] កិច្ចសម្ភាសន៍ជាមួយមេភូមិ ក្នុងឃុំកូនសត្វ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦។

បញ្ហាទាំងនេះត្រូវបានពិចារណាក្នុងការតាក់តែងគម្រោង ហើយកង្វល់របស់ប្រជាពលរដ្ឋជាច្រើនអាចត្រូវបានដោះស្រាយតាមរយៈការពិគ្រោះយោបល់បន្ថែមទៀត។

ក្រុមអ្នកស្រាវជ្រាវសួរប្រជាពលរដ្ឋ ថាតើពួកគាត់ចង់ឲ្យមានការពិគ្រោះយោបល់ពីគម្រោងតាមរបៀបណា។ អ្នកខ្លះស្នើឲ្យប្រើរចនាសម្ព័ន្ធដែលមានស្រាប់ ដូចជាប្រធានភូមិ និងប្រធានក្រុមប្រឹក្សាឃុំដើម្បីចែករំលែកព័ត៌មាន។ ប្រជាពលរដ្ឋម្នាក់បានលើកឡើងថា គណៈកម្មធិការសហគមន៍នេសាទ គួរតែក្លាយទៅជាទីតាំងរួមមួយសម្រាប់ផ្តល់ព័ត៌មានដល់អ្នកដែលអាចរងផលប៉ះពាល់ខ្លាំង។ ប្រជាពលរដ្ឋម្នាក់ទៀតបានស្នើឲ្យប្រើបណ្តាញសង្គមដើម្បីចែករំលែកព័ត៌មានពីគម្រោង ឬទទួលយោបល់ និងបណ្តឹងរបស់ប្រជាពលរដ្ឋ។ ប្រធានភូមិមកពីឃុំកូនសត្វស្នើឲ្យមានការរៀបចំវេទិកាសាធារណៈដែលអាច "ផ្តល់ព័ត៌មានលម្អិត និងអាចឲ្យពួកយើងលើកឡើងពីការព្រួយបារម្ភទាំងឡាយ ហើយពួកគេគួរតែឆ្លើយទៅនឹងការព្រួយបារម្ភរបស់យើងបន្ទាប់ពីវេទិកាសាធារណៈ"។[60]

## របាយការណ៍ និងបណ្តឹង

គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស គូសបញ្ជាក់ថាការផ្តល់ព័ត៌មានអំពីរបៀបដោះស្រាយផលប៉ះពាល់ ជាដំណើរការបន្តបន្ទាប់ ហើយព័ត៌មានដែលត្រូវផ្តល់ឲ្យនោះគួរតែ "គ្រប់គ្រាន់ក្នុងការវាយតម្លៃភាពសមស្របនៃការឆ្លើយតបរបស់សហគ្រាស ចំពោះផលប៉ះពាល់មកលើសិទ្ធិមនុស្សដែលពាក់ព័ន្ធ"។[61] EMP បញ្ជាក់ថារបាយការណ៍ "គួរតែត្រូវរៀបចំឡើង ដោយអមនឹងកិច្ចប្រជុំជាទៀងទាត់ជាមួយដៃគូពាក់ព័ន្ធ ដែលជាផ្នែកមួយនៃការបន្តទំនាក់ទំនងរវាងដៃគូពាក់ព័ន្ធ"។[62] កិច្ចប្រជុំទាំងនេះជាទំនួលខុសត្រូវរបស់អ្នកជំនាញការពារសុវត្ថិភាព ក្នុង PIU ។[63] EMP ដែលមានស្រាប់ មិនបានបង្ហាញឲ្យច្បាស់ថា តើកិច្ចប្រជុំទាំងនេះត្រូវធ្វើឡើងឲ្យបានទៀងទាត់កម្រិតណា តើគួរផ្តល់ព័ត៌មានអ្វីខ្លះ ឬថាតើអ្នកណាខ្លះដែលគួរតែចាត់ចូលជាដៃគូពាក់ព័ន្ធ ទោះបីជាក្នុងផែនការនេះបានរួមបញ្ចូលប្រជាពលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ។ ថ្វីបើនឹងមាន កិច្ចពិគ្រោះយោបល់បន្ថែមទៀតដើម្បីពិនិត្យមើល EMP សាជាថ្មី ត្រូវបានដាក់បញ្ចូលជា 'សូចនាករត្រួតពិនិត្យការអនុវត្ត' អំឡុងពេលមុនដំណាក់កាលសាងសង់ ប៉ុន្តែពុំមានសូចនាករនៃការរាយការណ៍ទៅកាន់ដៃគូពាក់ព័ន្ធក្នុងអំឡុងពេលសាងសង់នោះទេ។ អំឡុងពេលអនុវត្តគម្រោង "ទាំងរបាយការណ៍បរិស្ថាន និងរបាយការណ៍ EMP ដែលទទួលបានមកពី EA/PCU នឹងមានដាក់លើវែបសាយគម្រោង និងវែបសាយរបស់ ADB"។[64]

[60] កិច្ចសម្ភាសន៍ជាមួយមេភូមិ ក្នុងឃុំកូនសត្វ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៦។

[61] គោលការណ៍ណែនែ លេខ ១៧(គ) និង ២១ (ខ) ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស "គោលការណ៍ណែនាំ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស" ឆ្នាំ២០១១។

[62] ទំព័រ ១៧ ក្នុង "ផែនការតាមដានបរិស្ថាន" របស់ ADB ខែមីនា ឆ្នាំ២០១៤។

[63] ទំព័រ ៣ ក្នុង "ផែនការតាមដានបរិស្ថាន" របស់ ADB ខែមីនា ឆ្នាំ២០១៤។

[64] ទំព័រ ៤៤ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

អំឡុងពេលមុនដំណាក់កាលសាងសង់គម្រោង នឹងមានការផ្សព្វផ្សាយពីយន្តការបណ្តឹង ទៅកាន់ដៃគូដែលពាក់ព័ន្ធតាមរយៈការធ្វើយុទ្ធនាការព័ត៌មានសាធារណៈ។[65] យន្តការនេះនឹងអាចឲ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់ "ដាក់ពាក្យបណ្តឹងទាក់ទងនឹងបញ្ហាដែលពួកគេគិតថាអាចនឹងកើតមាន ដែលអាចប៉ះពាល់ដល់បរិស្ថាន ឬទាក់ទងនឹងការប្រមូលទិញដី ព្រមទាំងតម្រូវការនៃការតាំងទីលំនៅថ្មី"។[66] បណ្តឹងគួរតែដាក់ទៅកាន់គណៈកម្មាធិការបណ្តឹងថ្នាក់ឃុំ។ ប្រសិនបើគណៈកម្មាធិការនេះមិនឆ្លើយតបក្នុងរយៈពេល ១៥ថ្ងៃ ឬខកខានក្នុងការដោះស្រាយបណ្តឹង អ្នកដាក់ពាក្យបណ្តឹងអាចបន្តទៅគណៈកម្មាធិការថ្នាក់ស្រុក និងអាចបន្តដល់ថ្នាក់ខេត្ត។ IEE បញ្ជាក់ថាប្រជាពលរដ្ឋអាចប្តឹងទៅតុលាការបើពួកគេមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការថ្នាក់ខេត្ត។

នៅពេលដែលទទួលបានពាក្យបណ្តឹង គណៈកម្មាធិការទទួលបន្ទុកដោះស្រាយបណ្តឹងត្រូវទាក់ទងទៅក្រុមហ៊ុនម៉ៅការសាងសង់ និង PIU ដើម្បីដោះស្រាយបណ្តឹង។ កំណត់ត្រានៃពាក្យបណ្តឹង កិច្ចប្រជុំរបស់គណៈកម្មាធិការ និងដំណោះស្រាយដែលបានធ្វើឡើង ត្រូវបង្ហាញឲ្យអ្នកប្តឹងបានដឹងឮ និង "គួរតែផ្តល់ជូនទៅ [មន្ទីរទេសចរណ៍] PIU, ADB ប្រសិនបើមានការស្នើសុំ"។[67] PCU ទទួលខុសត្រូវក្នុងការត្រួតពិនិត្យយន្តការបណ្តឹង និងអាចស្នើឲ្យមានសកម្មភាពបន្ថែមទៀតដើម្បីដោះស្រាយពាក្យបណ្តឹង។ ក្នុងឯកសារគម្រោងមិនបានបញ្ជាក់ច្បាស់ថា PCU នឹងទទួលបានព័ត៌មានស្តីពីបណ្តឹង មុនពេលគណៈកម្មាធិការបណ្តឹង ដោយរបៀបណានោះទេ។ ទីប្រឹក្សាគ្រប់គ្រង និងគូរប្លង់លម្អិត "នឹងផ្តល់វគ្គបណ្តុះបណ្តាលដែលចាំបាច់ដើម្បីពង្រឹងនីតិវិធីបណ្តឹង និងយុទ្ធសាស្ត្រសម្រាប់សមាជិកគណៈកម្មាធិការបណ្តឹង ប្រសិនបើតម្រូវឲ្យធ្វើបែបនោះ"។[68] ប្រជាពលរដ្ឋក៏អាចដាក់ពាក្យបណ្តឹងទៅកាន់យន្តការដោះស្រាយទំនាស់ផ្ទៃក្នុងរបស់ ADB បានដែរ។

គុណសម្បត្តិមួយចំនួននៃយន្តការបណ្តឹង តាមការស្នើរបស់ក្រសួងទេសចរណ៍។ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ អាចដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការបណ្តឹងថ្នាក់ឃុំដោយងាយស្រួល ប្រសិនបើគណៈកម្មាធិការនេះត្រូវបានបង្កើតនៅតាមឃុំទាំងអស់ ដែលមានប្រជាពលរដ្ឋដែលរងផលប៉ះពាល់ (ដូចជាឃុំត្រពាំងសង្កែ និងឃុំកូនសត្វ)។ កំណែចុងក្រោយបង្អស់នៃ EMP/EIA តម្រូវឲ្យបញ្ជាក់ថាគណៈកម្មធិការអាចមានអំណាចត្រឹមកម្រិតណា ដើម្បីផ្លាស់ប្តូរឥរិយាបទរបស់ក្រុមហ៊ុនម៉ៅការសាងសង់ និងតើសហគមន៍អាចទទួលបានព័ត៌មាន ពាក្យណែនាំ និងជំនាញដែលចាំបាច់ដើម្បីចូលរួមក្នុងយន្តការបណ្តឹងដោយរបៀបណា។ តំណាងពិសេសនៃអគ្គលេខាធិការ អង្គការសហប្រជាជាតិ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស បានលើកឡើងថា យន្តការបណ្តឹងគួរតែស្របច្បាប់ អាចប្រើប្រាស់

65 ទំព័រ ៤៤ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

66 ទំព័រ ៤៤ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

67 ទំព័រ ៤៤ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

68 ទំព័រ ៤៥ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ADB ខែមីនា ឆ្នាំ២០១៤។

បាន អាចព្យាករណ៍បាន មានសមភាព ស្របនឹងសិទ្ធិ និងតម្លាភាព។[69] ការរៀបចំយន្តការបណ្តឹងលម្អិតគួរតែបញ្ចូលនូវគោលការណ៍ទាំងអស់នេះ។

ក្រុមស្រាវជ្រាវបានសួរយោបល់ពីប្រជាពលរដ្ឋ ស្តីពីដំណើរការដាក់ពាក្យបណ្តឹង និងការរាយការណ៍ដូចដែលបានស្នើ។ យោបល់ស្តីពីដំណើរការនៃការរាយការណ៍ គឺស្រដៀងទៅនឹងការផ្តល់យោបល់ស្តីពីកិច្ចពិគ្រោះយោបល់។ ប្រជាពលរដ្ឋបានផ្តល់អនុសាសន៍ថា ព័ត៌មានគួរតែផ្តល់តាមរយៈសហគមន៍នេសាទ ឬប្រធានភូមិ និងប្រធានក្រុមប្រឹក្សាឃុំ ខណៈដែលប្រជាពលរដ្ឋខ្លះចង់ឲ្យមានការផ្តល់ព័ត៌មានដោយផ្ទាល់តាមរយៈកិច្ចប្រជុំរួម។ អ្នកដែលចូលរួមក្នុងការសម្ភាសន៍ខ្លះបានយល់ស្របថា បណ្តឹងនឹងអាចដោះស្រាយបានយ៉ាងល្អបំផុតដោយអាជ្ញាធរថ្នាក់ភូមិ ឬថ្នាក់ឃុំជាមុន។ អ្នកខ្លះទៀតបានលើកឡើងថា សហគមន៍នេសាទគួរតែតំណាងឲ្យដើមបណ្តឹងនៅក្នុងដំណើរការ។ អ្នកចូលរួមក្នុងការសម្ភាសន៍ម្នាក់បានលើកឡើងថា អាជ្ញាធរមូលដ្ឋានមិនអាចមានអំណាចគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរឥរិយាបទក្រុមហ៊ុន ឬស្ថាប័នរដ្ឋាភិបាលនោះទេ ដូច្នេះគាត់ស្នើថាបណ្តឹងគួរតែដាក់ជូនទៅរដ្ឋបាលជលផលជំនាញ។ អ្វីដែលសំខាន់គួរធ្វើនៅក្នុងដំណើរការនៃកិច្ចពិគ្រោះយោបល់ដែលនឹងធ្វើឡើងជាបន្តបន្ទាប់នោះគឺ អ្នកអនុវត្តគម្រោងត្រូវស្នើសុំយោបល់ពីអ្នកនេសាទ អំពីភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃយន្តការរាយការណ៍ និងដាក់ពាក្យបណ្តឹង។[70]

## អនុសាសន៍
## ក្រសួងទេសចរណ៍ និងមន្ទីទេសចរណ៍៖

- បញ្ចូលអ្នកនេសាទដែលរស់នៅឃុំកូនសត្វ និងឃុំត្រពាំងសង្កែ ជាប្រពលរដ្ឋដែលអាចរងផលប៉ះពាល់ ទៅក្នុងកិច្ចពិគ្រោះយោបល់ និងផែនការផ្តល់ព័ត៌មានសម្រាប់គម្រោងកំពង់ផែទេសចរណ៍កំពត។
- ធ្វើការសិក្សាបន្ថែមទៀត ដើម្បីកំណត់ចំនួនសរុបរបស់សហគមន៍ ដែលមកនេសាទនៅតំបន់កោះស្មៅ ឬធ្វើដំណើរទៅមករវាងកោះស្មៅ និងឆ្នេរដើម្បីផ្គត់ផ្គង់ជីវភាពរបស់ពួកគេ ព្រមទាំងបញ្ចូលពួកគេទៅក្នុងកិច្ចពិគ្រោះយោបល់ និងផែនការរាយការណ៍។

[69] តំណាងពិសេសរបស់អគ្គលេខាធិការ ស្តីពី បញ្ហាសិទ្ធិមនុស្ស និងសាជីវកម្មអន្តរជាតិ និងសហគ្រាសធុរកិច្ច "ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ រួមទាំង សិទ្ធិក្នុងការអភិវឌ្ឍន៍ ៖ ការពារ គោរព និងសំណង ៖ ក្របខ័ណ្ឌសម្រាប់ធុរកិច្ច និងសិទ្ធិមនុស្ស" ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨។ អាចរកបាន ៖ http://www2.ohchr.org/english/bodies/hrcouncil/docs/8session/A-HRC-8-5.doc.

[70] ក្នុងទិដ្ឋភាពនេះ សូមអានជំបូន្មានរបស់ ការិយាល័យទីប្រឹក្សាផ្នែកអនុលោមតាមច្បាប់/មន្ត្រីទទួលបន្ទុកស៊ើបអង្កេត នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ភ្នាក់ងារធានាការវិនិយោគសហភាគី សមាជិកនៃក្រុមធនាគារពិភពលោក "កំណត់សម្គាល់ទីប្រឹក្សា ៖ មគ្គទេសក៍សម្រាប់ការគូរប្លង់ និងអនុវត្តយន្តការសោទុក្ខសម្រាប់គម្រោងអភិវឌ្ឍន៍" ឆ្នាំ២០០៨។ អាចរកបាន ៖ http://www.cao-ombudsman.org/howwework/advisor/documents/implemgrieveng.pdf.

- បកប្រែសេចក្តីសង្ខេបនៃការសិក្សាបរិស្ថានបឋមជាភាសាខ្មែរ និងដាក់ជាសាធារណៈនៅលើប្រព័ន្ធអ៊ីនធឺណែតដែលអាចទាញយកបាន។
- ធានាថាមានការចូលរួមពិគ្រោះយោបល់យ៉ាងពេញលេញ ជាមួយសហគមន៍ដែលអាចរងផលប៉ះពាល់ កាន់តែប្រសើរ ប្រសិនបើអនុលោមតាមគោលការណ៍ស្តីពីការជូនដំណឹងជាមុន និងព្រមព្រៀងដោយសេរី តាមរយៈ ៖
  - រៀបចំកិច្ចប្រជុំជាសាធារណៈក្នុងសហគមន៍ដែលរងផលប៉ះពាល់ និងចែកចាយព័ត៌មានជាភាសាខ្មែរក្នុងកិច្ចប្រជុំទាំងនេះ នៅតាមសាលាឃុំ លើប្រព័ន្ធអ៊ីនធឺណែត និងតាមបណ្តាញសង្គម
  - ពន្យល់ពីគម្រោងកំពង់ផែទេសចរណ៍កំពត ក្នុងដំណាក់កាលបច្ចុប្បន្ន ផែនការត្រួតពិនិត្យ និងរាយការណ៍ពីផលប៉ះពាល់នៃគម្រោង និងយន្តការបណ្តឹងដែលត្រូវបានស្នើ និង
  - ស្នើ និងបែងចែកឲ្យមានពេលគ្រប់គ្រាន់សម្រាប់ឲ្យប្រជាពលរដ្ឋ ផ្តល់យោបល់ឲ្យបានគ្រប់ជ្រុងជ្រោយពាក់ព័ន្ធគ្រប់ទិដ្ឋភាពគម្រោង រួមទាំងផែនការត្រួតពិនិត្យ រាយការណ៍ និងយន្តការបណ្តឹង។
- យ៉ាងហោចណាស់ ការរាយការណ៍ទៅប្រជាពលរដ្ឋដែលអាចរងផលប៉ះពាល់ គួរតែដាក់បង្ហាញរបាយការណ៍ប្រចាំត្រីមាសរបស់ PIU ទៅកាន់ PCU ជាសាធារណៈ ដោយភ្ជាប់នឹងឧបសម្ព័ន្ធនៃរបាយការណ៍មកពី EMC និងក្រុមហ៊ុនម៉ៅការសាងសង់។
- តម្រូវឲ្យគ្រប់ឯកសារបណ្តឹងទាំងអស់ ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ត្រីមាសរបស់ PIU ទៅកាន់ PCU។
- ត្រូវធានាថាប្រជាពលរដ្ឋទាំងអស់បានយល់ថា ពួកគេអាចសុំជំនួយពីតុលាការគ្រប់ពេលវេលា និងការចូលរួមរបស់ពួកគេក្នុងយន្តការបណ្តឹងមិនប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។

## ធនាគារអភិវឌ្ឍន៍អាស៊ី

- ធានាថាប្រជាពលរដ្ឋដែលអាចរងផលប៉ះពាល់យល់ពីយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

# ជំពូកទី ៦ ៖ គម្រោងផ្សេងទៀតនៅឆកសមុទ្រកំពត

ក្នុងអំឡុងពេលនៃការស្រាវជ្រាវសម្រាប់របាយការណ៍នេះ សមាជិកសហគមន៍ និងមន្ត្រីរដ្ឋាភិបាល បានចែករំលែកព័ត៌មានដល់ក្រុមអ្នកស្រាវជ្រាវ អំពីគម្រោងថ្មីៗ នៅលើឆកសមុទ្រកំពតដែលបង្កផលប៉ះពាល់ដល់សិទ្ធិប្រជាពលរដ្ឋ និងសំណើសម្រាប់គម្រោងអភិវឌ្ឍន៍ថ្មីទៀតដែលអាចនឹងមានផលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេផងដែរ។ គម្រោងទាំងនេះមិនមែនជាចំណុចផ្តោតសំខាន់ ដូចបានចែងក្នុងលក្ខខ័ណ្ឌអនុវត្តគម្រោង សម្រាប់ការស្រាវជ្រាវ និងបាយការណ៍នេះនោះទេ ហើយក្រុមការងារក៏មិនអាចធ្វើការសន្និដ្ឋានឲ្យជាក់ច្បាស់ស្តីពីគម្រោងទាំងនេះ ដរាបណាក្រុមការងារមិនទាន់បានធ្វើការស្រាវជ្រាវបន្ថែមទៀតនោះ។ ទោះបីជាយ៉ាងនេះក៏ដោយ យោងតាមព័ត៌មានដែលក្រុមការងារទទួលបានកន្លងមក មានការព្រួយបារម្ភថា ប្រសិនបើគម្រោងដែលបានដាក់ស្នើនេះអនុញ្ញាតឲ្យដំណើរការទៅមុខ ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើសិទ្ធិរបស់ប្រជាពលរដ្ឋ គឺមិនអាចចៀសផុតទេ។

## ការអភិវឌ្ឍន៍ថ្មីៗ

ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ ការអភិវឌ្ឍន៍នៅលើឆកសមុទ្រខេត្តកំពត បានបំផ្លាញដល់ប្រព័ន្ធអេកូឡូស៊ី កាត់បន្ថយប្រភពធនធាន និងការចាប់យកធនធាន ដែលប្រជាពលរដ្ឋភាគច្រើនពឹងផ្អែកលើសម្រាប់ផ្គត់ផ្គង់ជីវភាពរបស់ពួកគេ។ ចាប់តាំងពី ឆ្នាំ២០១០ មក អាជ្ញាធរខេត្តកំពតបានអនុញ្ញាតឲ្យមានការចាក់បំពេញដីតាមបណ្តោយឆ្នេរសមុទ្រ ក្នុងឃុំជុំគ្រៀល។ ព្រៃកោងកាងដែលដុះនៅតាមបណ្តោយឆ្នេរត្រូវបានកាប់បំផ្លាញ។ ទាំងអ្នកនេសាទ និងរូបភាពផ្កាយរណបដែលក្រុមការងារទទួលបាន (សូមមើលរូបទី ១០) សុទ្ធតែអះអាងពីការផ្លាស់ប្តូរនេះ។[71] កំពង់ផែទេសចរណ៍កំពតនេះ នឹងត្រូវសាងសង់ឡើងលើផ្ទៃដីបួនហិកតា ជាដីសមុទ្រដែលត្រូវបានចាក់បំពេញ។

អាជ្ញាធរខេត្តកំពត បានធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនមួយ ដើម្បីសាងសង់កំពង់ផែពាណិជ្ជកម្មអន្តរជាតិលើផ្ទៃដីពីរហិកតា ជាដីសមុទ្រដែលត្រូវបានចាក់បំពេញ។ ដើម្បីអនុញ្ញាតឲ្យទូកធំៗ ចូលមកក្នុងកំពង់ផែនេះបាន អាជ្ញាធរខេត្តកំពតក៏ធ្លាប់អនុញ្ញាតឲ្យក្រុមហ៊ុនស្តារឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូឲ្យកាន់តែជ្រៅថែមទៀត កាលពីអំឡុង ឆ្នាំ២០១៤។[72] ដីដែលបានមកពីការជីកនោះ ត្រូវបានយកមកចាក់ចោលក្បែរឃ្លោង ដើម្បីបង្កើតជាទំនប់។

---

[71] សក្ខីភាព និងរូបភាពផ្កាយរណប ដែលហាក់ដូចជាផ្ទុយនឹងការអះអាងក្នុងការសិក្សាបរិស្ថានបឋម ដែលថា "ព្រៃកោងកាង ដែលធ្លាប់ដុះជាជួរ នៅខាងកើតច្រាំងទន្លេត្រូវបានអ្នកអភិវឌ្ឍន៍ដីធ្លី តាំងពីមុនឆ្នាំ ២០០៥ មកម្លេះ" ទំព័រ ២១ ក្នុង "ការសិក្សាបរិស្ថានបឋម" របស់ ខែមីនា ឆ្នាំ២០១៤។

[72] កិច្ចសម្ភាសន៍ជាមួយសមាជិកសហគមន៍ មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន និងមន្ទីរបរិស្ថាន ខែកញ្ញា ឆ្នាំ២០១៦។

តំបន់ឆ្នេរសមុទ្រ គឺជាធនធានយ៉ាងសំខាន់សម្រាប់អ្នកនេសាទក្នុងតំបន់។ ព្រៃកោងកាងផ្ដល់កន្លែងសម្រាប់ត្រីបង្កាត់ពូជ ទីជម្រកសម្រាប់អ្នកនេសាទ និងទឹករាក់ៗសម្រាប់ចាប់បង្គា។ ការចាក់បំពេញដីបានបំផ្លាញព្រៃកោងកាង និងប្រព័ន្ធអេកូឡូស៊ី។ ទំនប់ឃ្លោងត្រូវបានសង់ឡើងចំពីលើស្មៅសមុទ្រ។ ទាំងការចាក់ដីបំពេញ និងការសង់ទំនប់ ទំនងជាបង្កើនបរិមាណដីល្បាប់ក្នុងទឹកសមុទ្រ និងបង្កការសឹករិចរិលលើគម្របស្មៅសមុទ្រនៅឆកសមុទ្រកំពត។

អ្នករាវគ្រែងម្នាក់ មានអាយុ ៥៥ ឆ្នាំ ៥៤ បានប្រាប់ក្រុមអ្នកស្រាវជ្រាវអំពីផលប៉ះពាល់នៃការរៀបចំដី និងការបូមខ្សាច់។

> *"នៅពេលដែលពួកគេបំពេញដីលើព្រៃកោងកាង កាលពីប្រមាណបួនឆ្នាំមុន ខ្ញុំមិនអាចរាវគ្រែងនៅទីនោះបានទៀតទេ។ នៅទីនោះ ធ្លាប់មានស្មៅសមុទ្រកម្ពស់ ២០ សង់ទីម៉ែត្រ ហើយគ្រែងពឹងផ្អែកលើស្មៅសមុទ្រនេះ។ ដូច្នេះពេលដែលពួកគេបានចាក់បំពេញដី ហើយខ្សាច់ដែលរសាត់ចេញនោះមកគ្របលើស្មៅសមុទ្រ ធ្វើឲ្យស្មៅសមុទ្រទាំងនោះងាប់អស់។ ពួកយើងក៏ធ្លាប់នេសាទនៅលើឃ្លោងសមុទ្រនេះដែរ។ ហើយប្រហែលជាមួយឆ្នាំមុន ពួកគេបានចាក់ដីដែលកាយចេញពីបាតព្រែក មកលើខ្នងឃ្លោង ដែលធ្វើឲ្យស្មៅសមុទ្រងាប់យ៉ាងច្រើន។ ប្រជាពលរដ្ឋជាច្រើនធ្លាប់ប្រមូលធនធាននៅទីនោះ។"*[73]

បើយោងតាមសមាជិកនៃគណៈកម្មាធិការសហគមន៍នេសាទត្រពាំងសង្កែការជីកឃ្លោងសមុទ្រ ក៏មានផលប៉ះពាល់ដល់ការលូតលាស់នៃដើមកោងកាងផងដែរ។

> *"យើងដាំដើមកោងកាងនៅតំបន់ភក់ ប៉ុន្តែពេលដែលពួកគេធ្វើទំនប់ ទឹកក៏កខ្វក់។ ឥឡូវនេះទឹកបានហូរនាំខ្សាច់ចេញពីឃ្លោងសមុទ្រ ហើយហូរលើដើមកោងកាង និងគ្របលើដើមកោងកាងទាំងនោះ ធ្វើឲ្យពួកវាមិនដុះលូតលាស់បាននោះទេ។"*[74]

ការស្ដារឃ្លោងសមុទ្រឲ្យកាន់តែជ្រៅ និងការធ្វើទំនប់ ក៏បង្កការលំបាកសម្រាប់អ្នកនេសាទក្នុងការរកមើលប្រភពធនធាន នៅតំបន់កោះស្មៅ និងឆ្នេរសមុទ្រក្បែរភ្នំដូងផងដែរ។ អ្នកនេសាទមួយចំនួន បានជូនដំណឹងដល់ក្រុមអ្នកស្រាវជ្រាវថា ចាប់តាំងពីឃ្លោងសមុទ្រត្រូវបានសាងសង់ឡើង ពួកគេត្រូវធ្វើដំណើរវាងជុំវិញឃ្លោងសមុទ្រនេះដើម្បីទៅកាន់កោះស្មៅ និងភ្នំដូង ដូច្នេះធ្វើឲ្យពួកគេចំណាយពេលវេលា និងថវិកាក្នុងការធ្វើដំណើរ។

[73] កិច្ចសម្ភាសន៍ជាមួយស្ត្រីម្នាក់ ក្នុងឃុំត្រពាំងស្ដែ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។

[74] កិច្ចពិភាក្សាជាមួយ គណៈកម្មាធិការសហគមន៍នេសាទត្រពាំងសង្កែ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦។

អ្នកចូលរួមក្នុងការសម្ភាសន៍ជាច្រើនបានបញ្ជាក់ថា ប្រាក់ចំណូលរបស់ពួកគេបានថយចុះ ដោយសារតែការបំផ្លាញប្រព័ន្ធអេកូឡូស៊ី ដោយសារតែ ការចាក់ដីបំពេញ និងការស្តារឃ្លោងសមុទ្រ។ ការស្រាវជ្រាវបន្ថែមទៀតគឺចាំបាច់ ដើម្បីអាចរកអំណះអំណាងភ្ជាប់រវាងការអភិវឌ្ឍន៍ ទាំងនេះ ទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ទោះជាយ៉ាងណា សក្ខីកម្មរបស់សមាជិកសហគមន៍ គឺស្របជាមួយនឹងរបាយការណ៍របស់សហភាពអន្តរជាតិដើម្បីការអភិរក្សធនធានធម្មជាតិ ស្តីពីគម្រមស្មៅសមុទ្រក្នុងខេត្តកំពត ដែលរកឃើញថាមានសម្ពាធកើនឡើងមកលើប្រភពធនធានតាមបណ្តោយឆ្នេរ ជាលទ្ធផលមកពីកំណើនអ្នកនេសាទ ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និងគម្រោងអភិវឌ្ឍន៍ឆ្នេរសមុទ្រ។[75]

រូបភាពទី ១០ ៖ រូបភាពផ្កាយរណបនៃមាត់ស្ទឹងទឹកឈូ បង្ហាញពីការរៀបចំដីសាជាថ្មី និងការរៀបចំស្តារឃ្លោងសមុទ្រ តាំងពីឆ្នាំ២០០០ ដើម្បីសាងសង់ផែអន្តរជាតិ។ ©DigitalGlobe and CNES / Astrium.




រូបភាពទី ១០ (ក) ៖ រូបភាពផ្គុំគ្នា នៃខែធ្នូ ឆ្នាំ២០០០ និងខែឧសភា ឆ្នាំ២០១០។




រូបភាពទី ១០ (ខ) ៖ រូបភាពផ្គុំគ្នា នៃខែធ្នូ ឆ្នាំ២០១១ និងខែឧសភា ឆ្នាំ២០១០។




រូបភាពទី ១០ (គ) ៖ រូបភាពពីខែធ្នូ ឆ្នាំ២០១៤




រូបភាពទី ១០ (ឃ) ៖ រូបភាពផ្គុំគ្នា នៃខែធ្នូ ឆ្នាំ២០១៥ និងខែធ្នូ ឆ្នាំ២០១៤។

[75] Kaarlep, A., "ការស្ទង់មតិផ្នែកសង្គមសេដ្ឋកិច្ច ស្តីពីសារៈសំខាន់នៃគម្រមស្មៅសមុទ្រ មកលើសហគមន៍រស់នៅតាមបណ្តោយឆ្នេរក្នុងខេត្តកំពត" ឆ្នាំ២០១៤។

នៅពេលដែលក្រុមស្រាវជ្រាវបានចុះទៅខេត្តកំពត សកម្មភាពស្តារ និងពង្រីកឃ្លោងសមុទ្រកំពុងតែដំណើរការ។ កម្មករនៅលើសាឡង់មួយកំពុងតែជីកដីពីបាតព្រែក និងពង្រីកប្រាំងនៅខាងចុងនៃឃ្លោងសមុទ្រ (សូមមើលរូបភាពទី ១១)។ សកម្មភាពទាំងនេះកំពុងតែ កំហិតទីតាំងមិនឲ្យទូកអាចបើកបរឆ្លងកាត់ទៅកោះស្មោ និងភ្នំដូងបានទៀតនោះទេ។


រូបភាពទី ១១ ៖ ការជីកដីនៅក្បែរទីតាំងស្នើសម្រាប់សាងសង់កំពង់ផែទេសចរណ៍កំពត។ កោះស្មោ គឺមើលឃើញនៅខាងឆ្វេងដៃ។

## ទីក្រុងកំពតថ្មី

អាជ្ញាធរខេត្តកំពត បានរៀបចំសំណើសុំសាងសង់កោះសិប្បនិម្មិតមួយនៅឆកសមុទ្រកំពត សម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍។ កោះនេះ នឹងមានទីលានវាយកូនហ្គោល សាលតាំងពិព័រណ៌ ភោជនីយដ្ឋាន និងអាងហែលទឹក។ កោះនេះនឹងត្រូវការផ្ទៃដីប្រមាណ ២៤៨ ហិកតានៃដីសមុទ្រ ហើយសាងសង់គ្របលើតម្របស្មៅសមុទ្រដែលកំពុងតែដុះលូតលាស់ក្នុងឆកសមុទ្រនេះ។ ផែនការមេសម្រាប់ក្រុងកំពតថ្មី បង្ហាញថាការអភិវឌ្ឍន៍នេះនឹងគ្របដណ្តប់លើសហគមន៍នេសាទត្រពាំងសង្កែ និងសហគមន៍នេសាទកំពង់សាមគ្គី (សូមមើលរូបភាពទី ១២)។

កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ អតីតអភិបាលខេត្តកំពត ប្រធានក្រុមប្រឹក្សាខេត្ត និងអគ្គលេខានៃគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះហត្ថលេខាលើគម្រោងការមេមួយនេះ។ បើយោងតាមមន្ត្រីរដ្ឋាភិបាលមូលដ្ឋានបានឲ្យដឹងថា គម្រោងនេះគឺកំពុងរង់ចាំការអនុម័តចេញពីក្រសួង មុនពេលដែលផែនការលម្អិតត្រូវចាប់ផ្តើមគ្រោង និងស្វែងរកថវិកាដើម្បីអនុវត្តគម្រោង។ ដូចបានកត់សម្គាល់ពីមុន អាជ្ញាធរខេត្តកំពតបានបង្ហាញពីផែនការរបស់ខ្លួន ស្តីពីគម្រោងក្រុងកំពតថ្មីនេះទៅដល់ប្រធានក្រុមប្រឹក្សាឃុំនានា កាលពី ឆ្នាំ២០១៤ ក្រុមអ្នកស្រាវជ្រាវទទួលដំណឹងថាការពិគ្រោះយោបល់លម្អិតបន្ថែមទៀត អាចនឹងត្រូវបានរៀបចំឡើង ក្នុងអំឡុងពេលដំណាក់កាលគូរប្លង់លម្អិត ប្រសិនបើក្រសួងអនុញ្ញាត។ ក្រុមអ្នកសិក្សាស្រាវជ្រាវមិនអាចជួបជាមួយអភិបាលខេត្តកំពតដើម្បីពិភាក្សាលើគម្រោងនេះបានទេ។




រូបភាពទី ១២៖ ផែនការមេ សម្រាប់គម្រោងទីក្រុងកំពតថ្មី ចុះហត្ថលេខានៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤។ ឆ្នេរសមុទ្រក្នុងឃុំជុំគ្រៀល និងកោះស្មៅមានឃើញក្នុងផែនទីដែរ។

**French Riviera City**

កាលពីខែតុលា ឆ្នាំ២០១៦ សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍ បានរាយការណ៍ពីផែនការនានា របស់ ក្រុមហ៊ុនវិនិយោគ និងអភិវឌ្ឍន៍ Pallas ដែលគ្រោងនឹងសាងសង់កោះសិប្បនិម្មិតចំនួនពីរ កាត់ខេត្តកែប និងខេត្តកំពត ដែលមានឈ្មោះថា French Riviera City។[76] គេហទំព័ររបស់ក្រុមហ៊ុន Pallas បានពណ៌នាទីក្រុងនេះថាជា "គោលដៅលំដាប់ពិភពលោក សម្រាប់រស់នៅ កំសាន្ត និងធ្វើជំនួញ" ហើយគេហទំព័រ នេះលើកបន្ថែមថា គម្រោងនេះនឹងរួមបញ្ចូលកន្លែងទាក់ទាញផ្សេងៗ ដូចជា "សួនទឹក ឆ្នេរសិប្បនិម្មិត និងឆ្នេរឯកជន ទីលានវាយកូនហ្គោល កំពង់ផែសម្រាប់លំហែ ខ្ចីបប្រណាំងទូក និងល្បែងប៉ូឡូ"។[77] ក្នុងគេហទំព័ររបស់ក្រុមហ៊ុន Pallas បានបញ្ជាក់ថា ការអភិវឌ្ឍន៍នេះនឹងគ្របដណ្តប់ផ្ទៃដី ៦,០៥៦ ហិកតា ខណៈពេលដែលឯកសាររបស់រដ្ឋាភិបាល បើយោងតាមការរាយការណ៍របស់សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍ បង្ហាញនូវគម្រោងដែលត្រូវប្រើដី "៤,១៥៨ ហិកតា ជារមណីយដ្ឋាន

[76] ភ្នំពេញ ប៉ុស្តិ៍ "រដ្ឋាភិបាលអនុម័តគម្រោងទេសចរណ៍ ២៣ ពាន់លាន" ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦។ អាចរកបាន ៖ http://www.phnompenhpost.com/business/massive-232b-project-gets-green-light.

[77] ក្រុមហ៊ុន Pallas វិនិយោគ "French Riviera City"។ អាចរកបាន ៖ http://pallasinvestmentgroup.com/kampot/.

ទេសចរណ៍ចម្រុះបែប និងកំពង់ផែសម្រាប់លំហែចំនួន ១៤៤ ហិកតា" ។ ទោះបីជាគេហទំព័ររបស់ក្រុមហ៊ុនបានបញ្ជាក់ថាគម្រោងនេះ "ត្រូវបានបង្កើតឡើងដោយមិនប៉ះពាល់ដល់បរិស្ថាន" ក៏ដោយ រូបភាពជាច្រើនលើគេហទំព័រនោះ បានបង្ហាញថាការសាងសង់នេះ នឹងធ្វើឡើងនៅចំពីលើស្មៅសមុទ្រ តាមបណ្ដោយឆ្នេរ (មើលរូបភាពទី ១៣)។

បើយោងតាមសារព័ត៌មាន ភ្នំពេញ ប៉ុស្ដិ៍ ទឹកប្រាក់ចំនួន ២៣. ២ ពាន់លាន ដុល្លារអាមេរិកសម្រាប់ចំណាយលើគម្រោងនេះ នឹងគាំទ្រដោយក្រុមហ៊ុន Pallas ដែលទីតាំងនៅទីក្រុងឌូបៃ។[78] ក្រសួងបរិស្ថានកំពុងតែត្រួតពនិត្យឡើងវិញនូវ ការវាយតម្លៃផល ប៉ះពាល់បរិស្ថាន នៃគម្រោងនេះ ហើយគម្រោងនេះកំពុងរង់ចាំការអនុម័តពី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។




រូបភាពទី ១៣ ៖ រូបភាពរបស់ French Riviera City បានពីវេបសាយរបស់ ក្រុមហ៊ុនវិនិយោគ និងអភិវឌ្ឍន៍។ ឆ្នេរសមុទ្រក្នុងឃុំជុំគ្រៀល និងកោះស្មៅអាចមើលឃើញបាន នៅជ្រុងឆ្វេងខាងលើនៃទីតាំងដែលស្នើសម្រាប់ការអភិវឌ្ឍន៍។

ក្រុងកំពតថ្មី និង French Riviera City នឹងបំផ្លាញតំបន់គម្របស្មៅសមុទ្រដ៏ធំជាងគេនៅក្នុងឆកសមុទ្រកំពត។ ដោយសារតែគម្របស្មៅទាំងនេះ ជាគ្រឹះសំខាន់សម្រាប់ប្រព័ន្ធអេកូឡូស៊ី គម្រោងនេះមិនអាចសាងសង់ទៅបាន ដោយមិនបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានជីវភាពរស់នៅសមស្របបាននោះទេ។ បន្ថែមពីលើនោះទៅទៀត គម្រោងនេះបង្កជាហានិ

[78] ភ្នំពេញ ប៉ុស្ដិ៍ "មានការសង្ស័យជាច្រើនមកលើគម្រោងអភិវឌ្ឍន៍តាមបណ្ដោយឆ្នេរ" ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦។ អាចរកបាន ៖ http://www.phnompenhpost.com/business/scepticism-clouds-massive-coastal-development-plan.

ភ័យ ព្រោះថាគម្រោងបានទាក់ទាញបុគ្គលដែលមានអំណាច ទាំងនយោបាយ និងសេដ្ឋកិច្ច មកប្រមូលទិញដីនៅក្នុងឃុំដែលបានសិក្សាសម្រាប់របាយការណ៍នេះ។ ប្រជាពលរដ្ឋគួរតែទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយហានិភ័យផ្សេងៗ ដែលគម្រោងអភិវឌ្ឍន៍នេះអាចបង្កមកលើសិទ្ធិដីធ្លីរបស់ពួកគេ។

## អនុសាសន៍

### អាជ្ញាធរខេត្តកំពត ៖

- ចាប់ផ្តើមរៀបចំកិច្ចពិគ្រោះយោបល់អោយបានពេញលេញ លើករណីការបន្តស្តារឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូ ជាមួយអ្នកនេសាទ ដែលកំពុងប្រើប្រាស់ផ្លូវទឹកមួយនេះ។
- ផ្អាករាល់ការស្តារឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូ ជាមុនសិន រហូតការពិគ្រោះយោបល់ត្រូវបានរៀបចំរួចស្រេច។
- នៅពេលអាជ្ញាធរខេត្តកំពតបង្កើតផែនការសម្រាប់ ក្រុងកំពតថ្មី អាជ្ញាធរទាំងនេះគួរតែផ្សព្វផ្សាយព័ត៌មាន និងរៀបចំកិច្ចពិគ្រោះយោបល់អោយបានពេញលេញជាមួយប្រជាពលរដ្ឋដែលអាចនឹងរងផលប៉ះពាល់។

### មន្ទីររៀបចំដែនដី ៖

- ចាប់ផ្តើមចុះបញ្ជីដីធ្លីក្នុងភូមិដែលនៅសេសសល់ ក្នុងឃុំកូនសត្វ និងធានាថាអ្នកស្រុកនៅឃុំជុំគ្រៀល ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ បានទទួលកម្មសិទ្ធិដីធ្លីស្របច្បាប់ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ដើម្បីឲ្យពួកគេមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។

### ក្រសួងបរិស្ថាន ៖

- រៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ជាមួយប្រជាពលរដ្ឋដែលនឹងរងផលប៉ះពាល់ រួមទាំង EIAs សម្រាប់ក្រុងកំពតថ្មី និងFrench Riviera City។

### ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៖

- នៅពេលដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រួតពិនិត្យលើគម្រោងរបស់ French Riviera City ក្រុមប្រឹក្សានេះគួរបង្ហាញព័ត៌មានជាសាធារណៈ និងរៀបចំកិច្ចពិគ្រោះយោបល់អោយបានពេញលេញជាមួយប្រជាពលរដ្ឋដែលអាចនឹងរងផលប៉ះពាល់។

## សេចក្ដីសន្និដ្ឋាន

ព័ត៌មានដែលអាចរកបានជាសាធារណៈ បង្ហាញថាគម្រោងកំពង់ផែទេសចរណ៍កំពត នឹងមិនមានផលប៉ះពាល់មកលើសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋនោះទេ ប៉ុន្តែអាចនឹងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ ប្រសិនបើប្រព័ន្ធអេកូឡូស៊ីក្នុងឆកសមុទ្រកំពតត្រូវបានបំពុល ហើយអ្វីដែលសំខាន់ គឺត្រូវរៀបចំឲ្យមានកិច្ចពិគ្រោះយោបល់បន្ថែមទៀតដែលចាំបាច់ ដើម្បីធានាថា ប្រជាពលរដ្ឋអាចចូលរួមបានយ៉ាងពេញលេញក្នុងសេចក្ដីសម្រេចចិត្ត ដែលប៉ះពាល់ជីវិតរបស់ពួកគេ។

ការរៀបចំផែនការគម្រោងកំពង់ផែកំពត កំពុងតែដំណើរការបានយ៉ាងល្អ។ ថវិកាសម្រាប់អនុវត្តគម្រោងត្រូវបានព្រមព្រៀងគ្នា ក្នុងខែធ្នូ ឆ្នាំ២០១៤។ ក្នុងខែតុលា ឆ្នាំ២០១៥ អាជ្ញាធរខេត្តកំពត បានទិញដីសម្រាប់សាងសង់គម្រោងនេះមកពីម្ចាស់ដីដែលមានជីវភាពធូរធារម្នាក់។ ដូច្នេះ គម្រោងនេះមើលទៅហាក់ដូចជាមិនប៉ះពាល់ទៅលើសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋដោយផ្ទាល់នោះទេ។ ប៉ុន្តែ ការអភិវឌ្ឍន៍នៅពេលអនាគតក្នុងតំបន់ឆ្នេរ អាចនឹងបង្កការគំរាមកំហែងដល់ប្រជាពលរដ្ឋដែលគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់។ ការចុះបញ្ជីដីធ្លី ដែលកំពុងតែដំណើរការក្នុងឃុំជុំគ្រៀល ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ គួរតែធានាឲ្យបានថាប្រជាពលរដ្ឋអាចមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ មុនពេលដែលគម្រោងអភិវឌ្ឍន៍ផ្សេងអាចគំរាមកំហែងមកលើសិទ្ធិដីធ្លីរបស់ពួកគាត់។

ទីប្រឹក្សា កំពុងតែធ្វើការគូរប្លង់លម្អិត សម្រាប់គម្រោងកំពង់ផែទេសចរណ៍កំពត ហើយកំពុងតែបំលែង ផែនការតាមដានបរិស្ថាន (EMP) ឲ្យទៅជា ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ដើម្បីទទួលបានការអនុម័តពីក្រសួងបរិស្ថាន។ ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន គួរតែធានាថាវិធានការការពារបរិស្ថាន ដែលបានដាក់ស្នើក្នុង EIA គឺគ្រប់គ្រាន់សម្រាប់ការពារការបំពុលបរិស្ថាន និងប្រព័ន្ធតាមដានដែលអាចទទួលបានព័ត៌មានស្ដីពីការបំពុលភ្លាមៗ និងចាត់វិធានការឲ្យបានទាន់ពេលវេលា។ ទីប្រឹក្សាគ្រប់គ្រងបរិស្ថាន គួរតែឯករាជ្យ និងមានសមត្ថភាពទាំងផ្នែកធនធាន និងបច្ចេកទេសក្នុងការតាមដាន និងរាយការណ៍រាល់ការបំពុលនានា។ EIA គួរតែបញ្ជាក់ឲ្យច្បាស់ថា សកម្មភាពណាខ្លះដែលគួរតែធ្វើដើម្បីបញ្ឈប់ការបំពុល និងផ្ដល់សំណងចំពោះការខូចខាតដែលបានកើតឡើង។ បន្ថែមពីលើនោះ គម្រោងគ្រប់គ្រងនាវាចរណ៍ គួរតែធានាថាកំណើនទូកដែលមកប្រើប្រាស់កំពង់ផែមួយនេះ នឹងមិនរារាំងអ្នកនេសាទពីការប្រើប្រាស់ផ្លូវទឹកដ៏សំខាន់នេះនោះទេ។ សេចក្ដីសន្និដ្ឋានទាំងនេះ គួរតែត្រូវធ្វើការវាយតម្លៃម្ដងទៀត ពេលដែលផែនការសម្រាប់កំពង់ផែទេសចរណ៍ និង EIA ត្រូវបានសម្រេចជាចុងក្រោយ។

អ្នកចូលរួមសម្ភាសន៍មួយចំនួន បានលើកពីការព្រួយបារម្ភដែលបានដោះស្រាយរួចរាល់ក្នុង EMP។ ចំណុចនេះកត់សម្គាល់ថា ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ភាគច្រើន មិនបានទទួលដំណឹងគ្រប់

គ្រាន់ ឬក៏ចូលរួមពិគ្រោះយោបល់ស្តីពីគម្រោងនេះទេ។ កិច្ចពិគ្រោះយោបល់ទើបតែបានធ្វើឡើងជាមួយប្រជាពលរដ្ឋចំនួន ១០០ នាក់ ក្នុងឃុំជុំគ្រៀល និងឃុំកំពង់កណ្តាល។ ប្រជាពលរដ្ឋក្នុងឃុំមួយចំនួនទៀត រួមទាំង ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ ប្រកបរបរនេសាទក្នុងឆកសមុទ្រកំពត និងអាចនឹងរងផលប៉ះពាល់ ពីការបំផ្លិចបំផ្លាញណាមួយមកលើប្រព័ន្ធអេកូឡូស៊ី ក្នុងឆកសមុទ្រនេះ។ ពួកគេមិនដែលបានចូលរួមក្នុងកិច្ចពិគ្រោះយោបល់នោះទេ មកទល់ឥឡូវ សិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានព័ត៌មាន និងដើម្បីចូលរួមក្នុងជីវភាពសាធារណៈ មិនទាន់បានគោរពនៅឡើយទេ។ ក្រសួងទេសចរណ៍ ត្រូវធានាថាកិច្ចពិគ្រោះយោបល់នាពេលអនាគត ត្រូវរួមបញ្ចូលអ្នកដែលរងផលប៉ះពាល់ទាំងអស់ ជាកិច្ចពិគ្រោះយោបល់មួយប្រកបដោយអត្ថន័យ និងអនុលោមតាមគោលការណ៍ FPIC។

នៅមានគម្រោងមួយចំនួនទៀត ដែលកំពុងស្នើសុំការអនុម័តលើឆកសមុទ្រកំពត ដែលអាចនឹងមានផលប៉ះពាល់ជាខ្លាំងមកលើសិទ្ធិរបស់ប្រជាពលរដ្ឋ។ ការស្តារឃ្លោងសមុទ្រក្បែរស្ទឹងទឹកឈូ បានបណ្តាលឲ្យប្រព័ន្ធអេកូឡូស៊ីរងការខូចខាតរួចទៅហើយ។ សំណើសម្រាប់ការអភិវឌ្ឍន៍ក្រុងកំពតថ្មីទំហំប្រមាណ ២៤៨ ហិកតា និងប្រមាណ ៤,០០០ ហិកតា សម្រាប់គម្រោង French Riviera City បង្កឲ្យមានក្តីបារម្ភ។ ប្រសិនបើត្រូវបានសាងសង់ គម្រោងនេះច្បាស់ជាបង្កភាពខូចខាតដល់ជីវភាពរបស់ប្រជាពលរដ្ឋរាប់ពាន់នាក់ ជាមិនខាន។ រដ្ឋាភិបាល ត្រូវតែធានាថាមានការរៀបចំកិច្ចពិគ្រោះយោបល់ដ៏មានអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់ មុននឹងគម្រោងត្រូវបានអនុម័ត។

ការស្រាវជ្រាវនេះ ទទួលបានអនុសាសន៍ជាច្រើន ដើម្បីការពារសិទ្ធិរបស់អ្នកនេសាទក្នុងឆកសមុទ្រកំពត។ លើសពីនោះ ទោះបីជាពាក់ព័ន្ធនឹងគម្រោងកំពង់ផែទេសចរណ៍កំពត ឬគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត អាជ្ញាធរគួរតែធានាថាពួកគេនឹងស្តាប់ពីក្តីបារម្ភរបស់អ្នកដែលនឹងអាចរងផលប៉ះពាល់ ហើយប្រសិនបើនិយាយពីកិច្ចពិគ្រោះយោបល់វិញគឺត្រូវ បង់សំណាញ់ឲ្យទូលាយ។

របាយការណ៍នេះវាយតម្លៃអំពីផលប៉ះពាល់ដែលអាចកើតឡើងដោយសារតែគម្រោងកសាងកំពង់ផែរកំពតទៅលើសិទ្ធិដីធ្លី ជីវភាព និងសិទ្ធិក្នុងការពិគ្រោះយោបល់របស់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងបណ្តាឃុំដែលនៅក្បែរទីកន្លែងនោះ ដូចជាឃុំជុំគ្រាល ឃុំត្រពាំងសង្កែ និងឃុំកូនសត្វ នៅក្នុងខេត្តកំពត។




actionaid

ផ្ទះលេខ ៣៣ ផ្លូវ ៧១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ (៨៥៥-២៣) ៩៩៤ ៩៨៧

អ៊ីម៉ែល៖ e-mail.cambodia@actionaid.org